ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 24-Jan-2012, 14:24
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១២**

**ម៉ោង ០៩:០១ នាទី**

**សវនាការលើកទី១៩**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍

*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)

*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ម៉ាតេអូ គ្រីប៉ា

*(Mr.Matteo CRIPPA)*

លោក ឌុច ផារី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាស្មី

លោក សេង ប៊ុនឃាង

លោក ថារីក អាប់ឌុលឡាក់

*(Mr. Tarik ABDULHAK)*

លោកស្រី សារ៉ាស អេនឌ្រូ

*(Ms.Sarah ANDREWS)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន

*(Mr. Michiel PESTMAN)*

លោក ហ្សាស្ពើ ប៉ៅ*(Mr Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក ហ្សាក់ វែកហ្សេស

*(Mr. Jacques VERGES)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ឡៅ ជុនធី

លោក បាណាបេ ណេគ្វី

*(Mr. Barnabé NEKUIE)*

លោក វ៉ែន ពៅ

លោក ហុង គឹមសួន

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក កូវ កែវរតនៈ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| ចៅក្រម យ៉ា សុខន | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក អាប់ឌុលឡាក់ ថារីក | អង់គ្លេស |
| លោក វ៉ាន់ថាន់ ដាវ៉ាពៅ | ខ្មែរ |
| លោក នួន ជា | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅលោក វ៉ាន់ថាន់ ដារ៉ាពៅ** (TCW-766)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី .......... ទំព័រ ០៣

សួរដោយចៅក្រម យ៉ា សុខន ផ្តើមពី .......... ទំព័រ ០៥

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍ ផ្តើមពី .......... ទំព័រ ២០

សួរដោយចៅក្រម អាប់ឌុលឡាក់ ថារីក ផ្តើមពី .......... ទំព័រ ៥២

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:៥០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ តាមកាលវិភាគសវនាការ នៅក្នុងសប្តាហ៍នេះ អង្គជំនុំជម្រះនឹងដំណើរការស្តាប់សក្ខីកម្មសាក្សីចំនួនពីររូប។ ហើយនៅដើមសប្តាហ៍នេះ អង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មសាក្សី TCW-766។

ហើយមុននឹងដំណើរការ អង្គជំនុំជម្រះសូមជម្រាបជូនភាគីថា ថ្ងៃនេះលោកស្រី ស៊ីលវៀ ខាតវ៉ាយច៍ បានមានវត្តមានវិញ ហើយគាត់បានចូលរួមនៅក្នុងកិច្ចដំណើរការសវនាការ។

ក្រឡាបញ្ជីសវនាការតើសាក្សី TCW-766 មានវត្តមានដែរឬទេនៅព្រឹកនេះ? លោក ផារី!

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សាក្សី TCW-766 ដែលអង្គជំនុំជម្រះបានកោះហៅមានវត្តមាននៅក្នុងនៅក្នុងបន្ទប់រង់ចាំ ដោយរង់ចាំការកោះហៅពីអង្គជំនុំជម្រះដើម្បីចូលសាលសវនាការ។ សាក្សីរូបនេះបានធ្វើសម្បថរួចហើយ សាក្សីក៏បានបញ្ជាក់ផងដែរថា គាត់មិនមានចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទ គឺដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណលោក ផារី។

មន្ត្រីតុលាការ អញ្ជើញសាក្សី TCW-766 ចូលមកកាន់បន្ទប់សវនាការ!

(សាក្សីចូលមកកាន់បន្ទប់សវនាការ)

**លោក ម៉ៃខល ផេសមិន៖**

លោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព ខណៈដែលយើងកំពុងរង់ចាំសាក្សី ខ្ញុំសូមឲ្យមានការបញ្ជាក់បំភ្លឺទៅលើមតិយោបល់ដែលលោកប្រធានបានលើកឡើងកាលពីថ្ងៃព្រហស្បតិ៍។ វាគឺជាការផ្លាស់ប្តូរទឡ្ហីករណ៍គ្នាទៅវិញទៅមក ពាក់ព័ន្ធទៅហ្នឹងសេចក្តីប្រកាសដែលធ្វើឡើងដោយនាយករដ្ឋមន្ត្រី ហ៊ុន សែន កាលពីពីរសប្តាហ៍មុន ដែលគាត់លើកឡើងអំពីកូនក្តីរបស់ខ្ញុំ។ ដូចដែលលោកប្រធាន

បានជ្រាបហើយ គាត់ហៅកូនក្តីរបស់ខ្ញុំថាជាឃាតកនៃអំពើប្រល័យពូជសាសន៍។ ដូច្នេះហើយខ្ញុំសូមឱ្យតុលាការថ្កោលទោសលោកនាយករដ្ឋមន្ត្រី ហើយបង្គាប់ទៅដល់លោកនាយករដ្ឋមន្ត្រីកុំឱ្យនិយាយដូច្នេះទៀតនៅពេលអនាគត។

ខ្ញុំបានលើកបញ្ហានេះកាលពីសប្តាហ៍មុនរួចមកហើយ ម្តងទៀត ហើយខ្ញុំបានសួរថា តើនៅពេលដែលលោកប្រធាន និងលោក លោកស្រី នឹងចេញសេចក្តីសម្រេចទៅលើសំណើរបស់ខ្ញុំ។ លោកប្រធានបានលើកឡើងថាយើងនឹងមិនធ្វើមតិយោបល់ទៅលើសំណើរបស់លោកនោះទេនៅក្នុងប្រតិចារឹក ហើយលោកបានរំឭកខ្ញុំថា កុំឱ្យខ្ញុំលើកបញ្ហានេះសាជាថ្មី។

ដូច្នេះខ្ញុំសូមឱ្យតុលាការបញ្ជាក់បំភ្លឺទៅលើចំណុចហ្នឹង អ្វីដែលលោកប្រធានប្រកាសថ្ងៃមុននេះគឺជាសេចក្តីសម្រេចឬក៏យ៉ាងម៉េច ឬក៏លោកប្រធានជម្រាបខ្ញុំថា ឱ្យខ្ញុំទ្រាំបន្តិចទៅ សេចក្តីសម្រេចនឹងចេញនាពេលឆាប់ៗ។ ដូច្នេះហើយ ខ្ញុំសូមសួរសាជាថ្មី ថាតើលោកប្រធាននឹងចេញសេចក្តីសម្រេចទៅលើសំណើរបស់ខ្ញុំនេះនៅពេលណាដែរ? សូមបញ្ជាក់។ សូមអរគុណ។

[០៩:០៦:០៨]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:០៧:២១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រមបន្ថែមនូវ តបទៅនឹងកំណត់សម្គាល់របស់មេធាវីការពារក្តី នួន ជា ដែលបានលើកឡើងបញ្ហានេះនៅពេលនេះបីលើកហើយ ទោះបីអង្គជំនុំជម្រះបានជម្រាបទៅគាត់រួចហើយកាលពីថ្ងៃព្រហស្បតិ៍ក៏ដោយ ឥឡូវនេះគាត់លើកសាជាថ្មីម្តងទៀត។ ឥឡូវនេះដើម្បីឱ្យបានច្បាស់លាស់ លោកស្រីចៅក្រមដែលប្រើភាសាអង់គ្លេសសូមជម្រាបគាត់ឱ្យបានច្បាស់លាស់ពីបញ្ហានេះ។

សូមអញ្ជើញ!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន ខ្ញុំមិនមានវត្តមាននៅពេលដែលលោកបានលើកបញ្ហានេះលើកទីពីរ និងលើកទីបីនោះ ដូច្នេះសូមឱ្យលោកក្រោកឈរឡើងនៅពេលដែលខ្ញុំនិយាយជាមួយនឹងលោក។

សូមអរគុណ។

ខ្ញុំមិនមានវត្តមាន នៅពេលដែលលោកបានលើកបញ្ហានេះមកកាន់អង្គជំនុំជម្រះ។ ខ្ញុំបានទទួល

ដំណឹងថា លោកប្រធានបានបញ្ជាក់ច្បាស់រួចមកហើយ ថាអង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ទៅលើបញ្ហាហ្នឹងរួចមកហើយ។ ហើយអង្គជំនុំជម្រះស្នើសុំកុំឲ្យលោកលើកបញ្ហាហ្នឹងសាជាថ្មី។ ដូច្នេះសូមឲ្យលោកកុំធ្វើដូច្នេះតទៅទៀត។ អង្គជំនុំជម្រះនឹងចេញសេចក្តីសម្រេចនៅក្នុងពេលសមស្របនាពេលឆាប់ៗ។

វាពុំចាំបាច់ដែលឲ្យមេធាវីការពារក្តី ដែលមានវិជ្ជាជីវៈនិងបទពិសោធន៍នោះ លើកឡើងសាជាថ្មីនោះទេ នៅពេលដែលអង្គជំនុំជម្រះ ក្រុមប្រឹក្សាជំនុំជម្រះបានបញ្ជាក់យ៉ាងច្បាស់រួចមកហើយ។ សូមអរគុណ។

[០៩:០៩:០២]

**ការតាំងសំណួរដោយចៅក្រម**

**ប្រធានអង្គជំនុំ៖**

អរុណសួស្តីសាក្សី។

**ស៖** តើលោកឈ្មោះអ្វីទៅ?

**លោក វ៉ាន់ថាន់ ដារ៉ាពៅ៖**

**ឆ៖** ខ្ញុំបាទឈ្មោះ វ៉ាន់ថាន់ ដារ៉ាពៅ។

**ស៖** ក្រៅពីឈ្មោះ វ៉ាន់ថាន់ ដារ៉ាពៅ តើលោកមានធ្លាប់ប្រើប្រាស់ឈ្មោះអ្វីផ្សេងដែរទៀតដែរឬទេ? ហើយបើមានតើប្រើឈ្មោះអ្វីដែរ?

**ឆ៖** អត់មានទេលោកប្រធានចៅក្រម។

**ស៖** តើលោកមានអាយុប៉ុន្មានឆ្នាំហើយ?

**ឆ៖** ខ្ញុំមានអាយុ ៤០ឆ្នាំ។

**ស៖** លោកមានទីលំនៅនៅឯណាដែរសព្វថ្ងៃនេះ?

**ឆ៖** ខ្ញុំបាទរស់នៅក្នុងទីក្រុងភ្នំពេញ។

**ស៖** លោកប្រកបមុខរបររកស៊ីធ្វើអ្វីដែរ?

**ឆ៖** ខ្ញុំបាទធ្វើការងារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា។

**ស៖** ហើយលោកធ្វើការនៅទីនោះ នៅមជ្ឈមណ្ឌលឯកសារកម្ពុជាហ្នឹងមានឋានៈអ្វីដែរ នៅទីនោះ?

**ឆ៖** ខ្ញុំបាទធ្វើជានាយករងនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលទទួលបន្ទុកផ្នែកការងារទូទៅ និងការងារឯកសារនេះតែម្តង។ ហើយខ្ញុំបាទធ្វើការងារនេះរយៈពេល១៧ឆ្នាំហើយ។

**ស៖** បាទ អរគុណ។ តើលោកនៅលីវ ឬក៏លោកមានប្រពន្ធហើយ?

**ឆ៖** ខ្ញុំបាទមានគ្រួសារហើយ។

**ស៖** លោកមានកូនប៉ុន្មាននាក់?

**ឆ៖** មានកូនពីរនាក់។

**ស៖** លោក វ៉ាន់ថាន់ ដារ៉ាពៅ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះ ទីមួយថា លោកបានស្បថរួចហើយមុននឹងចូលមកកាន់បន្ទប់សវនាការនេះ តើពិតមែនដែរឬទេ?

**ឆ៖** ត្រឹមត្រូវបាទ។

[០៩:១១:១៩]

**ស៖** ហើយតាមរបាយការណ៍របស់ក្រឡាបញ្ជីថា តាមសមត្ថភាពដែលលោកអាចដឹង គឺថា លោកមិនមានបុព្វញាតិ ញាតិលោហិត ឬក៏ញាតិពន្ធ ជាបងប្អូន បងប្អូនថ្លៃ ប្រពន្ធ ឬក៏ឪពុកម្តាយ ត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងក្តីនេះទេ។ តើពិតមែនដែរឬទេ?

**ឆ៖** បាទ ពិតជាត្រឹមត្រូវ។

**ស៖** ក្នុងនាមលោកជាសាក្សីដែលត្រូវផ្តល់សក្ខីកម្ម នៅក្នុងកិច្ចដំណើរការសវនាការនៅចំពោះអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះ លោកអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬក៏ធ្វើអំណះអំណាងណាមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនលោក សិទ្ធិមិនធ្វើសក្ខីកម្មលើខ្លួនឯង។ មានន័យថា ដោយសារតែចម្លើយ ឬអំណះអំណាងនោះនាំឲ្យលោកនឹងត្រូវទទួលរងនូវការចោទប្រកាន់ផ្សេងៗ លោកយល់ដែរទេ?

[០៩:១២:២១]

**ឆ៖** បាទ ខ្ញុំបានយល់ច្បាស់លាស់។

**ស៖** លោកអាចរៀបរាប់ប្រាប់ដល់អង្គសវនាការ ដោយសង្ខេបអំពីប្រវត្តិការងាររបស់លោក មុនពេលចូលមកបំពេញការងារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាដែរឬទេ? បានដែរទេ?

**ឆ៖** ជាដំបូង ខ្ញុំបានសិក្សារៀនសូត្រនៅសាលាច្បាប់នៅក្នុងឆ្នាំ១៩៩៣ ដល់ឆ្នាំ៩៥ ខ្ញុំបានចូលមកធ្វើការងារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ជាអ្នកស្ម័គ្រចិត្ត។ បន្ទាប់មក ខ្ញុំបានធ្វើការងារនេះនៅ

មជ្ឈមណ្ឌលឯកសារកម្ពុជា បន្ទាប់ពីបានទទួលនូវការបណ្ដុះបណ្ដាលមានបទពិសោធន៍នៅក្នុងការងារ ខ្ញុំបានក្លាយទៅជាបុគ្គលិកពេញសិទ្ធិនៅក្នុងឆ្នាំ១៩៩៧។ តាំងពីពេលនោះមក ខ្ញុំធ្វើការងារនៅមជ្ឈមណ្ឌលឯកសារកម្ពុជារហូតៗមកដល់ពេលនេះ។

[០៩:១៣:៥៨]

**ប្រធានអង្គជំនុំ៖**

តើអស់លោក លោកស្រីចៅក្រមមានសំណួរអ្វីសួរដល់សាក្សីរូបនេះដែរឬទេ? បើមានសូមអញ្ជើញ! សូមអញ្ជើញលោកចៅក្រម យ៉ា សុខន!

**សួរដោយចៅក្រម យ៉ា សុខន៖**

សួស្ដី លោក វ៉ាន់ថាន់ ពៅដារ៉ា។

**ស៖** នៅហ្នឹងមជ្ឈមណ្ឌលឯកសារកម្ពុជា តើលោកគ្រប់គ្រងបុគ្គលិកប៉ុន្មាននាក់ដែរនៅទីនោះ?

**លោក វ៉ាន់ថាន់ ដារ៉ាពៅ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម ខ្ញុំ ចំនួនបុគ្គលិកនេះមានការផ្លាស់ប្ដូរពីឆ្នាំ១៩៩៥ រហូតដល់ឆ្នាំ២០១២។ ហើយក្នុងការគ្រប់គ្រងបុគ្គលិកគឺមានពីឆ្នាំ១៩៩៥ ដល់ ឆ្នាំ២០១២ នេះគឺ ចំនួនបុគ្គលអាចពី១៥ ទៅ៥៥នាក់។

[០៩:១៥:០០]

**ស៖** តើបុគ្គលិកក្រោមការគ្រប់គ្រងរបស់លោកមានតួនាទីអ្វីខ្លះដែរ?

**ឆ៖** បុគ្គលិកនៅក្រោមបង្គាប់-- នៅក្រោមការគ្រប់គ្រងរបស់ខ្ញុំបាទ មានតាំងពីសន្តិសុខ មានតាំងពីបុគ្គលិកធម្មតា និងប្រធានក្រុមការងារ។

**ស៖** តើលោកមានសិទ្ធិក្នុងកម្រិតណាលើការងារប្រចាំថ្ងៃលើបុគ្គលិករបស់លោក?

**ឆ៖** ក្នុងការប្រចាំថ្ងៃ ខ្ញុំបាទសម្រេចបានគ្រប់យ៉ាងតាំងពីការងាររដ្ឋបាល តាំងពីការងារសន្តិសុខ តាំងពីការងារឯកសារ និងការងារផ្សេងៗទៀត។

**ស៖** តើតួនាទីរបស់លោក តម្រូវឲ្យលោកធ្វើការជាមួយឯកសារនីមួយៗ ដែលបានរក្សាទុកដោយមជ្ឈមណ្ឌលឯកសារកម្ពុជាដែរឬទេ?

**ឆ៖** បាទ ជាការត្រឹមត្រូវ ព្រោះខ្ញុំជាអ្នកទទួលបន្ទុកលើការងារនេះផ្ទាល់តែម្ដង។

**ស៖** តើលោកទទួលខុសត្រូវអ្វីខ្លះពាក់ព័ន្ធនឹងឯកសារ ដែលរក្សាទុកដោយមជ្ឈមណ្ឌលឯកសារ

កម្ពុជា?

**ឆ៖** ជាការទទួលខុសត្រូវនោះគឺ យើងធ្វើការប្រមូលឯកសារ ធ្វើការចងក្រងឯកសារ ធ្វើការទុកដាក់ឯកសារឲ្យបានត្រឹមត្រូវ ឲ្យមានសុវត្ថិភាព និងធ្វើការចងក្រងរបៀបជាកាតាឡុកឯកសារនោះឲ្យបានច្បាស់លាស់ ដើម្បីបម្រើដល់ការសិក្សាស្រាវជ្រាវ បម្រើដល់ការងារផ្សេងៗទៀត ដែលទាំងសាធារណជន និងទាំងអ្នកសិក្សាស្រាវជ្រាវទាំងក្នុងទាំងក្រៅប្រទេស អាចធ្វើការសិក្សាស្រាវជ្រាវលើឯកសារទាំងនោះបាន នៅមជ្ឈមណ្ឌលឯកសារកម្ពុជា។

[០៩:១៧:៣០]

**ស៖** តើលោកបានដឹងក្នុងកម្រិតណាអំពីឯកសារថ្មី ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបាន?

**ឆ៖** រាល់ឯកសារទាំងអស់ដែលចូលមកដល់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺខ្ញុំបាទជាអ្នកទទួលនៅក្នុងការរៀបចំ ការចាត់ចែងឯកសារទាំងអស់នោះ។

**ស៖** តើមជ្ឈមណ្ឌលឯកសារកម្ពុជានោះ ជាអ្វី?

**ឆ៖** មជ្ឈមណ្ឌលឯកសារ គឺជាអង្គការក្រៅរដ្ឋាភិបាល ជាអង្គការស្រាវជ្រាវឯករាជ្យ ជាអង្គការដែលមិនរកប្រាក់កម្រៃ និងមានបេសកកម្មច្បាស់លាស់។ គឺទីមួយ គឺយើងប្រមែប្រមូល និងចងក្រងឯកសារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងទីពីរគឺយើងផ្តល់ឯកសារដល់អ្នកទាំងឡាយណាដែលចង់ស្វែងរកយុត្តិធម៌ដល់អ្នកដែលរស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ តាមរយៈការផ្តល់ឯកសារនេះតែម្តង។

[០៩:១៨:៤៤]

**ស៖** លោកដឹងទេ តើមជ្ឈមណ្ឌលនេះបង្កើតឡើងតាំងពីណាពេលណាមក?

**ឆ៖** បាទលោកចៅក្រម មជ្ឈមណ្ឌលឯកសារកម្ពុជាបានចាប់កកើតនៅក្នុងឆ្នាំ១៩៩៥។

**ស៖** តើអ្នកណាជាអ្នកបង្កើតមជ្ឈមណ្ឌលនេះ?

**ឆ៖** ប្រវត្តិនៃការកកើតមជ្ឈមណ្ឌលកម្ពុជា ប្រហែលវែងបន្តិច ប៉ុន្តែខ្ញុំនឹងព្យាយាមនិយាយដោយសង្ខេប។ គឺដំបូងឡើយ គឺមជ្ឈមណ្ឌលឯកសារត្រូវបានបង្កើតឡើងជាការិយាល័យស្រាវជ្រាវមួយរបស់គម្រោងសិក្សាស្រាវជ្រាវនៃសាកលវិទ្យាល័យយ៉េល។ រហូតដល់ឆ្នាំ១៩៩៧ ការស្រាវជ្រាវត្រូវបាន-- គម្រោងនៃការស្រាវជ្រាវរបស់សាកលវិទ្យាល័យយ៉េលត្រូវបានបញ្ចប់ ហើយមជ្ឈមណ្ឌលឯកសារ បានបន្តការងាររបស់ខ្លួនដោយឯករាជ្យពីការងារ ពីគម្រោងរបស់សាកលវិទ្យាល័យយ៉េល

ហើយបានក្លាយទៅជាអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជារហូតទល់មកដល់សព្វថ្ងៃ។

[០៩:២០:០០]

**ស៖** តើមជ្ឈមណ្ឌលនេះទទួលហិរញ្ញវត្ថុតាមមធ្យោបាយណាដែរ?

**ឆ៖** ការទទួលបានហិរញ្ញវត្ថុសម្រាប់ទ្រទ្រង់ការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺបានមកពីប្រភពជាច្រើនផ្សេងៗគ្នា មានទាំងរដ្ឋាភិបាល មានទាំងអង្គការឯកជន មានទាំងស្ថាប័នសាលារៀន-- ជាសាលាជាសាកលវិទ្យាល័យ ជាអង្គការមិនមែនរកប្រាក់ចំណេញផ្សេងៗទៀតជាច្រើន។

**ស៖** តើសាកលវិទ្យាល័យយ៉េលមានតួនាទីអ្វីនៅមជ្ឈមណ្ឌលឯកសារកម្ពុជានាពេលបច្ចុប្បន្ន?

**ឆ៖** បាទសាកលវិទ្យាល័យយ៉េល ជាសាកវិទ្យាល័យ ជាអង្គការដៃគូមួយដែលមានទំនាក់ទំនងជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា ដូចដែលបានធ្វើការងារពីមុនកន្លងមកតាំងពីឆ្នាំ១៩៩៥។ បាទជាដៃគូ។

[០៩:២១:៣៣]

**ស៖** តើមជ្ឈមណ្ឌលឯកសារកម្ពុជា និងរដ្ឋាភិបាលមានទំនាក់ទំនងដូចម្ដេច?

**ឆ៖** មជ្ឈមណ្ឌលឯកសារកម្ពុជាមិន-- ជាអង្គការក្រៅរដ្ឋាភិបាល ប៉ុន្តែរាល់ការងារទាំងអស់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា មានការជួយជ្រោមជ្រែងពីការងារ ពីរាជរដ្ឋាភិបាល។ ជាក់ស្ដែងដូចជាការអនុញ្ញាតឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា មានសិទ្ធិចុះទៅស្រាវជ្រាវឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យនៅទូទាំងប្រទេស។ គាំទ្រផ្នែកសុវត្ថិភាពនៅពេលដែលការចុះស្រាវជ្រាវតាមបណ្ដាខេត្ត ដែលកាលជំនាន់នោះ ក្នុងចន្លោះឆ្នាំ៩៥ រហូតដល់ឆ្នាំ៩៨ គឺកងកម្លាំងប្រដាប់អាវុធខ្មែរក្រហមនៅមាននៅតាមតំបន់ដាច់ស្រយាលនៅឡើយ។ អ៊ីចឹង រដ្ឋាភិបាលបានផ្ដល់ជាការគាំពារផ្នែកសន្តិសុខនៅពេលដែលយើងចុះធ្វើការងារតាមខេត្ត។

[០៩:២២:៤៧]

**ស៖** តើលោកអាចពន្យល់អំពីគោលបំណងពិតប្រាកដនៃមជ្ឈមណ្ឌលឯកសារកម្ពុជានេះបានទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម ការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដូចខ្ញុំបានជម្រាបពីខាងដើម គឺថាបេសកកម្មសំខាន់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺយើងចងក្រង ប្រមែប្រមូលចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យ នៅក្នុងគោលបំណងដើម្បីបម្រើដល់ការចងចាំអំពីអ្វីដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា គឺការចងក្រងលក្ខណៈជាប្រវត្តិសាស្ត្រតែម្ដង។ នៅក្នុង

បេសកកម្មទីពីរ ដែលសំខាន់ គឺយើងមជ្ឈមណ្ឌលឯកសារកម្ពុជាចងក្រងឯកសារនេះ គឺសម្រាប់បម្រើដល់សាធារណជនទាំងឡាយដែលមានបំណងចង់ស្វែងរកយុត្តិធម៌ សម្រាប់ជនរស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ តាមរយៈការផ្តល់ឯកសារនេះតែម្តង។

**ស៖** តើមជ្ឈមណ្ឌលឯកសារកម្ពុជាមានរចនាសម្ព័ន្ធដូចម្តេចដែរ?

**ឆ៖** មជ្ឈមណ្ឌលឯកសារកម្ពុជាមានអង្គការលេខ រចនាសម្ព័ន្ធគ្រប់គ្រងនេះគឺច្បាស់លាស់ គឺមាន គណៈគ្រប់គ្រងមជ្ឈមណ្ឌល មាននាយកម្នាក់ មាន-- បន្ទាប់មកគឺមាននាយករង ដែលបច្ចុប្បន្ននេះមាននាយករងពីរនាក់ មានក្រុមគ្រប់គ្រងហិរញ្ញវត្ថុដែលឯករាជ្យពីនាយក ពីនាយករង។ ហើយបន្ទាប់មកគឺយើងមានប្រធានក្រុម ដែលប្រធានក្រុមនីមួយៗទទួលខុសត្រូវតាមគម្រោងជាក់លាក់មួយៗច្បាស់លាស់ បន្ទាប់មកគឺមានសមាជិកក្រុមដែលនៅក្នុងគម្រោងនីមួយៗ។

[០៩:២៥:០០]

**ស៖** តើនាយកមជ្ឈមណ្ឌលឯកសារកម្ពុជាហ្នឹង គាត់ឈ្មោះអីដែរ?

**ឆ៖** លោកនាយកមជ្ឈមណ្ឌលឯកសារកម្ពុជា មានឈ្មោះ យុ ឆាំង។ លោកនាយកបានធ្វើជានាយកនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ចាប់ពីឆ្នាំ១៩៩៧។

**ស៖** តើមជ្ឈមណ្ឌលនេះមានទីប្រឹក្សាដែរឬទេ?

**ឆ៖** មជ្ឈមណ្ឌលមានទីប្រឹក្សាទាំងខាងក្នុងទាំងខាងក្រៅ។ មានទីប្រឹក្សាខាងក្រៅចង់សំដៅទៅលើទីប្រឹក្សាជាជនបរទេស ហើយនិងខាងក្នុងមានសំដៅទៅលើទីប្រឹក្សាដែលជាជនជាតិខ្មែរ។

**ស៖** តើទីប្រឹក្សាជាជនជាតិខ្មែរមានប៉ុន្មាននាក់? ហើយទីប្រឹក្សាជាជនជាតិបរទេសមានប៉ុន្មាននាក់ដែរ?

**ឆ៖** បាទលោកចៅក្រម ចំពោះចំនួនវាមានការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ ហើយទីប្រឹក្សាគឺមានការជ្រើសរើសទៅតាមពេលវេលា ទៅតាមសមត្ថកិច្ច ទៅតាមជំនាញមួយៗដែលទាក់ទងទៅនឹងការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

[០៩:២៦:៤៩]

**ស៖** តើមជ្ឈមណ្ឌលឯកសារកម្ពុជា ទទួលតែព័ត៌មានដែលបានប្រមែប្រមូលដោយមនុស្សដទៃ ឬមួយមជ្ឈមណ្ឌលជាអ្នកស្រាវជ្រាវរកព័ត៌មានណាមួយដោយខ្លួនឯងដែរ?

**ឆ៖** ចំពោះការប្រមែប្រមូលឯកសារ មជ្ឈមណ្ឌលឯកសារកម្ពុជា មានយុត្តិសាស្ត្ររបស់ខ្លួនគឺ

ទីមួយ មជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា ដើម្បីឲ្យខ្លួនអាចចុះធ្វើការស្រាវជ្រាវបានគ្រប់ទីកន្លែង គ្រប់ច្រកល្ហក គ្រប់ស្ថាប័នទាំងអស់ ទាំងនៅក្នុងទាំងនៅក្រៅប្រទេស។ មជ្ឈមណ្ឌលឯកសារកម្ពុជា ក៏បានធ្វើការអំពាវនាវដល់ស្ថាប័នដទៃទៀត ដល់ប្រទេសដទៃទៀត ដែលមានឯកសារពាក់ព័ន្ធទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យ ឲ្យផ្តល់ឯកសារនេះមកមជ្ឈមណ្ឌលឯកសារកម្ពុជា ឬក៏ទៅផ្តល់មកកន្លែងណាមួយដែលខ្លួនយល់ថា អាចនឹងទុកដាក់ អាចនឹងមានប្រយោជន៍ក្នុងការប្រើប្រាស់ ជាពិសេសគឺមកដល់អង្គជំនុំជម្រះវិសាមញ្ញ នៅពេលដែលអង្គជំនុំជម្រះវិសាមញ្ញបានបង្កើតឡើង។

[០៩:២៨:១១]

នៅក្នុងការទៅប្រមែប្រមូលឯកសារ មជ្ឈមណ្ឌលឯកសារកម្ពុជាបានទៅប្រមែប្រមូលផ្ទាល់ បានទទួលពីការផ្តល់មកមជ្ឈមណ្ឌលឯកសារកម្ពុជាផ្ទាល់។ មួយទៀត គឺមជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រើប្រាស់ទស្សនាវដ្តីរបស់ខ្លួនដែលមានឈ្មោះថា “ទស្សនាវដ្តីស្វែងរកការពិត” ដែលទស្សនាវដ្តីនេះបានចែកចាយ ចែកផ្សាយទូលំទូលាយ នៅទូទាំងប្រទេស ដែលធ្វើឲ្យប្រជាពលរដ្ឋទាំងអស់ បានយល់ដឹងអំពីការដែលមានមជ្ឈមណ្ឌលឯកសារកម្ពុជា ជាកន្លែងដែលប្រមូលឯកសារ ជាកន្លែងដែលចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យ។ តាមរយៈការផ្សព្វផ្សាយនេះមានជាបុគ្គល មានបានផ្តល់ឯកសារនេះជូនមកដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីចងក្រង និងទុកដាក់សម្រាប់បម្រើដល់ការសិក្សាស្រាវជ្រាវ ក៏ដូចជាសម្រាប់ផ្តល់ដល់ស្ថាប័នណាដែលគិតថា ឯកសារនេះអាចត្រូវយកទៅប្រើប្រាស់បានតាមការគួរ។

[០៩:២៩:៣១]

**ឆ៖** តើព័ត៌មានប្រភេទណាខ្លះដែលមជ្ឈមណ្ឌលឯកសារកម្ពុជាប្រមែប្រមូលទុកក្នុងបណ្ណសាររបស់ខ្លួន?

**ឆ៖** ចំពោះព័ត៌មាន ខ្ញុំបាទសូមបញ្ជាក់ត្រង់បញ្ហានេះបន្តិច គឺយើងបានប្រើប្រាស់-- យើងបានប្រើពាក្យថា “ព័ត៌មាន ឬឯកសារ” សម្រាប់ឯកសារទាំងឡាយដែលមាននៅមជ្ឈមណ្ឌលឯកសារកម្ពុជា។

ទាក់ទងទៅនឹងប្រភេទនៃព័ត៌មានឯកសារ មានព័ត៌មានជាច្រើនដែលមានផ្ទុកនៅក្នុងឯកសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលព័ត៌មាននេះ វាទាក់ទងទៅនឹង-- ជាពិសេសហ្នឹង គឺរបបកម្ពុជាប្រជាធិបតេយ្យតែម្តង។

**ស៖** តើព័ត៌មានហ្នឹង វាជាឯកសាររឿងរ៉ាវរបស់ជនរងគ្រោះ ឬអ្នករួចពីស្លាប់ ខ្សែអាត់សំឡេង ឬវីដេអូ អ៊ីចឹងមែនទេ?

**ឆ៖** ចំពោះពាក្យថា "ឯកសារ" សម្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា យើងបានបែងចែកជាប្រាំប្រភេទ។ ឯកសារទីមួយ គឺទាក់ទងទៅនឹងឯកសារជាប្រភេទក្រដាស ជាសន្លឹកក្រដាស យើងមួយទំព័រ ពីរទំព័រនេះ ដែលឯកសារប្រភេទនេះ យើងមានរហូតដល់ទៅជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាៗបទសម្ភាស ដែលមជ្ឈមណ្ឌលឯកសាកម្ពុជា បានចុះទៅធ្វើការសម្ភាសនៅតាមខេត្ត តាមក្រុង ទូទាំងប្រទេស។ ឯកសារប្រភេទទីបី គឺទាក់ទងទៅនឹងរូបថត ដែលរូបថតទាំងអស់នេះ ត្រូវបានទុកដាក់ដោយប្រយ័ត្នប្រយែងនៅមជ្ឈមណ្ឌលឯកសារកម្ពុជា។ ប្រភេទទីបួននៃឯកសារ គឺទាក់ទងទៅនឹងការស្រាវ-- ទាក់ទងទៅនឹងផែនការធ្វើផែនទីរណ្ដៅសាកសពរួម ដែលឯកសារនេះយើងនៅមជ្ឈមណ្ឌលឯកសារកម្ពុជាបានហៅថាជា "ភស្តុតាងជាក់ស្ដែង ដែលជារណ្ដៅសាកសពដែលជាមន្ទីរសន្តិសុខរបស់ខ្មែរក្រហម ដែលជាកន្លែងបូជនីយដ្ឋាន។ និងឯកសារប្រភេទចុងក្រោយ គឺទាក់ទងទៅនឹងខ្សែភាពយន្តឯកសារ ដែលខ្សែភាពយន្តទាំងអស់នេះ ត្រូវបានផ្ដល់ដោយអ្នកដែលផលិតឯកសារហ្នឹងផ្ទាល់ សម្រាប់ការប្រើប្រាស់ស្រាវជ្រាវ និងការសិក្សារៀនសូត្រ។

[០៩:៣២:៤២]

**ស៖** តើបុគ្គលិកនិងទីប្រឹក្សាបានទទួលការអប់រំ ក្នុងការស្វែងរកភស្តុតាងសម្រាប់គោលបំណងនៃការជំនុំជម្រះឧក្រិដ្ឋកម្មដែរឬទេ?

**ឆ៖** ចំពោះទីប្រឹក្សា គឺទីប្រឹក្សា គឺជាអ្នកជំនាញដែលយើងត្រូវការជាជំនាញនៅក្នុងការថែរក្សា នៅក្នុងការប្រមែប្រមូលឯកសារ នៅក្នុងការសួរជាយោបល់ផ្សេងៗ។ ចំពោះបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា រាល់ការប្រមែប្រមូលឯកសារ រាល់ការចងក្រងឯកសារ បុគ្គលិកទទួលបាននូវការបណ្ដុះបណ្ដាលមួយយ៉ាងច្បាស់លាស់ គឺជាក់ស្ដែង ខ្ញុំរូបខ្ញុំផ្ទាល់ បានទទួលការបណ្ដុះបណ្ដាលនៅក្នុងការរៀបចំចងក្រងឯកសារនេះ នៅសាលវិទ្យាល័យញូសៅវែល នៅប្រទេសអូស្ត្រាលី។

ក្រៅពីនោះ គឺមានអ្នកជំនាញពីសាលវិទ្យាល័យញូសៅវែល និងសាលវិទ្យាល័យយែល បានមកបណ្ដុះបណ្ដាលផ្ទាល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជាទៀត។

[០៩:៣៤:០២]

**ស៖** តើបុគ្គលិកចំនួនប៉ុន្មាននាក់ ធ្វើការពាក់ព័ន្ធនឹងការប្រមែប្រមូលព័ត៌មានទាំងនេះ?

**ឆ៖** នៅមជ្ឈមណ្ឌលឯកសារកម្ពុជា គឺបុគ្គលិកស្ទើរទាំងអស់ដែលបានធ្វើការងារប្រមែប្រមូល និងចងក្រងឯកសារនៅមជ្ឈមណ្ឌលកម្ពុជា លើកលែងតែបុគ្គលិកផ្នែកសន្តិសុខ។

**ស៖** តើលោកអាចរៀបរាប់ប្រាប់ អង្គជំនុំជម្រះសាលាដំបូងបានដែរឬទេ អំពីប្រភពនៃឯកសារនានា ដែលមជ្ឈមណ្ឌលកម្ពុជាទទួលបាន?

**ឆ៖** ខ្ញុំបាទយល់ថាជាសំណួរវៀងទូលំទូលាយបន្តិចអំពីប្រភពនៃឯកសារ។ ប្រសិនបើមានការបង្ហាញជាឯកសារជាក់លាក់ណាមួយ នោះយើងនឹងអាចប្រាប់យ៉ាងច្បាស់លាស់អំពីថាតើប្រភពឯកសារនោះបានមកពីណា។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ខ្ញុំសូមព្យាយាមបញ្ជាក់អំពីប្រភពនៃឯកសារនេះ គឺយើងបានឯកសារនេះបានមកពីប្រភពជាច្រើនមានទាំងស្ថាប័នរដ្ឋ។ មានន័យថា រដ្ឋាភិបាលកម្ពុជាមានទាំងស្ថាប័នឯកជនជាបុគ្គល និងជាស្ថាប័ន។

**ស៖** តើមជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបានព័ត៌មានដោយវិធីណា?

**ឆ៖** ចំពោះការទទួលបានព័ត៌មាន ត្រង់សំណួរនេះខ្ញុំមិនលក្ខណៈច្បាស់លាស់ថាតើទទួលបានព័ត៌មាន ព័ត៌មានអ្វី ហើយព័ត៌មានយ៉ាងម៉េច? សូមលោកចៅក្រមមេត្តាជួយបញ្ជាក់ឲ្យច្បាស់ជាងនេះបន្តិច។

[០៩:៣៦:៥០]

**ស៖** នីតិវិធីទម្រង់បែបបទណាមួយសម្រាប់អនុវត្ត។ តើមាននីតិវិធីទម្រង់បែបបទណាមួយសម្រាប់អនុវត្តដែរឬទេក្នុងពេលប្រមូលឯកសារព័ត៌មាន?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម ចំពោះនីតិវិធីនៃការប្រមែប្រមូលឯកសារនេះ គឺមានជាក្បួនខ្នាតត្រឹមត្រូវច្បាស់លាស់ ហើយយើងអនុវត្តតាំងទីដើមដំបូងរហូតដល់ពេលបច្ចុប្បន្ន គឺការដែលប្រមែប្រមូលឯកសារ គឺយើងបានសួរនាំនូវប្រភពនៃឯកសារនេះយ៉ាងច្បាស់លាស់ បន្ទាប់ពីបានឯកសារនេះយើង គឺយើងធ្វើការថតចម្លងឯកសារនេះ ដើម្បីទុកឯកសារជាឯកសារដើមនៅក្នុងទីកន្លែងមួយដែលមានសុវត្ថិភាព ហើយឯកសារថតចម្លងនេះនឹងត្រូវបានចាត់ចែងជាបន្តបន្ទាប់ទៀត គឺយើងបានចុះលេខឯកសារដើម្បីសម្គាល់ឯកសារនីមួយៗ បន្ទាប់មកគឺឯកសារនេះត្រូវបានយកទៅធ្វើជាកាតាឡុកដើម្បីឲ្យដឹងថាតើប្រភេទឯកសារ ជាប្រភេទឯកសារយ៉ាងម៉េច ហើយត្រូវបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យប្រភេទមួយណា។ បន្ទាប់មក ទើបយើងយកឯកសារទាំងអស់នេះ យើងយកឯកសារដែលបានធ្វើការថតចម្លងរួចហើយទៅទុកដាក់នៅក្នុងទូមួយដែលមានតែបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាទេ ដែល

អាចយកឯកសារចេញចូលទុកដាក់បាន សម្រាប់អ្នកដែលសិក្សាស្រាវជ្រាវ ឬក៏អ្នកដែលមកអាន ឯកសារ មិនអនុញ្ញាតឲ្យយកឯកសារនេះចេញទៅខាងក្រៅ ឬក៏ប៉ះពាល់ឯកសារទេ គឺឯកសារថតចម្លង នេះត្រូវបានទុកដាក់សម្រាប់ការស្រាវជ្រាវ នរណា អ្នកណាក៏អាចមកធ្វើការស្រាវជ្រាវបាន។

[០៩:៣៩:០៨]

**ស៖** តើមជ្ឈមណ្ឌលឯកសារកម្ពុជាស្វែងរកសាក្សីផ្តល់ព័ត៌មានដោយវិធីណា?

**ឆ៖** នៅក្នុងការស្វែងរកអ្នកដែលត្រូវចុះទៅធ្វើសម្ភាស ព្រោះមជ្ឈមណ្ឌលឯកសារកម្ពុជាមិន បានប្រើប្រាស់ពាក្យថា "សាក្សី"ទេ។ សូមបញ្ជាក់ត្រង់នេះឲ្យបានច្បាស់លាស់ គឺមជ្ឈមណ្ឌលឯកសារ កម្ពុជានឹងចុះទៅសម្ភាសអ្នកដែលផ្តល់បទសម្ភាស។ ទីមួយគឺមជ្ឈមណ្ឌលឯកសារកម្ពុជាមានឯកសារ នៅក្នុងដៃដែលទាក់ទងទៅប្រវត្តិរូបរបស់អតីតយុទ្ធជនកម្មាភិបាលខ្មែរក្រហម។ មជ្ឈមណ្ឌលឯកសារ កម្ពុជា បានសិក្សាទៅលើឯកសារនេះ បន្ទាប់មកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅតាមខេត្ត ទៅតាម អាសយដ្ឋានដែលមាននៅលើឯកសារនេះតែម្តង។ ទីពីរ មជ្ឈមណ្ឌលឯកសារកម្ពុជា អាចរកអ្នកដែល ផ្តល់បទសម្ភាសឲ្យបានតាមរយៈការប្រាប់ពីអ្នកជិតខាង ដែលពេលយើងចុះទៅសម្ភាស អ្នកដែលផ្តល់ បទសម្ភាស ដូចជា ឧទាហរណ៍ថា យើងទៅភូមិមួយដែលសម្ភាសឈ្មោះ "ក" ឈ្មោះ "ក" បានធ្វើការ ចង្អុលបង្ហាញថា មានឈ្មោះ "ខ", "គ" អីបន្ទាប់ទៀតអីចឹង គឺមជ្ឈមណ្ឌលឯកសារកម្ពុជាបានទៅតាម ការចង្អុលបង្ហាញបែបនេះ។

**ស៖** តើមជ្ឈមណ្ឌលឯកសារមានគាំពារអ្នកផ្តល់សម្ភាសសកម្មដែរឬទេ?

**ឆ៖** ខ្ញុំបាទដូចជាមិនទាន់យល់ច្បាស់លាស់អំពីសំណួរទាក់ទងទៅនឹងគាំពារយ៉ាងម៉េចបាទ? សូមលោកចៅក្រមមេត្តាបញ្ជាក់?

**ស៖** ក្នុងន័យនេះ គឺតុលាការចង់ដឹងថា មជ្ឈមណ្ឌលឯកសារកម្ពុជាទទួលស្គាល់ថា អ្នកផ្តល់ សម្ភាសនេះ ជាអ្នកសម្ភាសសំខាន់។ តើមានកិច្ចការពារយ៉ាងណាដល់សន្តិសុខដល់គាត់ ឬទេមជ្ឈ មណ្ឌលនេះ?

**ឆ៖** ជាទូទៅ គឺយើងបាន-- មជ្ឈមណ្ឌលឯកសារកម្ពុជា នៅពេលដែលចុះទៅធ្វើការងារ សម្ភាសតាមខេត្ត គឺមជ្ឈមណ្ឌលឯកសារកម្ពុជាមានការប្រជុំ មានការពិភាក្សាជាមួយក្រុមច្បាស់លាស់ មានការពិភាក្សាអំពីសន្តិសុខ អំពីវិន័យនៅក្នុងការចុះទៅធ្វើបទសម្ភាស។ ទាក់ទងនឹងការសម្ភាស នីមួយៗ គឺមជ្ឈមណ្ឌលឯកសារកម្ពុជាបានសុំសិទ្ធិពីអ្នកដែលផ្តល់បទសម្ភាស និងបានបញ្ជាក់យ៉ាង

ច្បាស់លាស់ថា ការផ្តល់បទសម្ភាស គឺអ្នកផ្តល់បទសម្ភាសនឹងមានសិទ្ធិរក្សានូវអត្តសញ្ញាណនូវ-- ដើម្បីជាសុវត្ថិភាពដល់ខ្លួន។

[០៩:៤៣:១៤]

**ស៖** តើអ្នកណាជាអ្នកសួរសំណួរទៅអ្នកសម្ភាសនោះ?

**ឆ៖** គឺបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាដែលចុះទៅធ្វើបទសម្ភាសនោះផ្ទាល់តែម្តង។ រូបខ្ញុំបាទផ្ទាល់ក៏បានចុះទៅធ្វើការងារសម្ភាសដូចគ្នាដែរ។

**ស៖** តើអ្នកដែលផ្តល់ព័ត៌មកមជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលប្រយោជន៍ ឬរង្វាន់លើកទឹកចិត្តអ្វីដែរពីមជ្ឈមណ្ឌល?

**ឆ៖** បាទ គឺបានទទួលនូវពាក្យ "អរគុណ" ដ៏គួរសមដែលយើងបានផ្តល់ជូនទៅអ្នកទាំងនោះវិញ។

**ស៖** តើមាននីតិវិធីទម្រង់បែបបទអ្វីសម្រាប់អនុវត្តដែរឬទេ នៅពេលមជ្ឈមណ្ឌលឯកសារកម្ពុជាទទួលយកឯកសារណាមួយ?

**ឆ៖** បាទលោកចៅក្រម គឺមានយ៉ាងច្បាស់លាស់ គឺនៅពេលដែលរាល់ឯកសារដែលបាន-- ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបាន គឺយើងបានធ្វើការសួរបញ្ជាក់យ៉ាងច្បាស់លាស់ ថាតើឯកសារនោះមានប្រភពមកពីណា? ឯកសារទាំងអស់នោះប្រគល់មកមជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីថែរក្សា និងចងក្រងទុក។ ហើយដូចខ្ញុំបាទជម្រាបពីខាងដើម គឺរាល់ឯកសារចូលមកដល់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺយើងនឹងអនុវត្តនូវៗរបៀបនៃការទទួលនូវការចងក្រងឯកសារដូចៗគ្នាទាំងអស់ គឺមកដល់គឺយើងធ្វើការថតចម្លង ជាពិសេសធ្វើការថតចម្លងដំបូង បន្ទាប់មកយើងបានយកឯកសារដើមបើសិនជាឯកសារនោះជាឯកសារដើម យើងបានយកទៅទុកនៅកន្លែងទីសុវត្ថិភាពមួយត្រឹមត្រូវ យើងបានពិនិត្យទៅលើឯកសារហ្នឹង ពិនិត្យទៅលើអក្សរ ទៅលើប្រភេទក្រដាស ទៅលើខ្លឹមសារនៃឯកសារដើម្បីឲ្យយល់ថាតើឯកសារហ្នឹងជាឯកសារប្រភេទអ្វី? ហើយយើងបាន បន្ទាប់មកគឺយើងបានយកទៅធ្វើការចុះលេខ ធ្វើការចងក្រងបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យ។

[០៩:៤៥:៤៦]

**ស៖** តើមជ្ឈមណ្ឌលឯកសារកម្ពុជាទទួលយកតែឯកសារដើម ឬក៏ទទួលយកទាំងឯកសារចម្លង?

**ឆ៖** ទាំងពីរប្រភេទ។

**ស៖** តើមជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើការវាយតម្លៃអំពីយថាភាពនៃឯកសារដែរឬទេ? តើការវាយតម្លៃនោះធ្វើយ៉ាងដូចម្តេចដែរ?

**ឆ៖** ចំពោះការវាយតម្លៃទៅលើយថាភាពនៃឯកសារ គឺមជ្ឈមណ្ឌលឯកសារកម្ពុជាបានសួរនាំ បានពិនិត្យទៅលើឯកសារ បានសួរនាំ បានកត់ត្រានូវប្រភពៗឯកសារនេះយ៉ាងត្រឹមត្រូវ មុននឹងយើងធ្វើការទទួលយកឯកសារទាំងអស់នេះ។ ហើយបើឯកសារទាំងអស់នេះគឺបានយកមកធ្វើការចងក្រងដោយបានប្រាប់នូវប្រភពយ៉ាងច្បាស់លាស់ នូវរាល់ឯកសារនីមួយៗដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលនោះ។

**ស៖** តើមជ្ឈមណ្ឌលឯកសារកម្ពុជាអនុវត្តវិធានការដូចម្តេចខ្លះ ក្នុងការផ្ទៀងផ្ទាត់យថាភាពនៃឯកសារ ដែលពុំមែនជាឯកសារដើម?

**ឆ៖** រាល់ការផ្ទៀង-- រាល់ការទទួលបានឯកសារទាំងអស់ គឺជាពិសេសខ្ញុំបាទផ្ទាល់ គឺអានឯកសារហ្នឹងតែម្តង ដើម្បីឲ្យយល់ថា ឯកសារហ្នឹងវាជាឯកសារប្រភេទយ៉ាងម៉េច។ យើងពិនិត្យមើលទៅលើពាក្យពេចន៍ដែលប្រើប្រាស់នៅលើឯកសារហ្នឹង ថាតើឯកសារហ្នឹងអាចថាជាឯកសារយ៉ាងម៉េច យើងបានពិនិត្យទៅលើប្រភេទនៃក្រដាសហ្នឹងដែរ ថាតើវាឯកសារហ្នឹងវាជាប្រភេទក្រដាសហ្នឹងវាថ្មី ឬវាចាស់ ឬក៏យ៉ាងម៉េច ដើម្បីឲ្យដឹងថាតើឯកសារហ្នឹងជាឯកសារដែលនិយាយអំពីរបបកម្ពុជាប្រជាធិបតេយ្យ ឬជាឯកសារដែលជាឯកសារដែលបន្សល់ទុកដោយរបបកម្ពុជាប្រជាធិបតេយ្យ ឬក៏យ៉ាងណានោះ។

[០៩:៤៨:៥៤]

**ស៖** តើមជ្ឈមណ្ឌលឯកសារកម្ពុជាធ្លាប់បានបដិសេធឯកសារណាមួយដែរឬទេ? ហើយបើបានជាបដិសេធ តើផ្អែកលើមូលហេតុអ្វីបានបដិសេធ?

**ឆ៖** បើតាមដែលខ្ញុំចាំ ហើយនិងបានធ្វើការងារនេះផ្ទាល់ គឺមជ្ឈមណ្ឌលឯកសារកម្ពុជាបានបដិសេធលើឯកសារមួយ ដែលឯកសារនោះភាគច្រើនគឺយល់ថា ជាឯកសាររបស់ខ្មែរក្រហម ប៉ុន្តែតាមពិតឯកសារនោះ គឺជាឯកសារដែលទាក់ទងទៅនឹងការចាប់ជំរិតបរទេសពីរនាក់នៅភ្នំវល្លិ៍ ហើយដែលយើងពិនិត្យទៅលើឯកសារនោះ គឺជាឯកសារដែលថតចម្លង ហើយដែលមិនមាននូវយថាភាពពិតប្រាកដ ហើយភាសាដែលប្រើគឺមានលក្ខណៈខុសគ្នាពីភាសាដែលប្រើប្រាស់នៅក្នុងរបបកម្ពុជាប្រជា-ធិបតេយ្យក្នុងចន្លោះឆ្នាំ៧៥-៧៩។ យើងបានធ្វើការបដិសេធចំពោះឯកសារបែបនេះ។

[០៩:៥០:១៤]

**ស៖** នៅពេលដែលមជ្ឈមណ្ឌលបានស្រាវជ្រាវរកឃើញឯកសារណាមួយ តើមជ្ឈមណ្ឌលចាត់ការ ឬវិភាគឯកសារនោះយ៉ាងដូចម្ដេច?

**ឆ៖** មជ្ឈមណ្ឌលឯកសារកម្ពុជាមិនធ្លាប់ដែលធ្វើការវិភាគទៅលើឯកសារទេ មជ្ឈមណ្ឌលឯកសារកម្ពុជាប្រមែប្រមូលឯកសារចងក្រងទុកដូចដែលឯកសារនោះបានមាន បានផ្ដល់មកមជ្ឈមណ្ឌលឯកសារកម្ពុជាសម្រាប់ការសិក្សាស្រាវជ្រាវរបស់សាធារណជន របស់និស្សិត របស់សិស្ស របស់អ្នកសិក្សាស្រាវជ្រាវផ្សេងៗ។

**ស៖** តើមជ្ឈមណ្ឌលឯកសារកម្ពុជារក្សាទុកឯកសារដើមយ៉ាងដូចម្ដេច?

**ឆ៖** ចំពោះឯកសារដើម គឺមជ្ឈមណ្ឌលឯកសារកម្ពុជាបានរក្សាទុកដោយយកចិត្តទុកដាក់ដោយប្រយ័ត្នប្រយែងជាទីបំផុត គឺយើងមានជាទូសុវត្ថិភាពដែលអាចការពាររហូតដល់ទៅមិនឲ្យ ទោះបីជាមានអគ្គីភ័យគឺមិនអាចនឹងឆេះដល់ឯកសារដើមនេះទេ។ ហើយឯកសារដើមនេះ គឺត្រូវបានថែរក្សាទុកនៅក្នុងបន្ទប់មួយដែលមានៗសុវត្ថិភាពដែលយើងគិតគូរអំពីៗអាកាសធាតុ អំពីភាពសើម ភាពស្ងួតអីយ៉ាងដូចម្ដេច ដែលអាចធ្វើឲ្យឯកសារនេះមានលក្ខណៈគង់វង្ស មានលក្ខណៈរក្សានូវភាពដើមរបស់វាតាមដែលយើងអាចធ្វើទៅបាន។

[០៩:៥២:០៥]

**ស៖** តើមជ្ឈមណ្ឌលឯកសារវាយតម្លៃលើឯកសារថា ជាឯកសារដើមនោះដោយវិធីណា?

**ឆ៖** គឺយើងបានពិនិត្យឯកសារនេះផ្ទាល់តាមរយៈការអាន តាមរយៈការមើលអំពីកាលបរិច្ឆេទតាមរយៈការមើលសភាពនៃឯកសារ តាមរយៈការមើលភាសាដែលប្រើនៅក្នុងឯកសារ ដើម្បីឲ្យដឹងថាឯកសារនេះពិតជាឯកសារដើម ឬក៏ឯកសារថតចម្លង?

**ស៖** តើនៅមជ្ឈមណ្ឌលឯកសារមានសុទ្ធតែឯកសារដើម ឬក៏មានឯកសារចម្លងដែរ? ឯកសារចម្លងនោះមជ្ឈមណ្ឌលបានដឹងថា មានឯកសារដើមតម្កល់នៅទីណាដែរ?

[០៩:៥៣:២៦]

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម ចំពោះឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានទាំងឯកសារដើម មានទាំងឯកសារថតចម្លង។ ហើយឯកសារថតចម្លងនេះមានឯកសារថតចម្លងប្រភេទនេះ អាចថាចាត់ទុកជាឯកសារដើម ឬប្រភពឯកសារដែលវាចម្បងដោយសារថា ឯកសារថតចម្លងនេះ

មិនមានជាឯកសារដើមនៅក្នុងស្រុកខ្មែរទេ។ ប៉ុន្តែឯកសារថតចម្លងនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាអាចដឹងពីប្រភពរបស់វានៅទីណា នៅកន្លែងណា នៅជាមួយអ្នកណា?

**ស៖** តើមជ្ឈមណ្ឌលឯកសារកម្ពុជាចម្លងឯកសារដែរឬទេ? តើមាននីតិវិធីដូចម្ដេច ដើម្បីធានាថាការ ថាឯកសារចម្លងនោះមានភាពស៊ីសង្វាក់និងយថាភាពនៃឯកសារ?

**ឆ៖** នៅមជ្ឈមណ្ឌលឯកសារកម្ពុជា យើងបានធ្វើការថតចម្លងឯកសារ។ ដូចបាន ខ្ញុំបាទបានជម្រាបពីខាងដើមថា យើងមិនអនុញ្ញាតឲ្យសាធារណជន ក៏ដូចជាអ្នកសិក្សាស្រាវជ្រាវធ្វើការប៉ះពាល់ទៅលើឯកសារដើមនោះទេ។ ដូច្នេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានថតចម្លងឯកសារនេះ ដើម្បីដាក់បម្រើដល់សាធារណជន ជូនដល់អ្នកសិក្សាស្រាវជ្រាវឲ្យមកធ្វើ អាចមកធ្វើការសិក្សាស្រាវជ្រាវបានអាចធ្វើការស្នើសុំឯកសារនេះបាន ដោយតាមការចាំបាច់របស់អ្នកសិក្សាស្រាវជ្រាវទាំងអស់នោះ។

[០៩:៥៥:០៩]

អ៊ីចឹងនៅពេលដែលមានការស្នើសុំថតចម្លងបែបនេះ រាល់ការស្នើសុំ ត្រូវបាន ខ្ញុំបាទផ្ទាល់ជាអ្នកធ្វើកិច្ចការនេះ គឺទទួលនូវសំណើ ហើយយើងនិងចាត់សហការីរបស់ខ្ញុំធ្វើការថតចម្លងជូន ហើយបានផ្ដល់ជាលិខិតប្រគល់ និងទទួលយ៉ាងត្រឹមត្រូវ។

**ស៖** តើមជ្ឈមណ្ឌលឯកសារកម្ពុជាធ្លាប់ធ្វើការកែប្រែឯកសារថតចម្លងដែរឬទេ?

**ឆ៖** ឯកសារថតចម្លងយើងបានទុកដាក់នៅក្នុងទូឯកសារ ហើយឯកសារថតចម្លងនេះត្រូវបានថតចម្លងជាច្រើនដងទៅតាមការស្នើសុំរបស់អ្នកសិក្សាស្រាវជ្រាវ អ្នកសាធារណជន។ ត្រង់ចំណុចដែលថាតើអ្នកសិក្សាស្រាវជ្រាវនៅពេលដែលទទួលបានឯកសារថតចម្លងពីមជ្ឈមណ្ឌលកម្ពុជាទៅនោះ គឺយើងមិនដឹងបាន ថាតើអ្នកដែលយកថតចម្លងទៅគាត់យកទៅធ្វើយ៉ាងម៉េចតទៅទៀត។

[០៩:៥៧:០១]

**ស៖** អ្នកណាមានភារកិច្ចកំណត់អត្តសញ្ញាណមនុស្សដែលត្រូវសម្លាស?

**ឆ៖** ចំពោះអត្តសញ្ញាណអ្នកដែលត្រូវមជ្ឈមណ្ឌលឯកសារកម្ពុជានឹងត្រូវសម្ភាសនោះ គឺដូចខ្ញុំបាទ បានជម្រាបពីខាងដើម គឺយើងមានឯកសារប្រវត្តិរូបផ្ទាល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា។ តាមរយៈឯកសារប្រវត្តិរូបនេះ គឺយើងបានចុះទៅផ្ទាល់ដល់ភូមិឋាន ដល់អាសយដ្ឋានដែលដូចបានមានបង្ហាញនៅលើឯកសារប្រវត្តិរូបនេះតែម្ដង។

**ស៖** តើអ្នកដែលត្រូវសម្ភាសបានទទួលរង្វាន់លើកទឹកចិត្ត ឬទទួលប្រយោជន៍អ្វីមួយដែរឬទេ ពីមជ្ឈមណ្ឌល?

[០៩:៥៧:៥៦]

**ឆ៖** ដូចខ្ញុំបានជម្រាបពីខាង គឺមានតែភាព-- មានតែការថ្លែងនូវអំណរគុណដោយវាចារ ដោយគោរពជូនចំពោះអ្នកដែលបានផ្តល់ទាំងឯកសារ អ្នកដែលបានផ្តល់ទាំងបទសម្ភាស។

**ស៖** ក្រៅពីអ្នកធ្វើសម្ភាស និងអ្នកត្រូវសម្ភាស តើមានវត្តមានមនុស្សផ្សេងទៀតទេក្នុងអំឡុងពេលធ្វើសម្ភាសនោះ?

**ឆ៖** នៅពេលធ្វើសម្ភាស គឺមានបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាមានវត្តមាននៅទីនោះ ដោយសារការទៅសម្ភាស យើងទៅជាក្រុម បាទទៅជាក្រុម។ ក្នុងមួយក្រុមមានពីរ ឬទៅបីនាក់។ អ៊ីចឹងនៅពេលសម្ភាស គឺមានអ្នកធ្វើសម្ភាស មានអ្នកកត់ត្រានូវបទសម្ភាស។ ហើយបទសម្ភាសទាំងអស់នេះ ត្រូវបានយើងថតសំឡេងជាខ្សែអាត់ ហើយបទសម្ភាសនេះនៅពេលដែលយកមកដល់មជ្ឈមណ្ឌលឯកសារកម្ពុជា យើងធ្វើការចម្លងបទសម្ភាសនេះចេញមកដាក់នៅក្នុងក្រដាសជាសន្លឹកក្រដាសយើងតែម្តង។

**ស៖** បន្ទាប់ពីបានធ្វើកំណត់ហេតុទាំងនេះរួចហើយ តើត្រូវធ្វើដូចម្តេចទៀតចំពោះកំណត់ហេតុទាំងនេះ?

**ឆ៖** តើលោកចៅក្រម សំដៅថាកំណត់ហេតុជាបទសម្ភាស ឬក៏យ៉ាងដូចម្តេច? បាទសូមមេត្តាបញ្ជាក់។

**ស៖** គឺជាកំណត់ហេតុបទសម្ភាស ដែលលោកបាននិយាយអម្បាញ់មិញថា នៅពេលដែលសម្ភាសថតជាខ្សែអាត់ បន្ទាប់មកលោកមកដល់កន្លែង លោកចម្លងជាកំណត់ហេតុ។ ហើយតើកំណត់ហេតុនោះ លោកចាត់ការដូចម្តេចទៀត?

[១០:០០:០៣]

**ឆ៖** បាទ នៅពេលដែលបទសម្ភាសត្រូវបានយកមកដល់មជ្ឈមណ្ឌលឯកសារកម្ពុជាហើយ គឺយើងមានក្រុមការងាររបស់យើងធ្វើចម្លងដាក់លើក្រដាស ហើយយើងបានព្រីនវាចេញពីម៉ាស៊ីនកុំព្យូទ័រដាក់មកលើក្រដាស ហើយយើងធ្វើការចុះលេខសម្គាល់ និងរៀបចំទុកដាក់ទៅតាមប្រភេទឯកសារ ទៅតាមទូ ហើយយើងបានអនុវត្តនូវការចាត់ចែង និងរៀបចំទុកដាក់ឯកសារទាំងអស់នេះ ដូច

នឹងឯកសារដែលយើងបានទទួលទាំងអស់។

**ស៖** តើមជ្ឈមណ្ឌលឯកសារកម្ពុជាវាយតម្លៃមនុស្សដែលខ្លួនបានសម្ភាសដោយរបៀបណា ដើម្បីទទួលបានភាពជឿជាក់ ឬភាពអាចទុកចិត្តបាន?

[១០:០១:៣១]

**ឆ៖** ទាក់ទងទៅនឹងបទសម្ភាសនីមួយៗ គឺយើងបានធ្វើបទសម្ភាស យើងបានធ្វើជាចម្លងនូវបទសម្ភាសនេះ ហើយយើងមិនបានធ្វើការវិភាគទៅលើបទសម្ភាសទាំងអស់នេះទេ។

**ស៖** តើមជ្ឈមណ្ឌលឯកសារកម្ពុជាមានរក្សាទុកទស្សនាវដ្ដី ឬព្រឹត្តិបត្រណាមួយបន្សល់ពីសម័យកម្ពុជាប្រជាធិបតេយ្យ ឬសម័យមុននេះដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម គឺមជ្ឈមណ្ឌលឯកសារកម្ពុជាមានរក្សាទុកនូវឯកសារប្រភេទនេះ នៅមជ្ឈមណ្ឌលឯកសារកម្ពុជា។

**ស៖** លោកអាចរៀបរាប់បានខ្លះទេ? ទស្សនាវដ្ដីនោះ ឬព្រឹត្តិបត្រ?

**ឆ៖** បាទ មានជាទស្សនាវដ្ដីទង់បដិវត្ត មានទស្សនាវដ្ដីយុវជន យុវនារីបដិវត្ត ហើយឯកសារប្រភេទនេះ គឺជាឯកសារដែល-- ជាឯកសារដើម ដែលមានពណ៌ មានប្រភេទក្រដាសអីហ្នឹងគឺ-- ដែលវាមានភាពចំណាស់ ហើយនៅលើឯកសារគឺមានជាទង់ ហើយទង់នោះមានពណ៌ក្រហម។

**ស៖** តើមជ្ឈមណ្ឌលឯកសារកម្ពុជាមានទស្សនាវដ្ដីទាំងនេះគ្រប់លេខចេញផ្សាយដែរទេ? ទស្សនាវដ្ដីទង់បដិវត្ត។

[១០:០៣:៣២]

**ឆ៖** យើងមជ្ឈមណ្ឌលឯកសារបានខិតខំប្រមែប្រមូលឯកសារតាមលទ្ធភាពដែលអាចធ្វើទៅបាន ហើយឯកសារដែលបានទទួលមកទាំងអស់ គឺយើងរក្សាទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា។ ខ្ញុំអាចបញ្ជាក់បានត្រឹមប៉ុណ្ណេះ។

**ស៖** តើមជ្ឈមណ្ឌលឯកសារកម្ពុជាមានទស្សនាវដ្ដីទាំងនេះ ក្នុងទម្រង់ដើមគ្រប់លេខចេញផ្សាយដែរឬទេ?

**ឆ៖** មជ្ឈមណ្ឌលឯកសារកម្ពុជាមិនបានដឹងថាតើឯកសារទាំងអស់នេះចេញប៉ុន្មានលេខ ចេញចំនួនប៉ុន្មានទេ។ ប៉ុន្តែមជ្ឈមណ្ឌលឯកសារកម្ពុជា ពិតជាមានឯកសារនេះនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ជាពិសេសគឺទាក់ទងទៅនឹងឯកសារទង់បដិវត្ត ឬក៏យុវជន យុវនារីបដិវត្តនេះតែម្ដង។

**ស៖** តើទស្សនាវដ្ដីទង់បដិវត្តនេះ មជ្ឈមណ្ឌលមានដែលធ្វើការថតចម្លងទេ?

**ឆ៖** មជ្ឈមណ្ឌលឯកសារកម្ពុជា ធ្វើការថតចម្លងគ្រប់ឯកសារដើមទាំងអស់ ដើម្បីឲ្យសាធារណជន អាចនឹងមកធ្វើការស្រាវជ្រាវ មកអានឯកសារបានដោយមិនអនុញ្ញាតឲ្យសាធារណជនអ្នកសិក្សាស្រាវជ្រាវ ធ្វើការប៉ះពាល់ផ្ទាល់ទៅលើឯកសារដើមទាំងអស់នេះទេ។

[១០:០៦:១៤]

**ស៖** មុនពេលមជ្ឈមណ្ឌលឯកសារកម្ពុជា បានទទួលទស្សនាវដ្ដីទាំងនេះ តើទស្សនាវដ្ដីទាំងនេះត្រូវបានរក្សាទុកនៅទីណា?

**ឆ៖** ដូចឯកសារដទៃផ្សេងទៀតដែរ គឺទស្សនាវដ្ដីនេះ យើងបានទទួលពី-- ទីមួយ គឺបានទទួលពីខាងទួលស្លែង បាទ សារមន្ទីរឧក្រិដ្ឋកម្មទួលស្លែង និងទីពីរ បានមកពីបុគ្គលដែលពេលដែលចូលមកដល់ទីក្រុងភ្នំពេញ បន្ទាប់ពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ គឺឯកសារទាំងអស់នេះ វាអាចនៅក្នុងដៃបុគ្គល ឬក៏នៅក្នុងផ្ទះមួយដែលពេលដែលប្រជាពលរដ្ឋ អ្នកដែលចូលមករស់នៅទីក្រុងភ្នំពេញបានជួបប្រទះ ហើយប្រគល់មកមជ្ឈមណ្ឌលឯកសារកម្ពុជា។

**ស៖** តើមានវិធានការអ្វីខ្លះ ដើម្បីធានាបានថា សំណៅថតចម្លងដូចគ្នានឹងសំណៅដើម?

**ឆ៖** ជាក់ស្ដែង ដូចជាឯកសារដែលមជ្ឈមណ្ឌលឯកសារកម្ពុជា បានផ្ដល់មកអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺរាល់ឯកសារថតចម្លង ឬក៏ស្កេន ត្រូវបានបញ្ជាក់យ៉ាងច្បាស់លាស់ថាតើការថតចម្លងនោះ គឺជាការថតចម្លងឯកសារចេញពីឯកសារដើម ឬក៏ចេញពីឯកសារដែលថតចម្លងដែលមាននៅមជ្ឈមណ្ឌលឯកសារកម្ពុជា។

[១០:០៨:៤១]

**ចៅក្រម យ៉ា សុខន៖**

ជម្រាបលោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកចៅក្រម។ តើអស់លោក លោកស្រីចៅក្រមមានសំណួរអ្វីចង់សួរសាក្សីរូបនេះទៀតទេ?

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក!

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកប្រធាន។ សំណួរទាំងអស់នេះ គឺជាសំណួរបំភ្លឺចំពោះចម្លើយដែលលោកបានឆ្លើយជូន-- លោក វ៉ាន់ថាន់ ដារ៉ាពៅ។

**ស៖** ជាដំបូង ត្រឡប់មករឿងរបស់ ឌី.ស៊ី.ខេម វិញ ដែលលោកបានពន្យល់អម្បាញ់មិញនេះ ថាដើមកំណើតដំបូងនៃមជ្ឈមណ្ឌលនេះ គឺជាដំបូងគឺជាការិយាល័យសិក្សាមួយដែលបង្កើតឡើងដោយសាកលវិទ្យាល័យយែល។ ខ្ញុំគិតថា លោកបាននិយាយថា នៅឆ្នាំ១៩៩៣ តើត្រឹមត្រូវដែរឬទេ?

[១០:០៩:៥២]

**ឆ៖** ខ្ញុំនិយាយថា ឆ្នាំ១៩៩៥ មិនមែនឆ្នាំ១៩៩៣ទេ។

**ស៖** បើអ៊ីចឹងគឺឆ្នាំ១៩៥៥? មជ្ឈមណ្ឌលនេះ បង្កើតនៅឆ្នាំ១៩៥៥ តើវាពាក់ព័ន្ធនឹងរបបខ្មែរក្រហមយ៉ាងម៉េចដែរ ខ្ញុំដូចជាមិនយល់?

**ឆ៖** ខ្ញុំបាននិយាយថា មជ្ឈមណ្ឌលឯកសារកម្ពុជាបានកកើតដំបូង គឺជាការិយាល័យស្រាវជ្រាវមួយ ជាផ្នែកមួយរបស់សាកលវិទ្យាល័យយែល នៅក្នុងឆ្នាំ១៩៩៥ មិនមែនឆ្នាំ១៩៩៣ ឬក៏ឆ្នាំ១៩៥៥ នោះទេ។

**ស៖** លោកបានពន្យល់អម្បាញ់មិញនេះថា មជ្ឈមណ្ឌលឯកសារកម្ពុជាបានក្លាយជាមជ្ឈមណ្ឌលឯករាជ្យពីសាកលវិទ្យាល័យយែល តើលោកអាចបញ្ជាក់ជូនអង្គជំនុំជម្រះបានទេ ថាតើវាមានហេតុការណ៍យ៉ាងម៉េច? តើមានអង្គការថ្មីដែលបង្កើតឡើង ឬហើយមានទម្រង់គតិយុត្តជាក់លាក់ដែរឬក៏យ៉ាងម៉េច? តើលោកអាចបញ្ជាក់ឲ្យបានច្បាស់ទេ អំពីទម្រង់គតិយុត្តបច្ចុប្បន្ននៃមជ្ឈមណ្ឌលនេះ តើវាជាអង្គការក្រៅរដ្ឋាភិបាល វាជាមូលនិធិ តើទម្រង់គតិយុត្តនៃមជ្ឈមណ្ឌលនេះយ៉ាងម៉េចដែរ? សូមជម្រាបជូនតុលាការ។

[១០:១១:៤៦]

**ឆ៖** សូមអរគុណលោកចៅក្រម។ ត្រង់ចំណុចនេះ គឺថាមជ្ឈមណ្ឌលឯកសារកម្ពុជាដែលជាអង្គការក្រៅរដ្ឋាភិបាល ជាអង្គការសិក្សាស្រាវជ្រាវឯករាជ្យមួយនេះ គឺនៅពេលនោះ គឺអាណត្តិការងាររបស់សាកលវិទ្យាល័យយែលនេះ ត្រូវបានបញ្ចប់ក្នុងរយៈពេលពីរគឺពីឆ្នាំ៩៥ ដល់ឆ្នាំ៩៧។ អ៊ីចឹង ចាប់ពីឆ្នាំ៩៧មក គឺមជ្ឈមណ្ឌលឯកសារកម្ពុជាបានក្លាយទៅជាអង្គការមួយ ជាអង្គការក្រៅរដ្ឋាភិបាលជាអង្គការឯករាជ្យមួយដែលធ្វើការសិក្សាស្រាវជ្រាវបន្តពីការងារ ពីបេសកកម្មទាំងឡាយដែលមានតាំង

ពីឆ្នាំ៩៥ ដូចដែលធ្វើការងារនៅជាមួយនឹងសាកលវិទ្យាល័យយ៉េលអ៊ីចឹង។

**សៈ** តើលោកអាចជម្រាបជូនតុលាការបានទេ ថាក្នុងគោលបំណងរបស់មជ្ឈមណ្ឌលនេះ គឺមានការប្រែប្រួលពាក់ព័ន្ធទៅនឹងគម្រោងរបស់សាកលវិទ្យាល័យយ៉េល និងគម្រោងរបស់មជ្ឈមណ្ឌល តើគោលបំណងគឺនៅដដែល នៅពេលដែលមានផ្លាស់ប្តូរពីមកកាន់ជាមជ្ឈមណ្ឌលឯករាជ្យនោះ?

**ឆៈ** គោលបំណងនៃមជ្ឈមណ្ឌលឯកសារកម្ពុជា គឺមានដូចដែលមានពីខាងដើមហ្នឹងតែម្តងដូចខ្ញុំបាន ខ្ញុំបាទជម្រាបពីខាងដើម។

**សៈ** ខ្ញុំគិតថា ប្រហែលជាមានបញ្ហាក្នុងការបកប្រែ។ តើលោកអាចនិយាយម្តងទៀតបានទេនូវចម្លើយរបស់លោក? ពីព្រោះថា យើងអត់ទាន់ទទួលបានការបកប្រែជាភាសាបារាំងនោះទេ ខ្ញុំមិនដឹងថាភាសាអង់គ្លេសមានបកទេ។ ខ្ញុំអត់បានស្តាប់ឮជាភាសាបារាំងនូវចម្លើយរបស់លោកទេ។ សូមទោស។

សូមអញ្ជើញលោកនិយាយម្តង!

[១០:១៤:១១]

**ឆៈ** បាទ ចំពោះគោលបំណងនៃមជ្ឈមណ្ឌលឯកសារកម្ពុជានេះ គឺខ្ញុំបាទសូមបញ្ជាក់ម្តងទៀតថាមជ្ឈមណ្ឌលឯកសារកម្ពុជាមានគោលដៅសំខាន់ពីរ។ គឺទីមួយ គឺប្រមែប្រមូលចងក្រងឯកសារទាក់ទងទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីបម្រើដល់ផ្នែកប្រវត្តិសាស្ត្រ និងការចងចាំនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ហើយគោលបំណងទីពីរ គឺការផ្តល់ជូនឯកសារដល់អ្នកទាំងឡាយដែលមានបំណងចង់ស្វែងរកនូវយុត្តិធម៌សម្រាប់អ្នករស់រានមានជីវិត ក៏ដូចជាការស្វែងរកនូវសាច់ញាតិក្រុមគ្រួសារដែលបានបាត់បង់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

[១០:១៥:១១]

**សៈ** មជ្ឈមណ្ឌលឯកសារកម្ពុជានៅតែបន្តអភិវឌ្ឍគម្រោង ដែលបានបង្កើតឡើងតាំងពីដំបូងដែលបង្កើតដោយសាកលយ៉េល អ៊ីចឹងគោលបំណង គឺថានៅដដែល អត់មានប្រែប្រួលទេ តើអ៊ីចឹងមែនទេ?

**ឆៈ** ជម្រាបប្រសាសន៍លោកចៅក្រម ទាំងគោលបំណង ទាំងបេសកកម្មគឺនៅដដែល។

**សៈ** ពាក់ព័ន្ធទៅនឹងហិរញ្ញប្រទានលោកបានបញ្ជាក់ជូនថា ឌី.ស៊ី.ខេម ទទួលបានហិរញ្ញប្បទានពីប្រភពរដ្ឋាភិបាល ពីសាលារៀន ឬក៏សាកលវិទ្យា ហើយនិងពីអង្គការផ្សេងទៀតដែលមិនមានគោលដៅ មិនរកប្រាក់ចំណេញ ឬក៏អង្គភាព ឬក្រុមហ៊ុនឯកជន។ តើលោកអាចបញ្ជាក់ឲ្យបានច្បាស់បន្តិចទេ

អំពីទឹកប្រាក់របស់ ឌី.ស៊ី.ខេម ហើយតើមានការបែងចែកប្រភពនៃហិរញ្ញប្បទាននេះយ៉ាងម៉េចដែរ?

[១០:១៦:២៥]

**ឆៈ** ខ្ញុំបាទ ដូចបានជម្រាបពីខាងដើម គឺទាក់ទងនឹងរឿងហិរញ្ញវត្ថុ គឺមានមន្ត្រីដែលធ្វើការងារជំនាញទៅលើហិរញ្ញវត្ថុនេះតែម្តង។ ខ្ញុំបាទធ្វើការងារភាគច្រើនផ្ទាល់គឺទៅលើឯកសារ មិនទៅលើផ្នែកហិរញ្ញវត្ថុទេ។

**សៈ** លោកបានបញ្ជាក់ជូនថា សាកលវិទ្យាល័យយែល គឺនៅតែជាដៃគូរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា តើភាពជាដៃគូនេះ ជាភាពជាដៃគូហិរញ្ញវត្ថុ ឬក៏ជាដៃគូខាងផ្នែកស្រាវជ្រាវ? តើមានការផ្លាស់ប្តូរបុគ្គលិកគ្នាទេ មានការបណ្តុះបណ្តាល ដែលធ្វើឡើងដោយសាកលវិទ្យាល័យយែល? តើភាពជាដៃគូហ្នឹងសម្រេចឡើងយ៉ាងដូចម្តេច?

**ឆៈ** ភាពជាដៃគូជាមួយនឹងសាកលវិទ្យាល័យយែល គឺសំដៅទៅលើការសិក្សាស្រាវជ្រាវ។

**សៈ** តើលោកមានជាអ្នកស្រាវជ្រាវនៅសាកលវិទ្យាល័យយែលមកធ្វើការនៅ ឌី.ស៊ី.ខេម ដែរឬទេ? តើវាជាប្រភេទនៃការសហការគ្នាយ៉ាងម៉េចដែរ?

**ឆៈ** បាទលោកចៅក្រម គឺមានអ្នកសិក្សាស្រាវជ្រាវពីសាកលវិទ្យាល័យមកធ្វើការសិក្សាស្រាវជ្រាវនៅមជ្ឈមណ្ឌលឯកសារកម្ពុជា។

[១០:១៨:២២]

**សៈ** គឺជាអ្នកដែលស្រាវជ្រាវដែលមានចំនួនច្រើន គឺគាត់មានការប្រចាំការ ឬក៏មានការប្រែប្រួលយ៉ាងម៉េចដែរនៅមជ្ឈមណ្ឌលហ្នឹង? សូមលោកបញ្ជាក់ឲ្យបានច្បាស់បន្តិច។

**ឆៈ** ចំពោះការសិក្សាស្រាវជ្រាវ វាអាស្រ័យទៅលើអ្នកសិក្សាស្រាវជ្រាវដែលមកពីសាកលវិទ្យាល័យយែល។ ពេលវេលាអាចទៅតាមការកំណត់ ទៅតាមការមានពេលវេលារបស់អ្នកសិក្សាស្រាវជ្រាវ។ ជាក់ស្តែងដូចជានិស្សិតដែលត្រូវធ្វើការសិក្សាអំពីផ្នែកប្រវត្តិសាស្ត្រអាចនឹងមកធ្វើការស្រាវជ្រាវនៅមជ្ឈមណ្ឌលឯកសារកម្ពុជានៅអំឡុងពេល *សាំមើ* (summer) ហើយមកគឺរយៈពេលអាចពីប្រាំមួយ ទៅដប់ពីរសប្តាហ៍ ឬក៏អាចវែងជាងនេះតាមប្រធានបទមួយៗដែលអ្នកសិក្សាស្រាវជ្រាវនោះ ចង់ធ្វើការសិក្សាស្រាវជ្រាវ។

**សៈ** តើលោកអាចបញ្ជាក់បានទេ ឲ្យបានលើសពីហ្នឹងទេ អំពីគម្រោងស្រាវជ្រាវផ្សេងៗដែលកំពុងតែប្រព្រឹត្តទៅនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ឬក៏គម្រោងដែលត្រូវបានធ្វើចប់រួចមកហើយ តើ

មានប្រភេទគម្រោងណាខ្លះ? តើគម្រោងទាំងអស់ហ្នឹង លោកដំណើរការដល់ដំណាក់កាលណាអស់ទៅហើយ?

[១០:២០:០៧]

**ឆ៖** បាទ, នៅមជ្ឈមណ្ឌលឯកសារកម្ពុជាយើងមានគម្រោងជាច្រើន ដែលទ្រទ្រង់នូវការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទាំងមូលតែម្តង ដែលគម្រោងនីមួយៗនេះ មានការដឹកនាំដោយប្រធានក្រុមមួយសម្រាប់គម្រោងមួយ ហើយគម្រោងទាំងអស់នេះ បច្ចុប្បន្ននៅកំពុងតែមានដំណើរការនៅពេលរហូតដល់បច្ចុប្បន្ននេះនៅឡើយ។

**ស៖** អម្បាញ់មិញ គឺលោកនិយាយអំពីគម្រោងផែនទី គូសផែនទីនៃកន្លែងដែលយើងអាចរករណ្តៅសាកសពរួម ឬក៏ជាមន្ទីរសន្តិសុខ តើលោកអាចបញ្ជាក់ជូនបានដែរឬទេ ថាតើគម្រោងនេះ ចប់ហើយនៅ ឬក៏នៅកំពុងធ្វើការស្រាវជ្រាវនៅឡើយ? ហើយការស្រាវជ្រាវរុករកហ្នឹង គឺថាមានការកាយរករណ្តៅអីដែរឬទេ? សូមលោកបញ្ជាក់ឲ្យបានច្បាស់បន្តិចបាទ។

[១០:២១:០០]

**ឆ៖** ទាក់ទងនឹងគម្រោងជាក់លាក់មួយនេះ គឺគម្រោងចងក្រង ឬក៏ធ្វើផែនទីរណ្តៅសាកសពរួមនេះ គឺគម្រោងនេះ គឺមានការងារសកម្មនៅពេល រយៈពេលពីឆ្នាំ៩៥ មក ដោយសារថាមានការចងក្រងបានច្រើន គម្រោងនេះមានការរយាលសម្រាប់រយៈពេលប៉ុន្មានឆ្នាំចុងក្រោយ។ ប៉ុន្តែ មិនមែនមានន័យថា ត្រូវបានធ្វើដោយចប់សព្វគ្រប់នោះទេ។

**ស៖** តើលោកអាចបញ្ជាក់ជូនអង្គជំនុំជម្រះបានទេថា គម្រោងសំខាន់ៗផ្សេងទៀតរបស់ ស៊ី.ឌី.ខេម ហ្នឹងគឺស្អីខ្លះ?

**ឆ៖** ក្រៅពីគម្រោងៗ*មេបភីង* (maping) នេះ គឺយើងមានគម្រោងផ្សេងៗទៀតដូចជា គម្រោងជំរុញឲ្យមានការទទួលខុសត្រូវ ដែលគម្រោងនេះ យើងការងារសំខាន់ គឺការធ្វើសម្ភាសជាមួយនឹងអ្នករស់រានមានជីវិត ក៏ដូចជាអតីតយុទ្ធជនកម្មាភិបាលខ្មែរក្រហមដែលមានប្រវត្តិរូបផ្ទាល់។ យើងមានគម្រោងឯកសារ គឺទាក់ទងនឹងការប្រមែប្រមូលចងក្រងឯកសារនេះ ហើយរហូតមកដល់ សព្វថ្ងៃនេះក៏យើងនៅតែទទួលបានឯកសារថ្មីៗបន្ថែម។ គម្រោងផ្សព្វផ្សាយ គឺយើងធ្វើការផ្សព្វផ្សាយអំពីការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក៏ដូចជាការងារទាក់ទងទៅនឹងការងារដែលពាក់ព័ន្ធ។ គម្រោងបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យទៅតាមសាលារៀនក៏នៅតែបន្តធ្វើ ហើយដែលគម្រោងនេះ

យើងបានបណ្តុះបណ្តាលលោកគ្រូ អ្នកគ្រូ ដែលបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិប តេយ្យនេះបាន ៣.០០០នាក់ រួចមកហើយនៅទូទាំងប្រទេស។

គម្រោងចងក្រងឯកសារផ្ទាល់មាត់ ដែលគម្រោងនេះនៅតែអនុវត្តនៅឡើយនៅមជ្ឈមណ្ឌលឯកសារកម្ពុជា។ គម្រោងទស្សនាវដ្តីស្វែងរកការពិតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាក៏ជាគម្រោងមួយដែលនៅតែអនុវត្តបន្តរហូតមកដល់ពេលបច្ចុប្បន្ននេះ ហើយនិងមានគម្រោងផ្សេងៗទៀត។

[១០:២៥:០០]

**ស៖** លោកបានបញ្ជាក់ជូនអម្បាញ់មិញនេះ នៅពេលសួរដោយលោកចៅក្រម យ៉ា សុខន លោកបានបញ្ជាក់ថា មជ្ឈមណ្ឌល ស៊ី.ឌី.ខេម គឺមានឯកសារជាង១លានទំព័រ គឺឯកសារសរសេរ ឯកសារជាក្រដាស។ តើលោកអាចបញ្ជាក់ពីចំណុចនេះបានដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លើកចៅក្រម ខ្ញុំបាននិយាយថា ឯកសារជាប្រភេទក្រដាស ជាទំព័រនេះមានជិត១លាន មិនមែនជាង១លានទេ។

**ស៖** លោកបានពន្យល់ថា ឯកសារក្រដាសគឺត្រូវបានថតចម្លង ហើយឯកសារហ្នឹងគឺថាដាក់ឯកសារចម្លងដាក់ចូលជាកន្លែងត្រឹមត្រូវ។ តើជាឯកសារក្រដាស ឬក៏ជាឯកសារដែលយើងថតចម្លងដាក់ចូលជាក្នុងកុំព្យូទ័រ? ហើយជាឯកសារស្កេន ឬក៏គ្រាន់តែកូពីជាក្រដាសចេញមក?

[១០:២៦:១២]

**ឆ៖** ចំពោះឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ជាឯកសារសន្លឹកជាក្រដាសនេះ គឺយើងបានធ្វើការថតចម្លង ដើម្បីបម្រើដល់ការសិក្សាស្រាវជ្រាវ ដល់ការ-- ដល់សាធារណជន ដល់ភាគីដែលមានការចាប់អារម្មណ៍នៅក្នុងការសិក្សាស្រាវជ្រាវ អំពីរបបកម្ពុជាប្រជាធិបតេយ្យ គឺយើងបានធ្វើការថតចម្លងដាក់នៅក្នុងទូឯកសារ ដែលអាចយើងប្រើប្រាស់ជារៀងរាល់ថ្ងៃ ជាប្រចាំបាន។

**ស៖** នៅពេលដែលសាធារណជនទៅពិគ្រោះឯកសារទាំងអស់នោះ តើពួកគាត់អាចទទួលបានឯកសារថតចម្លងជាក្រដាស ឬក៏គាត់អាចចូលពិគ្រោះទៅក្នុងឯកសារមូលដ្ឋានទិន្នន័យដែលមាននៅក្នុងកុំព្យូទ័រ?

**ឆ៖** ជាទូទៅនៅក្នុងការមកធ្វើការសិក្សាស្រាវជ្រាវនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ទាក់ទងទៅនឹងការនិងឯកសារនេះ គឺយើងមានប្រព័ន្ធទិន្នន័យនៅក្នុងកុំព្យូទ័រ ដែលយើងបានបង្ហោះនៅក្នុងគេហទំព័រ ដែលតាមរយៈគេហទំព័រនេះគឺអ្នកសិក្សាស្រាវជ្រាវអាចស្វែងរកឯកសារដែលខ្លួនចង់បាន។ បន្ទាប់មក

គឺអ្នកសិក្សាស្រាវជ្រាវនេះ នឹងធ្វើជាសំណើមកមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីធ្វើការថតចម្លងឯកសារយកទៅប្រើប្រាស់ ហើយឯកសារនេះអាចយើងធ្វើទាំងពីរយ៉ាង គឺយើងហ្វូតូកូពី យើងថតចម្លងដាក់នៅលើជាសន្លឹកក្រដាស ហើយក៏យើងអាចនឹងធ្វើការស្កេនផ្ញើតាមអេឡិចត្រូនិចដែរ។ ប៉ុន្តែភាគច្រើនគឺថតចម្លងនៅលើក្រដាសហ្នឹងតែម្តង។

[១០:២៨:៣១]

**ស៖** តើព័ត៌មានដែលមាននៅលើ*ស៊ីត*(sheet) អ៊ីនធឺណេតរបស់លោកហ្នឹងមានអីខ្លះ? តើយើងអាចចូលទៅគ្រប់កាតាឡុកឯកសារ ដែលរក្សាទុកដោយ ឌី.ស៊ី.ខេម ឬក៏យើងអាចចូលបានតែត្រឹមតែមួយផ្នែកនៃកាតាឡុកទាំងអស់ហ្នឹង? តើលោកអាចបញ្ជាក់ឲ្យបានច្បាស់ទេ? គឺថាយើងដឹងថា តួនាទីរបស់ ឌី.ស៊ី.ខេម ហ្នឹងគឺរៀបចំកាតាឡុកឯកសារ ដើម្បីជួយសម្រួលដល់ការទទួលបានឯកសារ និងការស្រាវជ្រាវឯកសារ។ សូមលោកបញ្ជាក់ឲ្យបានច្បាស់។

**ឆ៖** ជាការពិត គឺអ្នកសិក្សាស្រាវជ្រាវអាចរកបានព័ត៌មានទាក់ទងទៅនឹងឯកសារនេះតាមប្រព័ន្ធកុំព្យូទ័រ តាមគេហទំព័រ ដោយយើងបានបង្ហោះនូវ យើងបានដាក់បញ្ចូលនូវប្រព័ន្ធទិន្នន័យទាក់ទងនឹងឯកសារនេះ នៅលើគេហទំព័រ ដែលនៅក្នុងនោះមានៗឯកសារគ្រប់ប្រភេទដែលយើងបានចងក្រងបានដាក់បង្ហោះនៅលើគេហទំព័រ។

[១០:៣០:០៩]

**ស៖** តើបញ្ជីឯកសារនៅក្នុងកាតាឡុក ដែលអាចចូលមើលតាមអ៊ីនធឺណេត តើមានពេញលេញគ្រប់គ្រាន់? ឬក៏មានឯកសារមួយចំនួនដែលមានថារក្សាការសម្ងាត់ ហើយខាងលោក គឺមិនអាចឲ្យចូលបាន គឺថាបើសិនជាចូលមើលបាន គឺទាល់មានលក្ខខណ្ឌមួយចំនួន។ គឺឧទាហរណ៍ នៅពេលដែលគេប្រគល់ឯកសារឲ្យខាងលោកហ្នឹង គឺគេមានដាក់លក្ខខណ្ឌថា ឲ្យរក្សាការសម្ងាត់នៃឯកសារទាំងអស់នេះ? ឬក៏គ្មានលក្ខខណ្ឌកំណត់ពាក់ព័ន្ធទៅនឹងការទទួល ការពិគ្រោះឯកសារទាំងអស់នេះទេ?

**ឆ៖** បណ្តាឯកសារដែលមជ្ឈមណ្ឌលឯកសារកម្ពុជាប្រមែប្រមូលនិងចងក្រងទុកនេះ គឺសម្រាប់បម្រើដល់សាធារណជន។ អ៊ីចឹងអ្នកណាក៏អាចនឹងមកធ្វើការសិក្សាស្រាវជ្រាវ ធ្វើការស្នើសុំឯកសារទាំងអស់នេះបាន។ យើងមិនបានមានដាក់លក្ខខណ្ឌអ្វីនោះទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក ដាវ៉ាពៅ។ ឥឡូវដោយដល់ពេលសមល្មមនឹងសម្រាកហើយ ដូច្នេះអង្គជំនុំ

ជម្រះសូមប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយចន្លោះពេលនេះ សូមលោកមន្ត្រីគ្រប់គ្រងតុលាការសម្របសម្រួលសាក្សីរូបនេះបានសម្រាក រកកន្លែងសម្រាកឲ្យគាត់សមរម្យ ហើយនិងឲ្យនាំគាត់មកកាន់អាសនៈ កន្លែងដែលគាត់សម្រាប់ផ្តល់សក្ខីកម្មនេះ មុនពេលអង្គជំនុំជម្រះចូលមកកាន់អាសនៈរបស់ខ្លួន។

សូមអញ្ជើញលោកមេធាវី!

[១០:៣១:៥៧]

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន ខ្ញុំបាទសូមលោកប្រធានអនុញ្ញាតឲ្យលោក អៀង សារី ទៅចូលរួមសវនាការនៅបន្ទប់រង់ចាំខាងក្រោម ដោយហេតុថាគាត់កំពុងឈឺឆ្អឹងខ្នង ហើយមិនអាចទ្រាំទ្រអង្គុយតទៀត។ សូមយើងសូមនេះ គឺសូមសម្រាប់តែមួយថ្ងៃនេះ ហើយយើងនឹងដាក់ពាក្យមកតាមត្រឹមត្រូវ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទយើងយល់ព្រមអនុញ្ញាតតាមសំណើរបស់លោក អៀង សារី ដែលបានស្នើតាមរយៈមេធាវីរបស់លោក សូមមិនចូលរួមផ្ទាល់នៅក្នុងការតាមដានកិច្ចដំណើរការសវនាការនៅក្នុងបន្ទប់សវនាការនេះ ដោយសូមដកខ្លួនថយទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍ ដែលនៅបន្ទប់ខាងក្រោមនៃបន្ទប់សវនាការនេះ។ ហើយយើងអនុញ្ញាតតាមការស្នើសុំនេះ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំលោក នួន ជា អ៎ សូមទោស! អៀង សារី ត្រឡប់ទៅកាន់បន្ទប់ខាងក្រោមដើម្បីឲ្យគាត់តាមដានសវនាការពីចម្ងាយ។ ហើយតម្រូវឲ្យមេធាវីការពារក្តីដាក់នូវពាក្យសុំលះបង់សិទ្ធិដោយមានការចុះហត្ថលេខា ឬក៏ផ្តិតស្នាមមេដៃរបស់ជនជាប់ចោទមកអង្គជំនុំជម្រះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១០:៣៤ នាទី ដល់ម៉ោង ១០:៥២ នាទី)*

[១០:៥២:៥២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការ ហើយមុននឹងប្រគល់វេទិកាទៅឲ្យលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ អង្គជំនុំជម្រះបង្គាប់ទៅមន្ត្រីសោតទស្សន៍សូមភ្ជាប់រូបភាព និងសំឡេងវីដេអូ ទៅបន្ទប់ដែលសម្រាប់លោក អៀង សារី តាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

ជាបន្តសូមប្រគល់-- សូមអញ្ជើញលោក នួន ជា!

**លោក នួន ជា៖**

គោរពលោកប្រធាន ខ្ញុំសូមអនុញ្ញាតទៅតាមដានខាងក្រោមមួយល្ងាច ព្រោះសុខភាពខ្ញុំមិនអំណោយ។

[១០:៥៤:០៥]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំអនុញ្ញាតតាមការស្នើសុំរបស់លោក នួន ជា ដោយសុំលះបង់សិទ្ធិក្នុងការមិនចូលរួមតាមដានកិច្ចដំណើរការសវនាការផ្ទាល់ នៅក្នុងបន្ទប់សវនាការនេះ។ ហើយទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍ នៅបន្ទប់ខាងក្រោមនៃសាលសវនាការនេះ ហើយដូចគ្នាគឺខាងផ្នែកសោតទស្សន៍សូមភ្ជាប់នូវប្រព័ន្ធរូបភាព សំឡេងវីដេអូ ទៅបន្ទប់ខាងក្រោមសម្រាប់លោក នួន ជា តាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ ហើយក៏សូមរំឭកដែរថា លោក នួន ជា ដោយមានបញ្ហាជាច្រើនពាក់ព័ន្ធនឹងឯកសារ ហើយនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ គឺយើងជជែកពិភាក្សាពាក់ព័ន្ធទៅនឹងឯកសារ។ ដូច្នេះ គឺជាសិទ្ធិរបស់លោកនៅក្នុងការតាមដានកិច្ចដំណើរការសវនាការ ពាក់ព័ន្ធជាមួយនឹងសាក្សី ដែលផ្តល់សក្ខីកម្មពាក់ព័ន្ធទៅនឹងឯកសារ នៃមជ្ឈមណ្ឌលឯកសារកម្ពុជានេះ។

អនុរក្សមន្ទីរឃុំឃាំងនាំខ្លួន លោក នួន ជា ទៅបន្ទប់ខាងក្រោមដើម្បីឲ្យគាត់បន្តការតាមដានកិច្ចដំណើរការសវនាការ តាមប្រព័ន្ធសោតទស្សន៍ពីចម្ងាយ ហើយបង្គាប់ឲ្យមេធាវីការពារក្តីផ្តល់នូវលិខិតលះបង់សិទ្ធិរបស់ នួន ជា ក្នុងការចូលរួមផ្ទាល់ទៅតាមដានសវនាការពីចម្ងាយដោយច្បាស់លាស់ ដោយក្បោះក្បាយ ហើយនិងដោយមានការចុះហត្ថលេខា ឬផ្តិតម្រាមដៃផ្តល់មកឲ្យអង្គជំនុំជម្រះភ្លាម។ នាំទៅចុះ!

[១០:៥៥:៥៧]

ជាបន្ត អង្គជម្រះសូមផ្តល់វេទិកា ទៅលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីបន្តការតាំងសំណួរដល់សាក្សីលោក ដាវ៉ាពៅ។ សូមអញ្ជើញលោកចៅក្រម!

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។

**ស៖** លោក បាននិយាយថា ឌី.ស៊ី.ខេម រក្សាឯកសារទុកជិត១លានឯកសារ ជិត១លានទំព័រ ដែលជាឯកសារក្រដាស។ តើចំពោះឯកសារទាំងអស់នេះ លោកអាចបញ្ជាក់ ជាលក្ខណៈប្រហាក់ប្រហែលបានទេថា តើឯកសារប៉ុន្មានដែលពាក់ព័ន្ធទៅនឹងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ឬមួយក៏លោកមិនដឹងទេ សូមលោកអាចឆ្លើយជូនតុលាការ?

**ឆ៖** សម្រាប់អាណត្តិរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅក្នុងការប្រមែប្រមូលឯកសារគឺយើងបានកំណត់ពេលវេលាជាក់លាក់ គឺពីឆ្នាំ៧៥ ដល់ឆ្នាំ៧៩។ អ៊ីចឹង ឯកសារដែលប្រមែប្រមូលចងក្រងមកនេះគឺសុទ្ធជាឯកសារដែល ជាឯកសាររបស់កម្ពុជាប្រជាធិបតេយ្យ និងជាឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យ។

**ស៖** អ្វីដែលខ្ញុំចង់ដឹងនោះ តើឯកសារប៉ុន្មានដែលអាចចាត់ទុកថាជាឯកសារសំខាន់ ឯកសារចម្បង ហើយដែលវាជាប់ពាក់ព័ន្ធផ្ទាល់ ថាមានទំនាក់ទំនងទៅនឹងខ្មែរក្រហម ដូចជា ទូរលេខ គឺជាឯកសារដែលកើតពេលនៅសម័យកម្ពុជាប្រជាធិបតេយ្យ?

[១០:៥៨:២៥]

**ឆ៖** ដូចខ្ញុំបាទមានប្រសាសន៍ពីខាងដើមគឺថា យើងមជ្ឈមណ្ឌលឯកសារកម្ពុជា មិនបានធ្វើការវិភាគទៅលើឯកសារនោះទេ។ ដូច្នេះ ឯកសារមកទទួលបានយ៉ាងម៉េច គឺឯកសារនោះគឺវាជាឯកសារតាមរបៀបនេះ ហើយយើងមិនបានគិតថាឯកសារណាមួយសំខាន់ជាងឯកសារណាមួយនោះទេ គឺឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា មានសារៈសំខាន់ដូចៗគ្នាទាំងអស់។

**ស៖** លោកអាចបញ្ជាក់បានទេថា ក្នុងចំណោមឯកសារទាំងអស់នេះ ឯកសារមួយចំនួនជាភាសាខ្មែរ ហើយឯកសារផ្សេងទៀត មានភាសាផ្សេងទៀតដូចជា ភាសាអង់គ្លេស ភាសាវៀតណាម ភាសាថៃ ភាសាបារាំង រុស្ស៊ី តើលោកអាចបញ្ជាក់អំពីប្រភេទនៃភាសាផ្សេងៗ ដែលមាននៅក្នុងឯកសារទាំងអស់នេះបានទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម គឺឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា មានជាភាសាខ្មែរ មានជាភាសាអង់គ្លេស មានជាភាសាស៊ុយអែត មានជាភាសាអាល្លឺម៉ង់ និងមានភាសាមួយចំនួនទៀតបាទ។

[១១:០០:១៤]

**ស៖** តើមជ្ឈមណ្ឌលឯកសារកម្ពុជាមានធនធានផ្ទៃក្នុងដើម្បីធ្វើការបកប្រែឯកសារដែរឬទេ? ហើយតើមានគោលនយោបាយពាក់ព័ន្ធនឹងការបកប្រែនេះ គឺថាមានការបកប្រែនៅពេលធ្វើការស្រាវជ្រាវ ឬក៏បកប្រែនៅពេលដែលមានការស្នើសុំ តើលោកអាចបញ្ជាក់អំពីបញ្ហាបកប្រែបានទេ?

**ឆ៖** រឿងបញ្ហាបកប្រែ មជ្ឈមណ្ឌលឯកសារកម្ពុជាមានក្រុមអ្នកបកប្រែ ហើយការបកប្រែនេះគឺបម្រើនៅក្នុងការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

**ស៖** នៅពេលឯកសារណាមួយត្រូវបានបកប្រែ ហើយផ្តល់ជូនទៅអ្នកស្រាវជ្រាវណាមួយនោះ តើមានចំណារជាក់លាក់ណាមួយដែលអាចឲ្យដឹងថាឯកសារនេះត្រូវបានបកប្រែនៅ ឌី.ស៊ី.ខេម ដោយធនធានផ្ទៃក្នុងរបស់ ឌី.ស៊ី.ខេម ឬក៏អត់មានទទួលបានព័ត៌មាននេះទេ?

**ឆ៖** ខ្ញុំបាទសូមបញ្ជាក់ឲ្យបានច្បាស់លាស់ត្រង់ចំណុចនេះ គឺទាក់ទងនឹងការបកប្រែ។ គឺមជ្ឈមណ្ឌលឯកសារកម្ពុជាបកប្រែឯកសារសម្រាប់សិក្សាស្រាវជ្រាវផ្ទាល់ខ្លួនរបស់-- សម្រាប់បម្រើនៅក្នុងការងារស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ ចំណែកឯអ្នកសិក្សាស្រាវជ្រាវផ្សេងទៀត ដែលមកធ្វើការសិក្សាស្រាវជ្រាវនៅមជ្ឈមណ្ឌលឯកសារកម្ពុជា នោះអ្នកសិក្សាស្រាវជ្រាវនោះ អាចមក-- អាចនាំមកនូវជាមួយអ្នកបកប្រែផ្ទាល់ខ្លួនរបស់ខ្លួន ហើយធ្វើការបកប្រែឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាតាមដែលអ្នកសិក្សាស្រាវជ្រាវនោះអាចធ្វើទៅបាន។

[១១:០២:២៥]

**ស៖** ការបកប្រែដែលធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា គឺជាឯកសារដែលបកប្រែទៅកាន់ភាសាអង់គ្លេស ឬក៏បកមកទៅជាភាសាខ្មែរ តើជាប្រភេទឯកសារណាមួយ? ហើយនៅពេលដែលធ្វើការបកប្រែនោះ ឯកសារដែលបកប្រែហើយ តើមានការបញ្ជាក់ទេ ថានៅលើឯកសារនោះថាឯកសារនេះ បកប្រែដោយមជ្ឈមណ្ឌលឯកសារកម្ពុជា? ឬក៏មានបោះត្រានៅលើនោះ ដើម្បីបញ្ជាក់ថាគឺការបកប្រែនេះ ធ្វើឡើងដោយធនធានផ្ទៃខាងក្នុងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម ទាក់ទងនឹងការបកប្រែនេះ គឺមជ្ឈមណ្ឌលឯកសារកម្ពុជានៅពេលដែលបកប្រែឯកសារណាមួយ គឺមជ្ឈមណ្ឌលឯកសារកម្ពុជាបានបញ្ជាក់យ៉ាងច្បាស់លាស់ថា តើអំពីឈ្មោះអ្នកណាដែលបកប្រែលើឯកសារនោះ ហើយយើងបានបន្សល់ឈ្មោះនៅលើឯកសារបកប្រែហ្នឹងទៀត ថាអ្នកណាជាអ្នកបកប្រែ។ សូមបញ្ជាក់ឲ្យបានច្បាស់ជាងនេះទៅទៀត គឺថា

នៅមជ្ឈមណ្ឌលឯកសារកម្ពុជាភាគច្រើនឯកសារជាភាសាខ្មែរ។

[១១:០៣:៥៨]

**សៈ** លោកបានបញ្ជាក់ថា ជំហានដំបូងនៅពេលដែលយើងទទួលបានឯកសារនោះ គឺយើងធ្វើការថតចម្លង ហើយបន្ទាប់មកយើងធ្វើជាកាតាឡុក។ ដូច្នេះ ខ្ញុំចង់ដឹងថាតើមជ្ឈមណ្ឌលឯកសារកម្ពុជាមានគោលនយោបាយពាក់ព័ន្ធទៅនឹងការចុះបញ្ជីឯកសារដែលបានប្រគល់ជូនមជ្ឈមណ្ឌលដែរឬទេ? ហើយតើមានការចុះលេខយ៉ាងដូចម្តេចដែរ ទៅលើឯកសារទាំងអស់ហ្នឹង ដើម្បីចុះបញ្ជីឯកសារ? តើជាការចុះបញ្ជីទៅតាមប្រភេទនៃឯកសារ។ តើលោកអាចពន្យល់បានទេ អំពីគោលនយោបាយនៃការចុះបញ្ជីឯកសារនេះ?

**ឆៈ** ខ្ញុំសូមបាទបញ្ជាក់ សូមលោកចៅក្រមមេត្តាបញ្ជាក់ឱ្យបានច្បាស់លាស់បន្តិច អំពីពាក្យថា "គោលការណ៍" ខ្ញុំខ្លួនឯងផ្ទាល់ ក៏មិនយល់ពាក្យថា "គោលការណ៍"ហ្នឹងយ៉ាងម៉េចនោះទេ។ សូមលោកចៅក្រមមេត្តាពន្យល់ឱ្យបានច្បាស់លាស់ជាងនេះបន្តិចទាក់ទងនឹងពាក្យគោលការណ៍បាទ។

**សៈ** តើលោកអាចបញ្ជាក់ជូនបានទេថាតើដើម្បីចុះបញ្ជីឯកសារមួយហ្នឹង តើលោកមានរបៀបធ្វើយ៉ាងណា? តើលោកបង់លេខ ហើយលេខបញ្ជីហ្នឹងមានចុះនៅលើឯកសារដែរឬទេ?

[១១:០៥:៤៩]

**ឆៈ** ជម្រាបប្រសាសន៍លោកចៅក្រម គឺរាល់ឯកសារទាំងអស់ត្រូវបានចុះលេខសម្គាល់សម្រាប់ឯកសារនីមួយៗ ដើម្បីបម្រើដល់ការសិក្សាស្រាវជ្រាវដល់ការស្វែងរកឯកសារនៅពេលដែលអ្នកស្រាវជ្រាវធ្វើការស្នើសុំ។ រាល់ការចុះលេខឯកសារទាំងអស់នេះ គឺយើងបានបែងចែកទៅតាមប្រភេទឯកសារនីមួយៗផងដែរ។ ឧទាហរណ៍ដូចជាឯកសារទាក់ទងទៅនឹងប្រវត្តិរូបនៃអតីតយុទ្ធជនកម្មាភិបាលខ្មែរក្រហមនេះ គឺមជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រើប្រាស់អក្សរ 'I" អក្សរជាភាសាអង់គ្លេសហ្នឹងដើម្បីសម្គាល់ ហើយបន្ទាប់មកទៀតគឺផ្តើមដោយលេខតែម្តង ដោយមានប្រាំខ្ទង់ សម្រាប់ចុះលេខឯកសារទាំងអស់នេះ។ ហើយឯកសារនឹងចុះលេខជាបន្តបន្ទាប់ ទៅតាមការទទួលបាននូវឯកសារទាំងអស់នេះ។

[១១:០៧: ១១]

**សៈ** ឧទាហរណ៍អក្សរផ្សេងៗដែលមាននៅដើមលេខនីមួយៗ គឺនៅលេខកូដហ្នឹងមានអក្សរ ហើយមានអក្សរផ្សេងៗគ្នា តើអក្សរផ្សេងនេះគឺបញ្ជាក់ថាមានកាតាឡុកផ្សេងៗគ្នា ព្រោះខ្ញុំហាក់ដូចជា

បានមើលឃើញឯកសារមួយចំនួននោះ គឺមានដាក់ផ្តើមដោយអក្សរ “D” តើលោកអាចបញ្ជាក់ជូនទេថាមានអក្សរប៉ុន្មានដែលលោកប្រើប្រាស់នៅមជ្ឈមណ្ឌលឯកសារកម្ពុជាហ្នឹង? ហើយវាពាក់ព័ន្ធទៅនឹងកាតាឡុកប្រភេទបែបណាខ្លះ?

**ឆៈ** ជម្រាបប្រសាសន៍លោកចៅក្រម គឺនៅក្នុងការចុះលេខឯកសារ យើងបានប្រើប្រាស់ទាំងតួអក្សរ ទាំងលេខជាមួយគ្នា គឺមានទៅតាមប្រភេទឯកសារ។ ជាក់ស្តែងដូចជាឯកសារដែលជាប្រភេទឯកសារចម្រុះ ឯកសារទូទៅ មជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រើប្រាស់អក្សរ *ឌី* អក្សរ ‘D” ពីខាងមុខ ហើយបន្ទាប់មកគឺលេខឯកសារ។

មានឯកសារប្រភេទផ្សេងទៀត ដូចជាឯកសារដែលមជ្ឈមណ្ឌលឯកសារកម្ពុជាហៅថាឯកសារលន់ នល់ ពីព្រោះដោយសារថាឯកសារនេះជាឯកសារដែលទាក់ទងនឹងរបបលន់ នល់ នេះ គឺយើងប្រើអក្សរ ‘L” បន្ទាប់ពីអក្សរ “L” គឺមានលេខបន្តបន្ទាប់។ យើងមានឯកសារប្រភេទមួយទៀត គឺទាក់ទងទៅនឹងចម្លើយសារភាព គឺសម្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺចម្លើយសារភាពនេះ យើងប្រើអក្សរ “J” ពីខាងដើម ហើយបន្ទាប់ទៅគឺលេខឯកសារ។

[១១:០៩:១២]

**សៈ** នៅលើឯកសារទាំងអស់នោះផ្ទាល់តែម្តង តើមានលេខផ្សេងទៀតទេ មានលេខចុះបញ្ជីផ្សេងទៀតទេ ឬក៏មានលេខកូដផ្សេងទៀតទេដែលប្រើប្រាស់ដោយខាងមជ្ឈមណ្ឌលឯកសារកម្ពុជានោះ? ខ្ញុំគិតថាឯកសារមួយចំនួនដែលបានប្រគល់ជូនខាងលោក ឬក៏លោកបានថតចម្លង ឬក៏មានបណ្ណសារផ្សេងទៀត ឬក៏មានមូលដ្ឋានទិន្នន័យផ្សេងទៀតនោះ គឺប្រើប្រាស់លេខចុះបញ្ជីផ្ទាល់ខ្លួន តើលោកអាចបញ្ជាក់ជូនបានទេថា នៅលើឯកសារមួយ យើងអាចមានឃើញលេខចុះបញ្ជីច្រើននៅលើឯកសារនុ៎ង ហើយយើងងាយស្រួលក្នុងការកំណត់អត្តសញ្ញាណលេខទាំងអស់ហ្នឹង?

[១១:១០:០៥]

**ឆៈ** ខ្ញុំបាទសូមបញ្ជាក់ថា នៅពេលដែលយើងចុះលេខឯកសារ គឺយើងមិនបានប៉ះពាល់ទៅដល់ឯកសារដើមទេ។ គឺឯកសារដើមដែលមកយ៉ាងម៉េច គឺឯកសារហ្នឹងវានៅតែជារូបរាងដើមយ៉ាងដូចដែលឯកសារដើម។ យើងបានថតចម្លងឯកសារដើមនេះ ហើយមជ្ឈមណ្ឌលឯកសារកម្ពុជាចុះលេខនៅលើឯកសារថតចម្លង។ អ៊ីចឹងនៅលើឯកសារថតចម្លង លោកចៅក្រមនឹងឃើញលេខឯកសារនេះនៅលើឯកសារថតចម្លងនេះតែម្តង ដោយអត់មានឃើញលេខនេះនៅលើឯកសារដើមទេ។ ការធ្វើដូច្នេះ

គឺដើម្បីងាយស្រួលក្នុងការធ្វើការសិក្សាស្រាវជ្រាវ ធ្វើការប៉ះពាល់ទៅលើឯកសារនេះដែលជាការសិក្សាស្រាវជ្រាវជាប្រចាំ ជាការងារប្រចាំថ្ងៃរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយដើម្បីឲ្យដឹងថាឯកសារថតចម្លងនេះ យើងថតចម្លងចេញពីឯកសារដើមមួយណា គឺនៅខាងក្រោមលេខនៃឯកសារដែលយើងចុះនៅលើឯកសារថតចម្លង គឺយើងបានប្រាប់ពីប្រភពនៃឯកសារដែលយើងអាចនឹងទៅស្វែងរកឯកសារថតចម្លងនេះនៅក្នុងឯកសារដើមបាន។

[១១:១១:៣៧]

**ស៖** ដូច្នេះនៅលើឯកសារថតចម្លង ដែលយើងអាចមើលបាន យើងអាចពិគ្រោះបាននៅពេលដែលយើងទៅមជ្ឈមណ្ឌលឯកសារកម្ពុជានោះ គឺយើងឃើញមានលេខផ្សេងៗគ្នា លេខចុះបញ្ជីផ្សេងៗគ្នានៅលើឯកសារតែមួយហ្នឹង។ តើលេខទាំងអស់ហ្នឹង យើងអាចកំណត់ដឹងបានថា តើលេខណាមួយប្រើដោយ ស៊ី.ឌី.ខេម ឬក៏លេខណាមួយប្រើដោយមូលដ្ឋានទិន្នន័យផ្សេងណាទៀតនោះ?

**ឆ៖** ចំពោះលេខឯកសារដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការចុះលេខ បានធ្វើការចងក្រងនឹងធ្វើការចុះលេខនេះ គឺមានលេខតែមួយគត់សម្រាប់ឯកសារមួយ។ យើងមិនមានចុះលេខឯកសារពីរនៅក្នុងឯកសារតែមួយទេ។ មានន័យថា យើងចុះលេខ១សម្រាប់ឯកសារមួយ និងបន្តបន្ទាប់ទៅទៅរកឯកសារផ្សេងៗទៀត ជាលំដាប់លំដោយ។

**ស៖** ក្រៅពីការចុះលេខនៅលើឯកសារ តើនៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជា តើមានការ--មានចំណារនៅលើឯកសារទាំងអស់ទេ? តើបុគ្គលិក ស៊ី.ឌី.ខេម ឬក៏អ្នកស្រាវជ្រាវគាត់ខ្លួនឯងផ្ទាល់គាត់ចារបន្ថែមនៅលើឯកសារទាំងអស់នុ៎ងដែរឬទេ?

[១១:១៣:៣៥]

**ឆ៖** ទាក់ទងនឹងរឿងចំណារនៅលើឯកសារ គឺមជ្ឈមណ្ឌលឯកសារកម្ពុជាមិនបានធ្វើចំណារទៅលើឯកសារណាមួយនោះទេ ក្រៅពីតែពីការចុះលេខទៅលើឯកសារថតចម្លង។

**ស៖** តើលោកមានធ្វើការស្រាវជ្រាវពាក់ព័ន្ធទៅនឹងចំណារដែលអាចមានទៅលើឯកសារមួយចំនួន ជាពិសេសស្រាវជ្រាវដើម្បីដឹងថាចំណារទាំងអស់នេះ គឺជាចំណារដែលធ្វើឡើងនៅពេលបង្កើតឡើងឯកសារ ឬក៏ចំណារដែលធ្វើឡើងនៅពេលក្រោយ។ តើលោកមានបានសិក្សាស្រាវជ្រាវ ឬក៏ពិនិត្យផ្ទៀងផ្ទាត់ទៅលើចំណុចទាំងអស់ហ្នឹងទេ? ហើយថាតើព័ត៌មានទាំងអស់នេះអាចទទួលបានដោយអ្នកស្រាវជ្រាវដែរឬទេ?

[១១:១៤:៤៣]

**ឆ៖** នៅពេលដែលទទួលបានឯកសារ គឺយើងបានពិនិត្យទៅលើឯកសារហ្នឹង។ យើងបានធ្វើការកត់សម្គាល់ទៅលើឯកសារ ថាតើឯកសារនេះមានចំណារ ឬក៏គ្មានចំណារ ឬក៏ចំណារអ្នកណាខ្លះ អ៊ីចឹងយើងបានធ្វើការពិនិត្យនិងផ្ទៀងផ្ទាត់ទៅលើឯកសារប្រភេទ បើសិនជាមានចំណារ។

**ស៖** នៅពេលដែលលោកស្រង់អត្ថិភាពនៃចំណារនោះ តើវា តើលោកមានសលាកប័ត្រមួយសម្រាប់ព័ត៌មាន សម្រាប់ឯកសារទាំងអស់ហ្នឹង ដើម្បីឲ្យយើងដឹងថា ដឹងពីប្រភពឯកសារ ហើយដឹងពីចំណារដែលគេបានធ្វើ ហើយដើម្បីឲ្យដឹងថា មជ្ឈមណ្ឌលឯកសារហ្នឹង បានធ្វើការវាយតម្លៃ ឬក៏ថាចំណារនៅសម័យនុំង ឬក៏ថាដើម្បីឲ្យយើងស្គាល់អ្នកនិពន្ធ ឬក៏ចំណារដែលបានធ្វើនៅពេលសម័យក្រោយនេះទេ?

**ឆ៖** ខ្ញុំបាទសូមបញ្ជាក់ឲ្យបានច្បាស់ត្រង់ចំណុចនេះ គឺថា បើសិនជាឯកសារដែលយើងទទួលបានមកមានចំណារនៅលើហ្នឹង គឺជាចំណារនៅលើឯកសារហ្នឹងតែម្តង។ គឺសម្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា យើងមិនបានធ្វើចំណារអ្វីទៅលើឯកសារក្រៅតែពីយើងបានថតចម្លងឯកសារ ហើយនិងចុះលេខឯកសារតែប៉ុណ្ណោះ។

[១១:១៦:៣៣]

**ស៖** យើងយល់ហើយថា មជ្ឈមណ្ឌលឯកសារនេះ គឺមិនធ្វើចំណារលើឯកសារទេ ក៏ប៉ុន្តែសំណួររបស់ខ្ញុំនោះ គឺវាខុសពីនេះបន្តិច គឺថា ព្រោះថាអ្វីដែលខ្ញុំចាប់អារម្មណ៍នោះ គឺថាតើមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការស្រង់ចំណារដែលមាននៅលើឯកសារ ហើយថាតើមជ្ឈមណ្ឌលនោះ បានសិក្សាអំពីចំណារនេះដែរឬទេ? ឬក៏គាត់អាចធ្វើការកំណត់ថាតើអ្នកនិពន្ធនោះឈ្មោះអី? ខ្ញុំគិតថា ហើយយើងនឹងត្រូវពិនិត្យឯកសារទាំងអស់នេះ លើកឧទាហរណ៍មួយឲ្យជាក់លាក់ និងអាចឲ្យយើងយល់អំពីខ្លឹមសាររបស់សំណួររបស់ខ្ញុំ។ ឧទាហរណ៍ យើងយកតេឡេក្រាមមួយ នៅលើតេឡេក្រាម តួរលេខហ្នឹងគឺថាមានចំណារ តើយើងស្រង់ចំណារហ្នឹង យើងសិក្សាចំណារហ្នឹង ឬក៏យើងចង់ថាកំណត់ថាអ្នកណាជាអ្នកនិពន្ធជាដើមនោះ?

**ឆ៖** ទាក់ទងនឹងបញ្ហាចំណារនេះ បើសិនជាខ្ញុំអាចមើលទៅលើឯកសារណាមួយជាក់លាក់ ប្រហែលជាខ្ញុំអាចពន្យល់បានទៅចៅក្រម ទៅលោកចៅក្រមបានច្បាស់ជាងនេះ ព្រោះឯកសារដែលទទួលបាន គឺជាការពិតគឺមានឯកសារខ្លះមានចំណារពីដើមមកនៅលើឯកសារហ្នឹងតែម្តង ឯកសារខ្លះ

ទៀតមិនមានចំណារក្រៅតែពីខ្លឹមសារពីអត្ថបទនៅលើឯកសារ។ ហើយបើសិនជាអាច គឺអាចខ្ញុំបាទស្នើសុំមើលឯកសារណាមួយ ដើម្បីខ្ញុំបាទនឹងធ្វើការពន្យល់ឲ្យបានច្បាស់លាស់ទៅលើឯកសារប្រភេទបែបយ៉ាងដូច្នេះ។

[១១:១៩:០១]

**ស៖** បាទនេះគឺជាសំណើមួយដែលគួរឲ្យចាប់អារម្មណ៍ អ៊ីចឹងខ្ញុំ ពេលក្រោយហ្នឹង គឺយើងនឹងបង្ហាញជូនលោកនូវឯកសារមួយចំនួន ដើម្បីយកធ្វើជាឧទាហរណ៍បញ្ជាក់ដើម្បីឲ្យលោកអាចបង្ហាញដល់យើងនូវគម្រុយមួយចំនួនទាក់ទងទៅនឹងចំណារផ្សេងៗ ដែលយើងឃើញនៅលើឯកសារទាំងអស់នេះ។ ប៉ុន្តែឥឡូវនេះ ខ្ញុំសូមបន្តការចោទសំណួររបស់លោកពេក ហើយយើងនឹងលើកបញ្ហានេះមកនិយាយនៅពេលក្រោយ។

ឥឡូវនេះ ខ្ញុំសូមឲ្យលោកធ្វើការបំភ្លឺទាក់ទងទៅនឹងប្រភពដែលមជ្ឈមណ្ឌលកម្ពុជាបានទទួលហើយនិងប្រភពដែលអាចឲ្យលោកប្រមូលសំណុំឯកសារទាំងអស់នេះ។ តើលោកអាចនិយាយជូនតុលាការអំពីប្រភពដែលមាននៅប្រទេសកម្ពុជាដែរឬទេ? តើប្រភពទាំងអស់នេះជាប្រភពអ្វីទៅ? ហើយតើលោកមានទំនាក់ទំនងអ្វីខ្លះដែលលោកមានជាមួយប្រភពទាំងអស់? ខ្ញុំលើកឧទាហរណ៍ ខ្ញុំគិតថាវាមានឯកសារមួយចំនួនដែលមកពីមន្ទីរស-២១ (គុកទួលស្លែង) ហើយនិងឯកសារមួយចំនួនដែលមកពីបណ្ណសារជាតិ ឬក៏បណ្ណសារផ្សេងៗទៀត។ តើលោកបញ្ជាក់ជូនអង្គជំនុំជម្រះ ឬក៏ថាផ្តល់ជាគំនិតមួយឧទាហរណ៍ទាក់ទងនឹងបណ្ណសារ ឬក៏ប្រភពដែលមជ្ឈមណ្ឌលកម្ពុជាមានទំនាក់ទំនង? ហើយតើទំនាក់ទំនងនោះវាយ៉ាងម៉េចខ្លះទៅ?

[១១:២១:០០]

**ឆ៖** បាទសូមអរគុណលោកចៅក្រម។ ទាក់ទងទៅនឹងការប្រមែប្រមូលឯកសារនេះ គឺមជ្ឈមណ្ឌលឯកសារកម្ពុជា៖ ទីមួយ គឺបានការអនុញ្ញាតដោយត្រឹមត្រូវពីរដ្ឋាភិបាលកម្ពុជានៅក្នុងចុះទៅធ្វើការសិក្សាស្រាវជ្រាវគ្រប់ទីកន្លែងទាំងអស់ទាំងក្នុងនិងក្រៅប្រទេស។ តាមរយៈលិខិតអនុញ្ញាតបែបនេះដែលធ្វើឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាអាចចុះធ្វើការស្រាវជ្រាវឯកសារគ្រប់ទីកន្លែងទាំងអស់។ ទីពីរមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការអំពាវនាវដល់ប្រទេសផ្សេងៗ ដែលអាចមានឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យនេះ ឲ្យធ្វើការផ្តល់ឯកសារទាំងអស់នេះមកមជ្ឈមណ្ឌលឯកសារកម្ពុជា ឬមកអង្គជំនុំជម្រះវិសាមញ្ញ។

នៅក្នុងការ-- ដោយសារបានមានការអនុញ្ញាតបែបនេះ គឺមជ្ឈមណ្ឌលឯកសារមានបានចុះទៅធ្វើការប្រមែប្រមូលឯកសារនេះ បានគ្រប់ទីកន្លែង គ្រប់ច្រកល្ហក មិនថានៅក្នុងស្ថាប័នរដ្ឋ មិនថានៅក្នុងស្ថាប័នឯកជន មិនថានៅទួលស្លែង ឬក៏នៅបណ្ណសារដ្ឋានជាតិនោះទេ។

ដូច្នេះឯកសារទាំងអស់នេះគឺមានប្រភពមកដូចខ្ញុំបានជម្រាបពីខាងដើម គឺថាមានប្រភពមកពីរដ្ឋាភិបាល មានមកពីស្ថាប័នឯកជន ហើយនិងបុគ្គលឯកជនមួយរូបៗហ្នឹងផងដែរ។

[១១:២២:៥៣]

**ស៖** ឥឡូវយើង ឧទាហរណ៍ លើកយកប្រភពរដ្ឋាភិបាល ដែលលោកបានលើកឡើងអម្បាញ់មិញនេះ ដែលជាប្រភពរបស់រដ្ឋ។ តើលោកបានទទួល គឺថាអាច ពិគ្រោះឯកសារហ្នឹងទាំងអស់តែម្តង ឬក៏គ្រាន់តែជាផ្នែកមួយទេ? ហើយផ្នែកថា មានជាឯកសារសម្ងាត់ តើលោកអាចរៀបរាប់អំពីបញ្ហានេះបានដែរឬទេ? ឧទាហរណ៍ថា លោកបានទទួលឯកសារទាំងអស់ដែលមាននៅក្នុងបណ្ណសារដ្ឋានជាតិ ឬក៏យ៉ាងណា?

[១១:២៣:៣០]

**ឆ៖** បាទ ដោយសារខ្ញុំទទួលការបកប្រែមិនសូវបានច្បាស់លាស់ ហើយខ្ញុំមិនសូវបានយល់ច្បាស់លាស់ពីសំណួរ។ ខ្ញុំសូមមេត្តាលោកចៅក្រមសួរម្តងទៀត ហើយខ្ញុំនឹងព្យាយាមផ្ទៀងការបកប្រែបាទ។

**ស៖** សំណួរខ្ញុំដូចតទៅនេះ លោកបាននិយាយថា លោកបានទទួលឯកសារដែលមកពីប្រភពផ្សេងៗ ឧទាហរណ៍ដូចជា ប្រភពនៃបណ្ណសារដ្ឋានរបស់រដ្ឋកម្ពុជា។ ខ្ញុំបានលើកឧទាហរណ៍មួយ គឺថាបណ្ណសារដ្ឋានជាតិ ខ្ញុំសួរសំណួរលោកដូចតទៅនេះ៖ តើលោកបានទទួលឯកសារទាំងអស់ដែលនៅក្នុងបណ្ណសារដ្ឋានជាតិនេះ ក៏មានឯកសារមួយផ្នែកដែលថាត្រូវចាត់ទុកជាឯកសារសម្ងាត់? តើមានឯកសារណាដែលថាលោកមិនទទួលបានទេ ឬក៏លោកមិនដឹងថា មានឯកសារណាដែលលោកបានមិនទទួលនោះទេ?

[១១:២៤:៥០]

**ឆ៖** ទាក់ទងទៅនឹងការចុះស្រាវជ្រាវឯកសារនៅបណ្ណសារដ្ឋានជាតិ គឺយើងបានប្រមែប្រមូលឯកសារ និងចងក្រងឯកសារនេះទៅតាមៗអាណត្តិរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាគឺមានន័យថាយើងប្រមែប្រមូលឯកសារអំពីរបបខ្មែរក្រហម ដែលពាក់ព័ន្ធនឹងរបបខ្មែរក្រហមរបបកម្ពុជាប្រជាធិបតេយ្យ។

**ស៖** ខ្ញុំយល់អំពីអ្វីដែលលោកនិយាយហើយ។ តើគេឲ្យលោកយកឯកសារដែលនៅក្នុងទូនោះ

ទាំងអស់ ឬក៏មានឯកសារដែលទាក់ទងសម័យខ្មែរនុំុង ដែលលោកមិនបានទទួលយកនោះ នេះជាសំណួររបស់ខ្ញុំ?

**ឆ៖** ដោយសារបណ្ណសារជាតិជាកន្លែងទុកដាក់ចងក្រងឯកសារមួយរបស់ជាតិ យើងបានត្រឹមតែថតចម្លងឯកសារដែលមាននៅបណ្ណសារដ្ឋានជាតិ ហើយយកមកធ្វើការចងក្រងទុកដាក់នៅមជ្ឈ-មណ្ឌលឯកសារកម្ពុជា ដើម្បីបម្រើដល់ការស្រាវជ្រាវ ការសិក្សារៀនសូត្រ។

[១១:២៦:២៦]

**ស៖** តើលោកអាចផ្ដល់បញ្ជីបណ្ណសារដ្ឋានជាតិកម្ពុជា ដែលលោកបានចូលពិគ្រោះដែរឬទេ? ឧទាហរណ៍ដូចថា តើលោកបានចូលពិគ្រោះនៅបណ្ណសារដ្ឋានរបស់ក្រសួងមហាផ្ទៃដែរឬទេ? ឬក៏លោកបានចូលពិគ្រោះនៅក្នុងបណ្ណសារដ្ឋាននៃក្រសួងការពារជាតិដែរឬទេ?

**ឆ៖** តាមរយៈលិខិតអនុញ្ញាតរបស់រាជរដ្ឋាភិបាលនេះឯងដែលយើងអាច មជ្ឈមណ្ឌលឯកសារកម្ពុជាអាចនឹងចុះទៅដល់ស្ថាប័នដែលយើងគិតថា ឯកសារប្រភេទ ឯកសារខ្មែរក្រហមអាចមាននៅតាមស្ថាប័នទាំងអស់នោះ។ ជាក់ស្ដែងដូចជា បណ្ណសារដ្ឋានជាតិ ដូចជានៅក្រសួងមហាផ្ទៃអីជាដើម។

**ស៖** តើឯកសារទាំងអស់ហ្នឹងត្រូវបានថតចម្លង ហើយនិងដាក់ឲ្យសាធារណជនអាចពិគ្រោះបាននៅមជ្ឈមណ្ឌលឯកសារកម្ពុជា ឬក៏មានតែឯកសារមួយផ្នែកទេដែលថតចម្លង។ តើមានការជ្រើសរើសឯកសារនេះដែរឬទេ? ហើយបើសិនជាមានតើលក្ខណៈវិនិច្ឆ័យនោះ យើងធ្វើរបៀបម៉េចដើម្បីធ្វើការជ្រើសរើសនោះ?

**ឆ៖** ជាក់ស្ដែងដូចជា ឯកសារដូចជានៅបណ្ណសារដ្ឋានជាតិ ក៏ដូចជានៅទួលស្លែង គឺមានការគ្រប់គ្រងឯកសារ មានការចងក្រងឯកសារច្បាស់លាស់និងត្រឹមត្រូវ មានស្ថាប័នមួយដែលថែរក្សាដែលចងក្រងឯកសារនោះច្បាស់លាស់រួចហើយ។ ដូច្នេះ មជ្ឈមណ្ឌលឯកសារកម្ពុជាមិនយកឯកសារទាំងអស់នោះមកទុកដាក់នៅមជ្ឈមណ្ឌលឯកសារកម្ពុជាទេ គឺយើង មជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើការថតចម្លង ដើម្បីយកមកប្រើប្រាស់នៅក្នុងការសិក្សាស្រាវជ្រាវ និងការសិក្សាផ្សេងៗទៀតដែលសាធា-រណជនអាចនឹងមានចំណាប់អារម្មណ៍នៅក្នុងការអាន នៅក្នុងការសិក្សាស្រាវជ្រាវ។ មានន័យថា យើងមិនបានយកឯកសារទាំងអស់នោះពីស្ថាប័នដូចជា បណ្ណសារដ្ឋានជាតិ ដូចជានៅទួលស្លែងនោះទេ ព្រោះនៅទីនោះគេមានការគ្រប់គ្រង ការចងក្រងច្បាស់លាស់នៅទីនោះរួចហើយ។

[១១:២៩:១០]

**ស៖** បាទសំណួរខ្ញុំនឹងខុសគ្នាពីហ្នឹងបន្តិច ខ្ញុំមិនបានសួរថា តើលោកបានយកឯកសារដើមនោះទេ ខ្ញុំសួរថា តើបើសិនជាលោកថតចម្លងនូវឯកសារទាក់ទងទៅនឹងសម័យកម្ពុជាប្រជាធិបតេយ្យនុ៎ង ឬក៏ទាំងអស់ ឬក៏តែមួយផ្នែកទេ? ដូចថា ឧទាហរណ៍គឺថា នៅបណ្ណសារដ្ឋានជាតិហ្នឹងបើកចំហដល់សាធារណជនថា យើងថា វាមិនចាំបាច់ក្នុងការថតយកឯកសារទាំងអស់នៅទីនោះទេ។ តើលោកអាចថាលោកថតចម្លងតែឯកសារណាដែលលោកគិតថា មានភាពពាក់ព័ន្ធសំខាន់សម្រាប់លោក។ អ៊ីចឹងសំណួរគឺថា តើលោកថតចម្លងឯកសារទាំងអស់នុ៎ង ឬក៏ថតតែមួយផ្នែកទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម ឲ្យតែឯកសារ បើនិយាយឲ្យខ្លីគឺថា ឲ្យតែឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យ និងពាក់ព័ន្ធទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យ គឺមជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើការប្រមែប្រមូលនិងថតចម្លង។

[១១:៣០:៣៩]

**ស៖** ក្រៅពីបណ្ណសារ ឬក៏បណ្ណសារដ្ឋានជាតិ ឬក៏ស្ថាប័នជាតិហ្នឹង តើលោកអាចពន្យល់ជូនតុលាការបានទេ ថាលោកទទួលបានប្រភពផ្សេងដែលនៅក្នុងប្រទេសកម្ពុជានេះដែរឬទេ? ឧទាហរណ៍មានបណ្ណសារដ្ឋានជាតិ-- បណ្ណសារដ្ឋានឯកជន ដែលថាកាន់កាប់ដោយឥស្សរជនសំខាន់ៗនៅប្រទេសកម្ពុជា ដែលថាចំពោះលោកហ្នឹងគឺថាជាប្រភពឯកសារសំខាន់។ ឧទាហរណ៍ដូចជា អ្នកសមាជិករដ្ឋាភិបាលមួយចំនួនដែលមានឯកសារទាំងអស់នោះ។ តើលោកបានពិគ្រោះឯកសារទាំងអស់នុ៎ងដែរឬទេ?

**ឆ៖** ទាក់ទងទៅនឹងបញ្ហានេះគឺថា រាល់ការចុះទៅស្រាវជ្រាវ មិនថាអ្នកនោះជាមន្ត្រីរដ្ឋាភិបាល ឬក៏ប្រជាជនសាមញ្ញនោះទេ ឲ្យតែគាត់មានឯកសារ គឺយើងអាចនឹងធ្វើការទំនាក់ទំនង ហើយនិងធ្វើការពិភាក្សា ហើយនិងធ្វើការប្រមែប្រមូលឯកសារនោះ បើសិនជាមានការយល់ព្រមឲ្យផ្តល់ឯកសារហ្នឹងមកទុកដាក់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា។ ហើយកន្លងមក គឺឯកសារទាំងអស់នេះ គឺមានយើងបានទទួលពីៗមន្ត្រីរដ្ឋាភិបាលដែរ ដូចជាឯកសារមួយចំនួនយើងបានមកពីឯកឧត្តម ស៊ូ ភិរិន្ទ ដែលកាលជំនាន់នោះលោកធ្វើអភិបាលខេត្ត នៅខេត្តតាកែវ នៅពេលដែលយើងចុះទៅធ្វើការការស្រាវជ្រាវនៅខេត្តតាកែវ គឺយើងបានទទួលឯកសារនោះឯងពីឯកឧត្តម ស៊ូ ភិរិន្ទ។ បាទនេះឧទាហរណ៍ជាក់ស្តែង។

[១១:៣២:៥១]

**ស៖** ប្រភពដែលឯកសារទាំងអស់នោះចេញមកនោះ តើមានការចុះបញ្ជីឧទាហរណ៍ថាតើមានឯកសារមួយដែលមកដល់មជ្ឈមណ្ឌលឯកសារកម្ពុជា យើងដឹងថា អ្នកណាដែលមកផ្តល់ៗជូនឲ្យមជ្ឈ-

មណ្ឌល ឬក៏ថាអ្នកណាអ្នកកាន់កាប់ហ្នឹង តើមានការផ្ទៀងផ្ទាត់លើម្ចាស់ឯកសារទាំងអស់នុ៎ងដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម គឺនេះជាកិច្ចការរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាតែម្តងនៅក្នុងការ នៅពេលដែលទទួលបានឯកសារមួយៗ គឺយើងធ្វើការផ្ទៀងផ្ទាត់ ធ្វើការសួរនាំអំពីប្រភពឯកសារ អំពីប្រវត្តិឯកសារទាំងអស់នោះ ដើម្បីទុក ចងក្រងទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា។

**ស៖** តើមានគេដាក់ជូនឯកសារដល់មជ្ឈមណ្ឌលឯកសារហ្នឹង ដែលជាឯកសារចម្លងដែរទេ? លោកធ្លាប់ទទួលឯកសារចម្លង ហើយលោកត្រូវបានគេចោទសំណួរដាក់ខ្លួនឯង ថាតើឯកសារដើមនោះនៅឯណា? ហើយមុននឹងទទួលឯកសារចម្លងហ្នឹង ហើយលោកធ្វើការផ្ទៀងផ្ទាត់ដើម្បីឲ្យច្បាស់ថាឯកសារចម្លងនេះដូចគ្នា សម ត្រឹមត្រូវដូចឯកសារដើមនោះ?

[១១:៣៤:៣៥]

**ឆ៖** ចំពោះការទទួលបាននូវឯកសារថតចម្លងដែលមិនមាន ដែលជាឯកសារថតចម្លង គឺយើងបានសួរនាំយ៉ាងច្បាស់លាស់ អំពីថាតើប្រភពឯកសារបានមកពីណា? ហើយឯកសារដើមយ៉ាងម៉េច? ប៉ុន្តែជាការទទួលចម្លើយមកគឺយើង អ្នកដែលផ្តល់ឲ្យយើងបាននិយាយថា ឯកសារមិនដឹងនៅកន្លែងណា ឬក៏អាចថានៅកន្លែងដទៃ។ ប៉ុន្តែខ្លួនមានតែឯកសារថតចម្លងនេះ។ អ៊ីចឹងយើងបានទទួលឯកសារថតចម្លងនេះតែប៉ុណ្ណឹង។ អ៊ីចឹងសម្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា ឯកសារថតចម្លងនេះគឺជាឯកសារតែមួយគត់ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាមាន ហើយយើងចាត់ទុកថាដូចជាឯកសារដើមយ៉ាងដូច្នេះដែរ។

**ស៖** បើខ្ញុំមិនច្រឡំនោះទេ លោកក៏បាននិយាយថា អាចមានកើតឡើងដែរ ដែលថាលោកទទួលឯកសារដោយថា លោកមិនដឹងថាឯកសារដើមនុ៎ងនៅកន្លែងណា តើពិតមែនដែរឬទេ? តើលោកខ្លួនឯងនោះបានធ្វើការវិភាគលើឯកសារហ្នឹង ហើយលោកចាត់ទុកថាឯកសារចម្លងនេះគួរឲ្យទុកចិត្តបាន ហើយដែលយើងអាចចាត់ទុកជាឯកសារដែលមានតម្លៃស្មើនឹងឯកសារដើម តើមែនដែរឬទេ?

[១១:៣៦:២១]

**ឆ៖** ឯកសារថតចម្លងប្រភេទនេះ យើងបាន។ដឹងអំពីប្រភពអ្នកដែលផ្តល់ឲ្យយើង ហើយបើសិនជាអង្គជំនុំជម្រះត្រូវការនូវអ្នកដែលផ្តល់នូវឯកសារប្រភេទបែបនេះ គឺចង់សំដៅទៅលើឯកសារដែលថតចម្លងនេះ គឺយើងអាចផ្តល់ជូនបាន។

**ស៖** ក្នុងចំណោមឯកសារ ប្រភពដែលមាននៅក្រៅប្រទេសកម្ពុជា គឺថាលោកបានទទួលឯកសារមួយចំនួនពីប្រភពក្រៅប្រទេសនោះ។ ឧទាហរណ៍ដូចថា កម្រងឯកសាររបស់ប្រទេសស៊ុយអែត តើ

លោកអាចនិយាយជូនអង្គតុលាការបានទេ ថាកម្រងឯកសារស៊ុយអែត នេះបានជូននូវ ស៊ី.ឌី.ខេម នៅពេលណា? ហើយដើមកំណើតនៃមជ្ឈមណ្ឌលឯកសារស៊ុយអែតនេះនៅឆ្នាំណា? ហើយឯកសារហ្នឹងមានឯកសារអីខ្លះ? គេផ្តល់ឯកសារដើម ឬក៏ឯកសារចម្លងអីមកមជ្ឈមណ្ឌលឯកសារកម្ពុជាដែរឬទេ? អីចឹង អាចរៀបរាប់អំពីបញ្ហានេះជូនអង្គតុលាការបានដែរឬទេ?

[១១:៣៧:៥៨]

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម ទាក់ទងទៅនឹងឯកសារដែលទទួលបានមកពីប្រទេសស៊ុយអែតនេះ គឺតាមរយៈការធ្វើការអំពាវនាវឲ្យដល់ប្រទេសទាំងឡាយ ឬក៏ឯកជនទាំងឡាយណាដែលមានឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យនេះផ្តល់មកមជ្ឈមណ្ឌលឯកសារកម្ពុជា ក៏ដូចជាផ្តល់មកអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ហើយឯកសារទាំងអស់នេះ គឺឯកសារស៊ុយអែតនេះ គឺយើងបានទទួលនៅក្នុងឆ្នាំ២០០៧ ហើយឯកសារនេះត្រូវបានដឹកជញ្ជូនមកមជ្ឈមណ្ឌលឯកសារកម្ពុជា គឺជាឯកសារដែល-- ជាឯកសារថតចម្លងមកមជ្ឈមណ្ឌលឯកសារកម្ពុជាបាទ។

**ស៖** តើលោកអាចជម្រាបជូនអង្គតុលាការពីរបី-- ដោយខ្លីថាតើនៅក្នុងកម្រងឯកសារស៊ុយអែតហ្នឹងមានឯកសារអីខ្លះ? ហើយកម្មវត្ថុនៃកម្រងឯកសារនុ៎ងជាអ្វី? ហើយអ្នកណាជាអ្នកបង្កើតកម្រងឯកសារទាំងអស់នុ៎ង?

**ឆ៖** ឯកសារស៊ុយអែតមាន ឯកសារខ្លះមានជាភាសាស៊ុយអែត ដែលយើងអត់ចេះភាសាហ្នឹង ហើយយើងអត់ដឹងថាឯកសារហ្នឹង-- មានន័យថា យើងបើសរសេរជាភាសាស៊ុយអែត យើងអត់ដឹងថាឯកសារហ្នឹងយ៉ាងម៉េច។ ប៉ុន្តែឯកសារនេះត្រូវបានផ្តល់មកមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយឯកសារខ្លះមានជាភាសាអង់គ្លេស យើងបានដឹង បានយល់បានអំពីថាតើឯកសារហ្នឹងនិយាយអំពីអ្វី។

[១១:៤០:០១]

**ស៖** តើអ្នកណាជាអ្នកបង្កើតកម្រងឯកសារស៊ុយអែតនេះ? តើជាមជ្ឈមណ្ឌលស្រាវ ឬអ្នកណាជាអ្នកបង្កើតកម្រងឯកសារហ្នឹង ហើយក្នុងបំណងអ្វី?

**ឆ៖** យើងមិនបានយល់ដឹងអំពីបំណងដែលម្ចាស់ឯកសារហ្នឹងធ្វើការចងក្រងនោះទេ ហើយខ្ញុំគិតថា អង្គជំនុំជម្រះអាចនឹងសាកសួរទៅម្ចាស់ដើមនៃអ្នកដែលចងក្រងឯកសារនោះវិញ។

**ស៖** ទាក់ទងទៅនឹងប្រភពកម្ពុជា វាហាក់ដូចជាមានបណ្តាសារមួយចំនួនដែលបានដាក់ជូនដោយសាលាចុងបូព៌ា ខ្ញុំគិតថា ប្រហែលដាក់ជូនដល់មជ្ឈមណ្ឌលឯកសារនេះ-- ដោយបណ្ណសារដ្ឋានជាតិ

ប្រទេសបារាំង។ ខ្ញុំគិតថាគឺជាសំណុំឯកសាររបស់សម្ដេច នរោត្ដម សីហនុ តើលោកដឹងពីឯកសារទាំងអស់នេះដែរឬទេ? តើលោកបានពិគ្រោះឯកសារទាំងអស់នេះទេ? ឬក៏លោកអាចបានធ្វើការកត់ចម្លងឯកសារទាំងអស់នេះដែរឬទេ?

[១១:៤១:៤០]

**ឆៈ** បាទ គ្រប់ឯកសារទាំងអស់ ចូលមកមជ្ឈមណ្ឌលឯកសារកម្ពុជា បើទោះបីជាខ្ញុំបាទផ្ទាល់ អ្នកទៅទទួលឯកសារ ឬក៏អ្នកផ្សេងៗទៀត ដែលទទួលឯកសារនេះគឺចុងក្រោយ គឺឯកសារនេះត្រូវបានធ្លាក់មកដៃខ្ញុំ ហើយខ្ញុំធ្វើការចងក្រង ធ្វើការចុះលេខ ធ្វើការកាតាឡុក និងថែរក្សាទុកដាក់នៅមជ្ឈ-មណ្ឌលឯកសារកម្ពុជា។

**សៈ** តើលោកដឹងថា ឯកសាររបស់សម្ដេច នរោត្ដម សីហនុ សព្វថ្ងៃនេះនៅឯណាដែរឬទេ?

**ឆៈ** ចំពោះឯកសាររបស់សម្ដេច សីហនុ លោកបានផ្សព្វផ្សាយនៅលើគេហទំព័ររបស់ព្រះអង្គ ហើយក្រោយមក គេហទំព័រនេះត្រូវបានផ្អាកទៅវិញ ហើយយើងបានដឹងអំពីការផ្សព្វផ្សាយនេះ នៅលើគេហទំព័ររបស់សម្ដេចព្រះ នរោត្ដម សីហនុ។

**សៈ** តើលោកបានពិគ្រោះឯកសារផ្សេងទៀត ឧទាហរណ៍ ដូចជា សំណុំឯកសាររបស់គណៈបក្សប្រជាជនកម្ពុជា?

**ឆៈ** ចំពោះឯកសារ-- ចំពោះ-- ដូចខ្ញុំបានជម្រាបពីខាងដើមថា មជ្ឈមណ្ឌលឯកសារកម្ពុជា ដោយទទួលបានការអនុញ្ញាតឱ្យចុះធ្វើការស្រាវជ្រាវពីរដ្ឋាភិបាល អ៊ីចឹងមជ្ឈមណ្ឌលឯកសារកម្ពុជាអាចមានលទ្ធភាពចុះទៅធ្វើការសិក្សាស្រាវជ្រាវគ្រប់ស្ថាប័ន គ្រប់ទីកន្លែងបានដោយសារមានការអនុញ្ញាតបែបនេះ។ អ៊ីចឹង មិនថាឯកសារនៅបណ្ណាល័យរបស់គណៈបក្សប្រជាជន ឬក៏គណៈបក្សផ្សេងណាទៀតនោះទេ ឱ្យតែគិតថាឯកសារនេះមាននៅកន្លែងណា យើងអាចនឹងចុះទៅស្រាវជ្រាវបាន។

[១១:៤៤:២៦]

**សៈ** តើលោកដឹងដែរឬទេថា អាជ្ញាធរវៀតណាមនៅក្នុងទសវត្សរ៍ឆ្នាំ៨០ បានធ្វើការស្រាវជ្រាវជាលក្ខណៈវិទ្យាសាស្ត្រ លក្ខណៈដូចថា លើការស៊ើបអង្កេតលើបទឧក្រិដ្ឋដែលមានកើតឡើងនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ។ តើលោកបានដឹង ឬក៏បានពិគ្រោះលើឯកសារទាំងអស់នេះដែរឬទេ?

**ឆៈ** បាទសូមអញ្ញាតឱ្យលោកចៅក្រមមេត្តាផ្តល់ជាសំណួរជាម្តងទៀត ខ្ញុំអត់មាន-- ខ្ញុំយល់មិនទាន់ច្បាស់អំពីសំណួររបស់លោកចៅក្រម។

[១១:៤៥:២៤]

**ស៖** សំណួររបស់ខ្ញុំអម្បាញ់មិញនេះ គឺថាតើលោកដឹងជាយថាហេតុនោះ ថាមានការស្រាវជ្រាវលើការស៊ើបអង្កេត លើបទឧក្រិដ្ឋតាមលក្ខណៈវិទ្យាសាស្ត្រ ដែលធ្វើដោយអាជ្ញាធរវៀតណាមពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ដែលកើតឡើងនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ។ តើលោកបានពិគ្រោះឯកសារដែលបានប្រមូលផ្តុំដោយអាជ្ញាធរវៀតណាម? ហើយនេះជាប្រភពដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលដែរឬទេ?

**ឆ៖** អរគុណលោកចៅក្រម។ តាមការយល់ដឹងរបស់ខ្ញុំ គឺថាវៀតណាមបានមកធ្វើជាជំនាញការនៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា នៅគ្រប់ទីកន្លែងទាំងអស់ រួមទាំងការរៀបចំ ចងក្រងឯកសារនេះថែមទៀតបាទ។ អ៊ីចឹង ឯកសារនេះអាចមានការជួយជ្រោមជ្រែងពីវៀតណាម ដើម្បីធ្វើការចងក្រងឯកសារទុកដាក់ឯកសារ ដូចជាក់ស្តែងមាននៅជួយនៅទួលស្លែង ដែលឯកសារនៅទួលស្លែងមានការជួយរៀបចំ ជួយរៀបចំទុកដាក់ដោយជំនាញការវៀតណាម។

[១១:៤៧:២៥]

**ស៖** តើមជ្ឈមណ្ឌលឯកសារកម្ពុជាបានពិគ្រោះសំណុំឯកសារ ដែលបានធ្វើដោយប្រទេសវៀតណាមដែរឬទេ? តើលោកបានទទួលឯកសារដែលចេញពីប្រភពវៀតណាមនេះដែរឬទេ?

**ឆ៖** មជ្ឈមណ្ឌលឯកសារកម្ពុជា ពិតជាបានទទួលឯកសារពី-- ឯកសារពីប្រទេសវៀតណាម ដែលនៅក្នុងនោះ មានឯកសាររូបថត ហើយនិងមានឯកសារជាកុន ខ្សែភាពយន្តឯកសារពីប្រទេសវៀតណាម។

**ស៖** តើមជ្ឈមណ្ឌលឯកសារកម្ពុជា បានពិគ្រោះបណ្ណសារផ្សេងទៀតនៅបរទេស ឧទាហរណ៍ដូចជានៅប្រទេសថៃ នៅសហរដ្ឋអាមេរិក នៅប្រទេសចិន នៅប្រទេសរុស្ស៊ី។ តើលោកបានទទួលឯកសារមួយពីប្រភពទាំងអស់នេះដែរឬទេ? ឬក៏លោកបានធ្វើការផ្តួចផ្តើមគំនិតខ្លួនឯង ដើម្បីទទួលយកនូវសំណុំឯកសារទាំងអស់នេះ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម គឺដូចបានជម្រាបពីខាងដើម គឺមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការអំពាវនាវដល់ប្រទេសផ្សេងៗដែលអាចមានឯកសារប្រភេទនេះ មានឯកសារពាក់ព័ន្ធទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យ ក៏ដូចជាអំពីរបបកម្ពុជាប្រជាធិបតេយ្យ ឱ្យធ្វើការផ្តល់ឯកសារទាំងអស់នេះមកមជ្ឈមណ្ឌលឯកសារកម្ពុជា ឬក៏មកអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ អ៊ីចឹង

មជ្ឈមណ្ឌលឯកសារកម្ពុជាមានការ ធ្វើការអំពាវនាវបែបនេះ។

**ស៖** ដោយជាក់ស្តែងហ្នឹង គឺថាការអំពាវនាវទាំងអស់នោះ បានចេញជាលទ្ធផលអ្វីដែរ លោកបានទទួលឯកសារទាំងអស់នោះពីបរទេស ឬក៏យ៉ាងណា?

**ឆ៖** បាទតាមការអំពាវនាវបែបនេះ ជាក់ស្តែងគឺបានទទួលឯកសារពីប្រទេសស៊ុយអែត ហើយយើងបានទទួលឯកសារពីបណ្ណសារផ្ទាល់ខ្លួន របស់សាស្ត្រាចារ្យ ឡូវ៉ា សាំមី។

[១១:៥០:០៦]

**ស៖** តើអ្នកស្រាវជ្រាវមួយចំនួនដែលធ្វើការជាឯកជន ដោយពុំមានទំនាក់ទំនងជាចាំបាច់ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជានោះ បានផ្តល់បណ្ណសារផ្ទាល់ខ្លួនរបស់គាត់មួយចំនួនដល់មជ្ឈមណ្ឌលហ្នឹងដែរឬទេ? ឧទាហរណ៍ដូចជារូបថត ឬក៏សំណុំឯកសារដែលថាពាក់ព័ន្ធទៅនឹងរដ្ឋកាលសម័យខ្មែរក្រហមនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម គឺដូចខ្ញុំបាទបានជម្រាបអម្បាញ់មិញអ៊ីចឹង គឺថាតាមរយៈការអំពាវនាវនេះ គឺយើងបានទទួលឯកសារពីបណ្ណសារផ្ទាល់ខ្លួនរបស់លោកសាស្ត្រាចារ្យ ឡូវ៉ា សាំមី។ សម្រាប់ជាបុគ្គល បាទខ្ញុំផ្ទាល់ខ្លួនឯង គឺបានទទួលឯកសារជារូបថតពីបុគ្គលផ្ទាល់ពី ជាបុគ្គលមកដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយយើងបានធ្វើការកត់ត្រានូវឈ្មោះ លេខទូរស័ព្ទអ្នកដែលបានផ្តល់ឯកសារមកដល់យើងខ្ញុំនៅមជ្ឈមណ្ឌលឯកសារកម្ពុជា។

[១១:៥១:៤២]

**ស៖** ឥឡូវនេះ តើលោក យើងនិយាយអំពីវិស័យផ្សេងទៀត តើលោកអាចជម្រាបជូនតុលាការបានទេអំពីតួនាទី ឬក៏របៀបដែលមជ្ឈមណ្ឌលកម្ពុជាសហការជាមួយនឹងអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា។ តើលោកអាចនិយាយអំពីទំនាក់ទំនងដែលមានជាមួយនឹងសហព្រះរាជអាជ្ញាជាដើម តើលោកអាចជម្រាបជូនអំពីបញ្ហានេះដែរឬទេ? តើថាទំនាក់ទំនងទាំងអស់នេះបានធ្វើចងភ្ជាប់ឡើងតាមរបៀបណាវាង ឌី.ស៊ី.ខេម ហើយនិងការិយាល័យសហព្រះរាជអាជ្ញានេះ?

**ឆ៖** សូមអរគុណលោកចៅក្រម។ បាទនៅក្នុងការងារនេះ គឺខ្ញុំបាទផ្ទាល់ដែលជាអ្នកទទួលបន្ទុកលើការងារឯកសារ គឺយើងបានធ្វើការផ្តល់ឯកសារមកអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតាមរយៈការស្នើសុំៗ ហើយយើងបានធ្វើការងារនេះជាមួយនឹង ស្ទើរគ្រប់អង្គភាពទាំងអស់នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មិនថាអង្គភាព-- ការិយាល័យសហព្រះរាជអាជ្ញា ការិយាល័យ

សហចៅក្រមស៊ើបអង្កេត ការិយាល័យគាំពារនិងការពារក្ដី ការិយាល័យចាត់ចែងការងារនៅអង្គជំនុំជម្រះក៏ដូចជាការិយាល័យគាំពារជនរងគ្រោះជាដើម។ អ៊ីចឹងរាល់ការធ្វើទំនាក់ទំនងនេះ ជាពិសេសផ្នែកឯកសារគឺមជ្ឈមណ្ឌលឯកសារកម្ពុជាផ្ដល់ជូនតាមការស្នើសុំរបស់ការិយាល័យមួយៗនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ នៅក្នុងផ្ដល់ជូននេះទៀតសោត គឺយើងបានបញ្ជាក់នូវការ-- នូវសេចក្ដីបញ្ជាក់នូវការផ្ដល់ជូន និងការទទួលនូវឯកសារទាំងអស់នេះ។

[១១:៥៤:២០]

**ស៖** ឯកសារមួយចំនួននៅក្នុងអ្វីដែលគេហៅថាសំណុំរឿងរបស់តុលាការ គឺជាឯកសារដែលយើងថត ដែលយើងស្កេន។ អ្វីដែលខ្ញុំចង់ដឹងនោះ គឺថានៅពេល នៅក្នុងក្របខ័ណ្ឌនៃទំនាក់ទំនងរបស់លោកជាមួយនឹងការិយាល័យសហព្រះរាជអាជ្ញា តើអ្នកណាអ្នកថតចម្លងឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជានេះ? តើជាបុគ្គលិករបស់មជ្ឈមណ្ឌលរបស់លោក ឬក៏ការងារដែលធ្វើដោយសហការគ្នា ឬក៏ជាការងារដែលធ្វើដោយផ្ទាល់មុខរបស់ការិយាល័យសហព្រះរាជអាជ្ញា។ តើដោយជាក់ស្ដែងនោះ តើការដាក់ឯកសារជូនដល់សហព្រះរាជអាជ្ញានេះធ្វើឡើងតាមរបៀបណា?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម គឺការងារនេះ គឺខ្ញុំបាទជាអ្នកទទួលបន្ទុកផ្ទាល់នៅក្នុងការទទួលនូវសំណើផ្សេងៗពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ នៅពេលបានសំណើស្នើសុំឯកសារ គឺខ្ញុំបាទមានក្រុមការងាររបស់ខ្ញុំ ធ្វើការងារនេះដោយផ្ទៀងផ្ទាត់ទៅលើសំណើសុំនេះ ជាមួយនឹងឯកសារដែលមាននៅមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយយើងយកឯកសារនេះចេញមកដើម្បីធ្វើការថតចម្លង ឬក៏ធ្វើការស្កេនតាមតម្រូវការ របស់សំណើសុំ។ ឧទាហរណ៍ បើសិនជាឯកសារនេះ ត្រូវបានស្នើសុំធ្វើការស្កេន គឺមជ្ឈមណ្ឌលឯកសារកម្ពុជានឹងធ្វើការស្កេនជូន ហើយម៉ាស៊ីនស្កេនដែលធ្វើការស្កេនឯកសារនេះ គឺយើងបានទទួលពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយពេលបច្ចុប្បន្ននេះ ត្រូវបានប្រគល់ជូនមកអង្គជំនុំជម្រះវិញហើយ។

[១១:៥៦:៥៤]

**ស៖** បើសិនជាខ្ញុំសង្ខេបទៅ គឺថាឯកសារមួយចំនួននោះ ដែលជាឯកសារចម្លងលើក្រដាសដែលថា ផ្ដល់ជូនមកតុលាការ ហើយពេលខ្លះជាឯកសារស្កេន។ តើលោកអាចបញ្ជាក់បានដែរ ឬទេថា តើឯកសារស្កេននេះជាឯកសារដែលជាស្កេនជាពណ៌ស-ខ្មៅ ឬស្កេនជាពណ៌?

**ឆ៖** រាល់ការប្រគល់ជូនឯកសារជូនមកអង្គជំនុំជម្រះ និយាយជារួមគឺការប្រគល់នីមួយៗតែង

តែមាននូវការៗបញ្ជាក់ជាលិខិតច្បាស់លាស់ថា តើឯកសារដែលប្រគល់ជូននេះត្រូវបានស្កេន ឬក៏ធ្វើការថតចម្លងចេញពីឯកសារបែបណា? ចេញពីឯកសារថតចម្លងដែរ ឬក៏ចេញពីឯកសារដើម ហើយជាទូទៅឯកសារដែលធ្វើការថតចម្លងនេះមិនមានជាពណ៌ទេ។ សម្រាប់ការស្កេន គឺបើសិនជាការស្កេននោះត្រូវបានស្នើសុំ ស្កេនជាពណ៌ គឺយើងអាចយើងនឹងធ្វើទៅតាមការស្នើសុំនោះ។

**ស៖** ខ្ញុំបាទនៅចាំថា មានឯកសារចម្លងស្កេននៃចម្លើយសារភាពនៅមន្ទីរស-២១ ហើយមានឯកសារមួយចំនួនបានបង្ហាញជូនតុលាការនៅក្នុងសំណុំរឿង០០១ផងដែរ។ តើលោកមានឯកសាររបស់មន្ទីរស-២១ ដែរឬទេ? តើមជ្ឈមណ្ឌលកម្ពុជាជាអ្នកកាន់កាប់ឯកសារទាំងអស់នេះ ឬក៏សារមន្ទីរទួលស្លែងជាអ្នកកាន់កាប់?

[១១:៥៩:០៦]

**ឆ៖** ត្រង់ចំណុចនេះ គឺខ្ញុំបាទសុំធ្វើការបញ្ជាក់ឲ្យបានច្បាស់លាស់។ ទាក់ទងទៅនឹងឯកសារចម្លើយសារភាពដែលអង្គជំនុំជម្រះបានធ្វើការស្កេន ហើយយកមកប្រើប្រាស់។ ចម្លើយសារភាពនេះមានចម្លើយសារភាពមួយ គឺនៅទួលស្លែង ដែលឯកសារចម្លើយសារភាពប្រភេទនេះ មិនមាននៅមជ្ឈមណ្ឌលឯកសារកម្ពុជាទេ។ មានឯកសារចម្លើយសារភាពផ្សេងទៀត ដែលមាននៅមជ្ឈមណ្ឌលឯកសារកម្ពុជា ប៉ុន្តែមិនមាននៅសារមន្ទីរទួលស្លែងទេ។

ខ្ញុំចាំបានថា នៅពេលដែលមន្ត្រីស៊ើបអង្កេតមកធ្វើការស្កេនឯកសារ គឺឯកសារនេះ ឯកសារចម្លើយសារភាពនេះត្រូវបាន ស្កេនជាពណ៌នៅមជ្ឈមណ្ឌលឯកសារកម្ពុជា។ ឯចំណែកឯកសារចម្លើយសារភាពដែលមាននៅទួលស្លែង តាមការយល់ដឹងរបស់ខ្ញុំ គឺថាមន្ត្រីស៊ើបអង្កេតនឹងទៅធ្វើការស្កេននៅសារមន្ទីរទួលស្លែង។ ចំណែកឯចម្លើយសារភាពណាដែលមាននៅមជ្ឈមណ្ឌលឯកសារកម្ពុជា គឺមន្ត្រីស៊ើបអង្កេតនឹងធ្វើការស្កេនចម្លើយសារភាពនៅមជ្ឈមបណ្ឌលឯកសារកម្ពុជា។

**ស៖** អ៊ីចឹងលោកបញ្ជាក់ថា លោកបានទទួលសំណើពីការិយាល័យសហព្រះរាជអាជ្ញា ការិយាល័យសហចៅក្រមស៊ើបអង្កេត តើលោកបានទទួលសំណើផ្សេងៗទៀតអំពីការិយាល័យផ្សេងទៀតនៃ អ.វ.ត.ក ដែរឬទេ? ឧទាហរណ៍ដូចជា សំណើពីការិយាល័យគាំពារជនរងគ្រោះ ឬក៏ការិយាល័យការពារក្តី តើលោកបានទទួលដែរឬទេ?

**ឆ៖** ជាការត្រឹមត្រូវ គឺខ្ញុំបាទទទួលនូវសំណើពីអង្គភាពគាំពារការពារក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញក៏ដូចជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណី គឺថាឯកសារទាំងអស់នេះ គឺផ្តល់ជូនតាមការស្នើសុំ ហើយ

ប្រសិនបើចាំបាច់ ខ្ញុំអាចនឹងផ្តល់ជូនជាតួរលេខបាន ថាតើមជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្តល់ឯកសារប៉ុន្មានដល់អង្គភាពការពារក្តី។ ហើយមជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកទូលាយ បានផ្តល់ជាការិយាល័យធ្វើការងារទៀតសម្រាប់អង្គភាពការពារក្តី ប្រសិនបើអង្គភាពនេះបានបញ្ជូនក្រុមមេធាវី ឬក៏មន្ត្រីចុះទៅធ្វើការស៊ើបអង្កេតផ្ទាល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា។ ហើយមជ្ឈមណ្ឌលឯកសារកម្ពុជាបានទុកមួយថ្ងៃ គឺថ្ងៃសុក្រសម្រាប់អង្គភាពនេះទៅធ្វើការសិក្សាស្រាវជ្រាវ ព្រោះជាកន្លែងធ្វើការងារហ្នឹងតែម្តង ដើម្បីសម្រួលដល់កិច្ចការងារនេះ។

**ប្រធានអង្គជំនុំ៖**

អរគុណលោក ដារ៉ាពៅ ឥឡូវនេះពេលវេលាសមល្មមនឹងឈប់សម្រាក ដើម្បីពិសារអាហារថ្ងៃត្រង់ហើយ។ ដូច្នេះ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ ហើយមន្ត្រីច្បាប់សម្របសម្រួលដល់សាក្សីរូបនេះ ដើម្បីឲ្យគាត់មានលទ្ធភាពអាចចូលមកកាន់បន្ទប់សវនាការ គឺកន្លែងផ្តល់សក្ខីកម្មនេះឲ្យបានមុនម៉ោងអង្គជំនុំជម្រះចូលកាន់អាសនៈបល្លិច។

សូមអញ្ជើញមេធាវី!

[១២:០៣:២៦]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ គ្រាន់តែខ្ញុំសួរដោយខ្លីមួយ ពាក់ព័ន្ធទៅនឹងព្រឹកមិញ។ ព្រឹកមិញនេះគឺចៅក្រម ខាតវ៉ាយថ៍ គឺសុំឲ្យខ្ញុំក្រោកឈរឡើង នៅពេលដែលគាត់លើកយោបល់ឡើង។ នេះជាលើកទីមួយហើយ ដែលលោកស្រីសុំឲ្យខ្ញុំធ្វើដូច្នេះ។

ខ្ញុំក៏ចាំដែរ លោក កាណាវាស ក៏ធ្លាប់ម្តងដែរ គឺឲ្យសូមឲ្យគាត់អង្គុយចុះនៅក្នុងតុលាការ។ មេធាវីសហសេវីករបស់ខ្ញុំប្រាប់ខ្ញុំពេលឈប់សម្រាកថា វាមិនជាការអនុវត្តជារួមនៅក្នុងប្រទេសកម្ពុជាទេ ដែលថាឲ្យមេធាវីក្រោកឈរឡើង។ មានតែជនជាប់ចោទតែប៉ុណ្ណោះ ដែលត្រូវបង្គាប់ឲ្យក្រោកឈរឡើង។

ខ្ញុំសូមការបង្គាប់ពីអង្គជំនុំជម្រះ អំពីការអនុវត្តនៅក្នុងតុលាការជាតិប្រទេសកម្ពុជា ថាតើខ្ញុំត្រូវតែក្រោកឈរឡើងនៅពេលដែលខ្ញុំឡើងកំណត់សម្គាល់របស់ខ្ញុំនេះ នៅចំពោះមុខចៅក្រម ឬក៏យ៉ាងម៉េច? ឬក៏ការអនុវត្តបែបនេះ អនុវត្តតែចំពោះមេធាវីអន្តរជាតិ ដូចដែលលោកចៅក្រម ខាតវ៉ាយថ៍

លើកឡើង ដែលគាត់បង្គាប់តែចំពោះខ្ញុំ។ ដូច្នេះ ខ្ញុំសូមឲ្យមានការបង្គាប់និងបញ្ជាក់ឲ្យបានច្បាស់លាស់ទៅលើចំណុចហ្នឹង។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី ដែលបានធ្វើការបញ្ជាក់អំពីបញ្ហានេះ។ អង្គជំនុំជម្រះនឹងឆ្លើយតបទៅនឹងបំណងរបស់លោកនៅរសៀលនេះ មុនពេលចាប់ផ្តើមកិច្ចដំណើរការសវនាការ សួរស្តាប់សក្ខីកម្មសាក្សី។

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោម ហើយនិងឲ្យនាំខ្លួនគាត់មកកាន់បន្ទប់សវនាការនេះ នៅរសៀលនេះឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង១២:០៥នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:៤៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មុននឹងផ្តល់វេទិកាទៅលោកចៅក្រមហ្សង់ម៉ាក អង្គជំនុំជម្រះសូមជម្រាបដល់ភាគីនៃរឿងក្តីបានជ្រាបថា នៅគ្រប់ពេលវេលាដែលភាគីនិយាយមកកាន់អង្គជំនុំជម្រះ ឬក៏អង្គជំនុំជម្រះនិយាយទៅកាន់មេធាវីជាក់លាក់ណាមួយ គឺមេធាវី ឬក៏ភាគីនៃរឿងក្តីនោះត្រូវក្រោកឈរ ដើម្បីបង្ហាញអំពីការគោរពដល់អង្គជំនុំជម្រះ ក៏ដូចជាការអនុវត្តល្អនូវក្រមសីលធម៌វិជ្ជាជីវៈ ហើយដោយឡែកមេធាវីដែលអះអាងថា ការអនុវត្តនៅកម្ពុជាមិនដូច្នោះគឺមិនពិតទេ គឺការអនុវត្តនៅកម្ពុជា គឺគ្រប់ពេល និយាយមកកាន់អង្គជំនុំជម្រះ ឬក៏អង្គជំនុំជម្រះនិយាយទៅកាន់គោលដៅណាមួយ គឺគោលដៅនោះអង្គជំនុំជម្រះបង្គាប់ឲ្យឈរជាមុនទើបនិយាយទៅកាន់គោលដៅនោះជាក្រោយ។

អង្គជំនុំជម្រះសង្ឃឹមថា ភាគីពាក់ព័ន្ធនឹងរឿងក្តីនេះនឹងអនុវត្តឲ្យបានល្អ ដោយឡែកគោលដៅណាមួយដែលអង្គជំនុំជម្រះអនុញ្ញាតឲ្យអង្គុយនិយាយ គឺជាលក្ខណៈពិសេសដោយសារមូលហេតុវ័យចាស់ ដូចជាជនជាប់ចោទជាដើម ឬក៏ដោយសារមូលហេតុនៃអំឡុងពេលឆ្លើយតបទៅនឹងសំណួរ

ផ្សេងៗមានរយៈពេលវែង ដូចជាការអនុវត្តចំពោះអ្នកជំនាញ សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីជាដើម។ ក្នុងករណីដោយឡែកផ្សេងទៀត ធ្វើខុសពីនេះលុះត្រាតែមានការអនុញ្ញាតជាពិសេសពីអង្គជំនុំជម្រះ ដូចជាករណី ការអនុញ្ញាតឲ្យសួរដេញដោលចំពោះសាក្សី ឡុង នរិន្ទ អីជាដើម។ នោះជាការអនុវត្ត-- ការអនុញ្ញាតជាពិសេសតែប៉ុណ្ណោះ។

[១៣:៣៥:១០]

ជាកិច្ចបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាទៅលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីបន្តសំណួរសួរទៅដល់សាក្សី ដាវ៉ាពៅ សូមអញ្ជើញលោកចៅក្រម!

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំចង់ចំណាយពេលវេលាមួយចំនួនដើម្បីសួរសំណួរទៅកាន់សាក្សីពាក់ព័ន្ធទៅនឹងឯកសារជាក់លាក់មួយ គឺជាចម្លើយសារភាពដែលទទួលបាននៅមន្ទីរស-២១ ខ្ញុំអាច-- ខ្ញុំបញ្ជាក់ថា ឯកសារពាក់ព័ន្ធផ្សេងទៀតអាចបង្ហាញជូនសាក្សី ដោយអង្គជំនុំជម្រះនៅថ្ងៃស្អែក គឺអាចជាសារទូរលេខដែលមាននូវចម្លើយសារភាព។ ប៉ុន្តែនៅពេលនេះ គឺខ្ញុំយោងទៅលើឯកសារតែមួយទេ ឯកសារនេះមានលេខ D43/4ជាលេខ រ៉ូម៉ាំង ហើយ*អាណិច* 57 លេខ ERNជាភាសាបារាំង 00234668 ជាភាសាអង់គ្លេស 00224085 ទៅដល់00224086 ERN ជាភាសាខ្មែរ 00174375 ទៅដល់ 00174391។

[១៣:៣៧:១៨]

សូមបញ្ជាក់ខ្លះៗពាក់ព័ន្ធទៅនឹងឯកសារនេះ នេះគឺជាឯកសារដែលបានដាក់បញ្ចូលទៅក្នុងសំណុំរឿងដោយសហចៅក្រមស៊ើបអង្កេត ក្រោយពីការ ក្រោយពីបញ្ចប់ដីកាចាត់ឲ្យស៊ើបសួរជំនួសដែលបានចេញជូនអ្នកអង្កេត ស្ទីវ ហេដឌ័រ ហើយនិង ស៊ឹម សុរិយ៉ា។ អ្នកស៊ើបអង្កេតទាំងពីរនេះបានទៅមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីធ្វើការស្កេនជាពណ៌ធម្មជាតិជាឯកសារដើម ដែលរក្សាទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា។ ដូច្នេះ ខ្ញុំសូមសួរទៅខាងក្រឡាបញ្ជី តើអាចបញ្ចាំងឯកសារនេះនៅលើអេក្រង់បានទេ គឺទំព័រក្របមុខនៃឯកសារនេះ?

ដូច្នេះ គុណភាពនៃឯកសារនេះ គឺយើងអាចមើលល្អ។

**ស៖** លោកសាក្សី តើលោកអាចអានឯកសារនេះបានទេ គឺនៅក្នុង-- នៅមុខអេក្រង់នៅចំពោះមុខលោកនេះ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម ខ្ញុំអាចអានបាន។

[១៣:៣៩:៤២]

**ស៖** បាទ នេះគឺជាទំព័រក្របមុខ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះថាតើលោកស្គាល់ឯកសារនេះទេ? ហើយតើមានការអត្ថាធិប្បាយអីទៅលើឯកសារនេះទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម ឯកសារនេះ ខ្ញុំបាទស្គាល់ ហើយជាឯកសារចម្លើយសារភាពដែលយើងដឹងថា ជាឯកសារដែលស្ថិតនៅក្នុងឯកសាររបស់ក្រសួងការពារជាតិ កម្ពុជាប្រជាធិបតេយ្យ ដែលជំនាន់នោះគឺទទួលខុសត្រូវដោយ សុន សេន ហើយឯកសារនេះគឺមាននៅមជ្ឈមណ្ឌលឯកសារកម្ពុជា ជាច្បាប់ដើម ហើយជាឯកសារប្រភេទឯកសារ "J"។ ប៉ុន្តែនៅពេលដែលលោក ស្ទីវ ហេដឌ័រ ទៅស្កេនដោយសារការស្កេននេះ ស្កេនចេញពីឯកសារដើម អ៊ីចឹងឯកសារដែលមើលឃើញថាជាអក្សរ "J" នៅលើឯកសារចម្លើយសារភាពនេះ គឺអត់មានទេ ព្រោះឯកសារនៅលើចម្លើយសារភាពថតចម្លង ទើបយើងមានចុះជាលេខឯកសារ ដែលផ្ដើមដោយអក្សរ "J"។

[១៣:៤១:១៩]

**ស៖** ប្រសិនបើវាមិនមែនជា ឯកសារស្កេន ដែលបានដាក់ចូលទៅក្នុងសំណុំរឿងនោះទេ ប៉ុន្តែវាគ្រាន់តែជាឯកសារថតចម្លងជាក្រដាស យើងនឹងឃើញលេខដែលចាប់ផ្ដើមដោយអក្សរ "J" ដែលជាលេខចុះបញ្ជីនៃឯកសារ ឌី.ស៊ី.ខេម តើមែនទេ?

**ឆ៖** ជាការត្រឹមត្រូវលោកចៅក្រម។

**ស៖** ដូចលោកបានបញ្ជាក់អ៊ីចឹង គឺថាមានចំណារជាច្រើននៅលើឯកសារនេះ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ ថាហេតុអីបានជាយើងអាចចាត់ទុកថា ចំណារហ្នឹងគឺជាចំណារដែលចារនៅពេលដែលកើតឯកសារហ្នឹងតែម្ដង?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម នៅក្នុងឯកសារមួយនេះ បើយើងមើលទៅលើចំណារនេះគឺថា ទឹកប៊ិចដែលប្រើប្រាស់នៅលើចំណារនេះ គឺវាមានលក្ខណៈយូរហើយ ដែលមិនមែនជាទឹកប៊ិកមួយដែលយើងអាចមើលទៅថា ឃើញថាអាចសរសេរដោយថ្មីៗ។ ទីពីរ ចំណារខ្លះទៀតសោត គឺមានបញ្ជាក់ឈ្មោះ អ្នកធ្វើចំណារនេះនៅលើឯកសារ ប៉ុន្តែនៅលើឯកសារនេះ គឺអត់មានឃើញជាឈ្មោះអ្នកដែលធ្វើចំណារលើឯកសារនេះទេ។ ប៉ុន្តែតាមបទពិសោធន៍ តាមការកត់សម្គាល់ តាមការអានឯកសារច្រើន ខ្ញុំបាទ តាមការកត់សម្គាល់គឺថា អក្សរនេះអាចជាអក្សររបស់ សុន សេន។

[១៣:៤៣:៤២]

**ស៖** នៅលើឯកសារនេះ យើងឃើញចំណងជើង គឺសរសេរវៃជាដាក់ទីឡូ វៃជាអង្គុលីលេខ ហើយយើងឃើញមានចំណារជាច្រើន ដែលថាមិនមែនជាអក្សររបស់មនុស្សតែម្នាក់។ ដូច្នេះចំណារដែលលោកបាននិយាយនេះ គឺសរសេរដោយផ្ទាល់ដៃរបស់ សុន សេន បើសិនជាខ្ញុំយល់ស្តាប់ច្បាស់នោះ។ តើលោកយោងទៅលើចំណារមួយណា ព្រោះក្នុងនេះមានចំណារច្រើន?

**ឆ៖** ខ្ញុំមានឯកសារមួយនៅមុខខ្ញុំនេះ នៅលើអេក្រង់កុំព្យូទ័រខាងស្តាំដៃរបស់ខ្ញុំ ហើយឯកសារមួយនេះ គឺមានចំណារពណ៌រាងក្រហម ហើយសន្លឹកក្រដាសពណ៌រាងក្រហម ដោយភាពចំណាស់របស់វា។ បើសិនជាអាច ខ្ញុំអាចអានអក្សរនៅលើឯកសារនេះ ដើម្បីលោកចៅក្រមអាចផ្ទៀងផ្ទាត់ថាតើឯកសារមួយណាដែលខ្ញុំបានមើល។

[១៣:៤៥:១៤]

**ស៖** អ្វីដែលសំខាន់នេះ ខ្ញុំគិតថាយើងអាចដាក់ឲ្យអេក្រង់នោះ-- ដាក់ឯកសារនោះនៅក្នុងអេក្រង់ដដែលកុំអាលបិទ។ ខ្ញុំឃើញអក្សរជាច្រើនពណ៌ក្រហម តើលោកចង់និយាយដល់អក្សរពណ៌ក្រហមមួយណាខ្លះទៅ?

**ឆ៖** អក្សរពណ៌ក្រហមមាននៅខាងលើនៃចំណងជើងឯកសារ ដែលសរសេរអក្សរធំៗជាងអក្សរពណ៌ក្រហម ដែលសរសេរនៅខាងក្រោមចំណងជើងឯកសារ ជាអក្សរពណ៌ក្រហមដែរ តែតូចជាងអក្សរខាងលើ។

**ស៖** តើលោកអាចអានចំណារអស់នេះបានទេ?

**ឆ៖** បាទ ខ្ញុំព្យាយាមអានចំណារនេះ "ឌឹម អនុកងពលសមមិត្ត នុត"។

**ស៖** ខ្ញុំឮអម្បាញ់មិញនេះ ថា ឌឹម របស់សមមិត្ត មុត។ តើលោកអាចអានម្តងទៀតបានទេ? ពីព្រោះខ្ញុំគិតថា ការបកប្រែដូចជាមិនបានពេញលេញ ហើយសូមអានចំណារនៅខាងក្រោមផង។

**ឆ៖** ខ្ញុំបាទអានម្តងទៀត "ឌឹម អនុកងពលសមមិត្ត នុត" នៅចំណារខាងក្រោមពណ៌ក្រហមដែលអក្សរតូចជាងចំណារខាងលើពណ៌ក្រហមដែរហ្នឹង គឺមានសរសេរ៖ "១-- ក្នុងវង់រង្វង់មូល ជូនបងជាព័ត៌មាន អំពីផែនការគឺត្រូវហើយ ឯមនុស្សខ្លះគឺខ្ញុំ--" បាទ អក្សរកន្លែងនេះ មិនជាច្បាស់ប៉ុន្មានទេនៅពេលស្កេនទៅ។

[១៣:៤៩:០៣]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ដើម្បីជួយសម្រួលដល់ការអាន តើយើងអាចផ្ដល់ជាឯកសារក្រដាសជូនទៅសាក្សីបានទេ?

[១៣:៤៩:៤៩]

**លោក វ៉ាន់ថាន់ ដារ៉ាពៅ៖**

**ឆ៖** ខ្ញុំបាទសូមអានម្ដងទៀត នូវចំណារចុងក្រោយនៅខាងក្រោម ដែលអក្សរតូចៗ៖ "ជូនបង ជាព័ត៌មាន អំពីផែនការគឺត្រូវហើយ ឯមនុស្សខ្លះគឺត្រូវ តែខ្លះតាមខ្ញុំស្គាល់ដូចមិនសមទេ។ ខ្ញុំនឹងអញ្ជើញ សមមិត្ត មុត មក-- សមមិត្ត មុត មកពិនិត្យជាមូលដ្ឋាន។ អានេះឆ្លើយកំបាំងឯងខ្លួនឯងខ្លះមិនខាន។ ពីរ វាឆ្លើយដាក់អាទុំនៅឯកសារមុន បងប្អូនកំពុងចម្លងចេញពីខ្សែអាត់"។

**ស៖** តើលោកអាចធ្វើការអត្ថាធិប្បាយជូនអង្គជំនុំជម្រះទៅលើចំណារនេះបានទេ? តើវា សរសេរចេញពីដៃមនុស្សតែមួយ ហើយលោកស្គាល់អ្នកដែលប្រហែលជាសរសេរចំណារនេះដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម ដោយសារខ្ញុំបាន ជាពិសោធន៍ការងារ ហើយជាការ អង្កេតរបស់ខ្ញុំបាទដែលជាអ្នកចងក្រងឯកសារនេះ គឺចំណារនេះគឺជាចំណារដែលសរសេរដោយមនុស្ស តែម្នាក់ទេ ហើយតាមការចំណាំជាតួអក្សរដែលខ្ញុំបានឃើញនៅក្នុងឯកសារផ្សេងទៀតដែលមានចុះ ហត្ថលេខា និងឈ្មោះហ្នឹង គឺថាការចំណារនេះគឺជាចំណាររបស់ សុន សេន។

**ស៖** ខ្ញុំចង់ឲ្យយើងបង្ហាញទៅអេក្រង់នៅទំព័រដែលមានលេខ ERN ជាភាសាខ្មែរ00174384។

បើអ៊ីចឹងខ្ញុំសូមគិតឲ្យយើងផ្ដល់ឯកសារក្រដាសទៅគាត់ផងដែរ តើលោកអាចធ្វើអត្ថាធិប្បាយ ទៅលើទំព័រនេះបានទេ? តើលោកអាចអានចំណារនេះបានទេ?

[១៣:៥៥:១៦]

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម ខ្ញុំអាចអានចំណារនេះបាន ហើយចំណារនេះ គឺជា ចំណារដែលមាននៅលើឯកសារដើមតែម្ដង ហើយមានពណ៌ក្រហមដូចចំណារទៅលើឯកសារមុន ហើយតាមការកត់សម្គាល់របស់ខ្ញុំ ដែលខ្ញុំបានអានឯកសារនេះផ្ទាល់ផងដែរនៅមជ្ឈមណ្ឌលឯកសារ កម្ពុជា គឺចំណារនេះ គឺចំណាររបស់ ខៀវ ដែលមានដាក់នៅខាងក្រោម ដែលជាអ្នកសរសេរចំណារ នេះ។ ហើយចំណារនេះ គឺជាចំណារមួយដែលមានលក្ខណៈដូចគ្នាបេះបិទទាំងទម្រង់អក្សរ ទាំងអក្សរ គឺដូចគ្នាទៅនឹងឯកសារមុនដែលបង្ហាញដោយលោកចៅក្រម។ ហើយឯកសារក្រោយនេះ ខ្ញុំអាចអាន បាន ដូចជាពាក្យអក្សរពណ៌ក្រហម ដាក់ថា៖ "ស" ហើយគូសរង្វង់បួនជ្រុង ហើយបន្តទៅទៀតដាក់

ពាក្យថា "សម្ងាត់ណាស់" ហើយគូសបន្ទាត់ពីក្រោម។ បន្តមកទៀត គឺមានសរសេរថា "សម្គាល់ ឯកសារនេះសម្ងាត់ ព្រោះមានទាក់ទិនខាងបូព៌ា។ មិនអាចជូនទៅមូលដ្ឋានបានទេ។ ទាល់តែដកស្រង់។ ៣១/៧/៧៧ ខៀវ" ហើយគូសបន្ទាត់ពីក្រោម។

[១៣:៥៧:២៤]

**ស៖** តើការប្រើប្រាស់ពណ៌ក្រហម តើវាមានពាក់ព័ន្ធទៅនឹងអីពិសេសទេ? ពីព្រោះថាយើងតែងតែឃើញមានអក្សរពណ៌ក្រហមចំពោះការចំណារនេះ។ តើវាមានន័យអីពិសេសទេ អក្សរពណ៌ក្រហមនេះ?

**ឆ៖** ចំពោះការកត់សម្គាល់របស់ខ្ញុំក៏ដូចជាការកត់សម្គាល់របស់លោកចៅក្រមដែរ គឺថាចំណារមានពណ៌ក្រហមអីចឹងមែន ហើយខ្ញុំមិនអាចនឹងធ្វើអត្ថាធិប្បាយបានទេ ថាតើហេតុអីបានជាចំណារពណ៌ក្រហម ឬក៏ហេតុអីបានជាចំណារនេះចារពណ៌ខៀវ ឬពណ៌ខ្មៅ ខ្ញុំមិនអាចធ្វើអត្ថាធិប្បាយបានទេ។

**ស៖** សំណួរចុងក្រោយ។ លោកបាននិយាយថា ឈ្មោះ ខៀវ គឺមាននៅខាងក្រោមនៃទំព័រនេះ ប្រសិនបើលោកដឹង តើអាចជម្រាបជូនអង្គជំនុំជម្រះបានទេថា តើឈ្មោះ ខៀវ ហ្នឹងជាអ្នកណាដែរ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម ខៀវ នេះគឺជាឈ្មោះហៅក្រៅរបស់ សុន សេន។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំសូមអរគុណលោក ពៅដារ៉ា ហើយខ្ញុំគ្មានសំណួរអីនឹងសួរទៅកាន់សាក្សីទៀតទេ ហើយថ្ងៃស្អែកប្រសិនបើយើងទទួលបានសារទូរលេខនោះយើងនឹងផ្តល់ជូនលោក ហើយដើម្បីសួរឲ្យលោកបំភ្លឺអំពីចំណារនេះ។

លោកប្រធានខ្ញុំអស់សំណួរហើយ។

[១៣:៥៩:២៣]

**ប្រធានអង្គជំនុំ៖**

អរគុណលោកចៅក្រម តើអស់លោក លោកស្រីចៅក្រមមានសំណួរអ្វីចង់សួរសាក្សីរូបនេះទៀតដែរ ឬទេ?

បាទ បើមិនមានទេ អង្គជំនុំជម្រះសូមផ្តល់វេទិកាទៅសហព្រះរាជអាជ្ញា ដើម្បីមានឱកាសនៅក្នុងការតាំងសំណួរចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

[១៤:០០:០០]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ សួស្តីលោក លោកស្រីចៅក្រម សួស្តីលោក ដារ៉ាពៅ។ សូមអរគុណដែលលោកមកទីនេះ ដើម្បីផ្តល់សក្ខីកម្ម ផ្តល់ជាព័ត៌មានដល់អង្គជំនុំជម្រះ ដើម្បីស្វែងរកការពិត ជាពិសេសពាក់ព័ន្ធទៅនឹងការគ្រប់គ្រងឯកសារនៅ ឌី.ស៊ី.ខេម។

យើងខ្ញុំនឹងព្យាយាម ហើយនិងបង្កើតការពិនិត្យទៅលើភស្តុតាង ដូចដែលបន្តពីចៅក្រម។ ដូច្នេះហើយសូមអធ្យាស្រ័យដល់ខ្ញុំ ប្រសិនបើនៅក្នុងចំណុចមួយចំនួន គឺខ្ញុំសួរទៅលើចំណុចដែលលោកបានសួររួច ត្រូវបានសួររួចមកហើយ។ ដូច្នេះខ្ញុំ សំណួររបស់ខ្ញុំនេះគឺសួរទៅលើប្រធានបទដដែលទេ។

**ស៖** ខ្ញុំសូមឲ្យលោកបង្ហាញអំពីគុណវុឌ្ឍិរបស់លោក លោកបាននិយាយថា លោកសិក្សានីតិសិក្សាច្បាប់ ហើយនិងលោករៀននៅសាលាញូវសៅវែលផងដែរ។ ហើយសូមលោកបញ្ជាក់ថាតើនៅពេលដែលទៅរៀននៅអូស្ត្រាលីនោះ រៀនជំនាញជាក់លាក់អ្វីដែរ?

[១៤:០០:៥៨]

**លោក វ៉ាន់ថាន់ ដារ៉ាពៅ៖**

**ឆ៖** បាទ អរគុណ។ នៅស្រុកខ្មែរ ខ្ញុំបានរៀននៅបញ្ចប់ថ្នាក់បរិញ្ញាប័ត្រច្បាប់នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ នៅភ្នំពេញ នៅកម្ពុជា។ នៅពេលដែលខ្ញុំបានចូលធ្វើការនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ខ្ញុំទទួលបានការបណ្តុះបណ្តាលផ្នែកគ្រប់គ្រង និងថែរក្សាចងក្រងឯកសារនៅសាកលវិទ្យាល័យញូវសៅវែល នៅទីក្រុងស៊ីដនី ប្រទេសអូស្ត្រាលី។ ហើយបន្ថែមពីលើនោះទៀត ខ្ញុំបានទទួលនូវវគ្គបណ្តុះបណ្តាលទាក់ទងទៅនឹងការស៊ើបអង្កេតបទឧក្រិដ្ឋកម្មអន្តរជាតិនៅប្រទេស អៀរឡង់ នៅក្នុងឆ្នាំប្រហែលជា ដូចជា២០០០ ហើយក្រោយមកទៀត ខ្ញុំបានបន្តការសិក្សានៅសហរដ្ឋអាមេរិក ទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកច្បាប់សិទ្ធិមនុស្ស និងមនុស្សធម៌អន្តរជាតិ នៅសាកលវិទ្យាល័យ *ណូត្រឺដេម យូនីវើស៊ីធី*។

[១៤:០២:២១]

**ស៖** សូមអរគុណច្រើន លោកបានបញ្ជាក់រួចមកហើយផងដែរថា ខ្ញុំគិតថាលោកបាននិយាយអំពីមហាវិទ្យាល័យយ៉ែល និងញូវសៅវែល ដែលគេមកផ្តល់ការបណ្តុះបណ្តាលនៅ ឌី.ស៊ី.ខេម ផងដែរ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជាការត្រឹមត្រូវ។ មិនត្រឹមតែសាកលវិទ្យាល័យយ៉េល បានបញ្ជូនអ្នកជំនាញមកធ្វើការបណ្តុះបណ្តាលនៅមជ្ឈមណ្ឌលឯកសារកម្ពុជាទេ ប៉ុន្តែបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាមួយចំនួនក៏បានទៅធ្វើការបណ្តុះបណ្តាលនៅទីនោះដែរ។

**ស៖** ចាតើបុគ្គលិកទាំងអស់ដែលបានទទួលការបណ្តុះបណ្តាលនោះ នៅតែបន្តធ្វើការងារនៅ ឌី.ស៊ី.ខេម ទៀតដែរឬទេ?

**ឆ៖** មួយចំនួននៅបន្តធ្វើការងារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយមួយចំនួនទៀតបានទៅធ្វើការងារខាងក្រៅ ដែលចេញផុតពីមជ្ឈមណ្ឌលឯកសារកម្ពុជា។

[១៤:០៣:៣៥]

**ស៖** ខ្ញុំសូមសួរបន្តជាលក្ខណៈទូទៅអំពីមជ្ឈមណ្ឌលឯកសារកម្ពុជា ឌី.ស៊ី.ខេម ហើយនិងរចនាសម្ព័ន្ធរបស់វា ហើយដើម្បីធ្វើយ៉ាងណាបន្ថែមទៅលើសំណួរដែលចៅក្រមសួរកាលពីព្រឹកមិញ។ ខ្ញុំគិតថាលោកបានលើកឡើងថា ឌី.ស៊ី.ខេម ទទួលមូលនិធីពី-- ទទួលហិរញ្ញប្បទានពីប្រភពផ្សេងៗ។ តើវាមានលក្ខខណ្ឌចងភ្ជាប់ជាមួយនឹងហិរញ្ញប្បទានដែលគេផ្តល់ជូនឲ្យនោះដែរឬទេ?

**ឆ៖** ជាទូទៅហិរញ្ញប្បទានដែលបានផ្តល់ដោយប្រទេសម្ចាស់ជំនួយ ដោយម្ចាស់ជំនួយផ្សេងៗ គឺអត់មានលក្ខខណ្ឌអីដែលដាក់មកមជ្ឈមណ្ឌលឯកសារកម្ពុជាទេ។ គឺមជ្ឈមណ្ឌលឯកសារកម្ពុជា ជាអ្នកសម្រេច ជាអ្នកធ្វើកិច្ចការងារដោយផ្ទាល់ខ្លួនៗ ដោយឯករាជ្យតែម្តង។

[១៤:០៤:៣៧]

**ស៖** តើវាដូចទៅនឹងលក្ខខណ្ឌ ដូចទៅនឹងហិរញ្ញប្បទានដែលទទួលពីខាងរាជរដ្ឋាភិបាលផងដែរ រាជរដ្ឋាភិបាលកម្ពុជាផងដែរ មែនដែរឬទេ?

**ឆ៖** មជ្ឈមណ្ឌលឯកសារកម្ពុជា មិនបានទទួលជំនួយជាថវិកាពីរដ្ឋាភិបាលកម្ពុជាទេ ប៉ុន្តែមជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលជំនួយឧបត្ថម្ភជាៗការអនុញ្ញាត ការគាំពារផ្សេងៗទាក់ទងទៅនឹងសុវត្ថិភាព ទាក់ទងទៅនឹងការអនុញ្ញាតឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាបានចុះទៅស្រាវជ្រាវគ្រប់ទីកន្លែងនៅក្នុងប្រទេសកម្ពុជា។

**ស៖** ចាតើមានទទួលបង្គាប់បញ្ជាពីខាងរាជរដ្ឋាភិបាលដែរឬទេ នៅពេលដែលរាជរដ្ឋាភិបាលកម្ពុជាជំនួយឧបត្ថម្ភផ្សេងៗនោះ?

**ឆ៖** យើងមិនដែលទទួលការបញ្ជា ឬការបង្គាប់បញ្ជា ឬការអ្វីមួយពីរាជរដ្ឋាភិបាលទេ ក្រៅតែ

ពីការអនុញ្ញាតឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាមានសិទ្ធិចុះធ្វើការស្រាវជ្រាវគ្រប់ទីកន្លែងទាំងអស់នៅក្នុងប្រទេសកម្ពុជា ក៏ដូចជានៅក្រៅប្រទេសកម្ពុជា។

[១៤:០៦:០០]

**ស៖** សូមអរគុណ។ លោកក៏បាននិយាយផងដែរថា ខាង ឌី.ស៊ី.ខេម ហ្នឹងគឺមានគណៈគ្រប់គ្រង តើលោកដឹងថា តើមានប្រធានប៉ុន្មាននាក់នៅក្នុងគណៈគ្រប់គ្រងរបស់ ឌី.ស៊ី.ខេម នោះ? ថាតើគេតែងតាំងយ៉ាងម៉េចដែរ?

**ឆ៖** សូមមេត្តាសួរម្តងទៀត ដោយការបកប្រែមានចន្លោះមួយពាក្យដែលខ្ញុំចាប់អត់បាន។

**ស៖** ពាក់ព័ន្ធទៅនឹងគណៈកម្មការនាយក ឬក៏ក្រុមប្រឹក្សាភិបាល ថាតើមាននាយកប៉ុន្មានដែរដែលគាត់ធ្វើការងារជាគណៈនាយកនេះ? ហើយថាតើគេតែងតាំងដោយរបៀបណាដែរ? សូមអរគុណ។

**ឆ៖** នៅ-- ជារចនាសម្ព័ន្ធនៅមជ្ឈមណ្ឌលឯកសារកម្ពុជា គឺយើងមានគណៈនាយក និងមាននាយកប្រតិបត្តិមួយរូប ហើយនិងអនុប្រធានពីររូប ហើយនិងមានបន្តបន្ទាប់មកគឺប្រធានក្រុមបាទ។ ចំពោះគណៈនាយកនោះ គឺមានជាអ្នកជំនាញ ដែលគាត់អាចផ្តល់ជំនាញទៅតាមជំនាញរៀងៗខ្លួនដែលអាចជួយមកដល់មជ្ឈមណ្ឌលឯកសារកម្ពុជា តាមការស្ម័គ្រចិត្តរបស់គាត់។ សម្រាប់នាយកមជ្ឈ-មណ្ឌលឯកសារកម្ពុជា គឺបន្ទាប់ពីមានការបញ្ចប់ការងារជាមួយនឹងសាកលវិទ្យាល័យយ៉េល នៅក្នុងឆ្នាំ១៩៩៧ គឺពីពេលនោះមក គឺលោកនាយក យុ ឆាំង ជានាយកមជ្ឈមណ្ឌលឯកសារកម្ពុជារហូតមកដល់សព្វថ្ងៃនេះ។

[១៤:០៨:១៦]

**ស៖** សូមអរគុណ។ បានន័យថា លោកបានរៀបរាប់អំពីការជំនួយប្រឹក្សាផ្សេងៗផ្តល់ជូនដោយអ្នកសិក្សាស្រាវជ្រាវដើម្បីផ្តល់ទៅដល់លោក យុ ឆាំង ដើម្បីបំពេញអាណត្តិរបស់ ឌី.ស៊ី.ខេម បាន តើពិតជាដូច្នោះដែរឬទេ?

**ឆ៖** បាទ ជាការត្រឹមត្រូវ។

**ស៖** សូមអរគុណ។ លោកក៏បាននិយាយបញ្ជាក់ផងដែរ ក្នុងរយៈពេលលោកដែលលោក គ្រប់គ្រងនេះ លោកបានគ្រប់គ្រងបុគ្គលិកពី១៥ ទៅ៥០នាក់។ តើលោកអាចជម្រាបដែរឬទេ នៅពេលបច្ចុប្បន្ននេះ? តើមានបុគ្គលិកប៉ុន្មាននាក់ដែរ ដែលកំពុងធ្វើការងារនៅ ឌី.ស៊ី.ខេម?

[១៤:០៩:០៧]

**ឆ៖** នៅមជ្ឈមណ្ឌលឯកសារកម្ពុជាពេលបច្ចុប្បន្ននេះមានបុគ្គលិក៥៥នាក់ ដែលនៅក្នុងនោះក៏មានបុគ្គលិកស្ម័គ្រចិត្ត ហើយនិងបុគ្គលិកពេញសិទ្ធិ។ បុគ្គលិកស្ម័គ្រចិត្តមានន័យថា ជាបុគ្គលិកដែលស្ម័គ្រចិត្តមកធ្វើការងារឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយមិនមានប្រាក់ខែ ប៉ុន្តែជាការងារមួយដែលត្រូវធ្វើឡើងដោយគោរពទៅតាមបទបញ្ជាផ្ទៃក្នុងដោយគោរពទៅតាមពេលវេលា ទៅតាមវិន័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដូចបុគ្គលិកដទៃទៀតដែរ។

**ស៖** លោកក៏បានបញ្ជាក់ផងដែរ ថាបុគ្គលិកភាគច្រើនគឺគាត់ធ្វើការងារនៅក្នុងចាត់ចែង និងប្រមែប្រមូលឯកសារ តើពិតជាត្រឹមត្រូវដែរឬទេ?

**ឆ៖** នៅមជ្ឈមណ្ឌលឯកសារកម្ពុជា មានបុគ្គលិកជាច្រើន បានចូលរួមនៅក្នុងការប្រមែប្រមូល ក្នុងការចងក្រងឯកសារ មិនមែនមានតែរូបខ្ញុំ ឬក៏លោក ឆាំង យុ តែម្នាក់ទេ។

**ស៖** បុគ្គលិកនីមួយៗនោះ បើសិនជាខ្ញុំយល់ពីលោកនោះ គឺគាត់ធ្វើការងារក្រោមការគ្រប់គ្រងរបស់លោក តើពិតជាដូច្នោះដែរឬទេ?

**ឆ៖** ជាការត្រឹមត្រូវ។ ជាពិសេសគឺទាក់ទងទៅនឹងរឿងឯកសារនេះតែម្តង។

**ស៖** សូមអរគុណ។ ចំណុចចុងក្រោយពាក់ព័ន្ធទៅនឹងបុគ្គលិក នៅពេលបុគ្គលិកចូលរួមធ្វើការងារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ថាតើបុគ្គលិកទាំងអស់នោះ ត្រូវបានចាត់ចែងឲ្យធ្វើការងារនៅក្នុងការរៀបចំចាត់ចែងឯកសារ ហើយតើមានការបណ្តុះបណ្តាល ណែនាំអំពីនីតិវិធីដែលគេត្រូវចងក្រង និងប្រមែប្រមូលឯកសារនោះតាមរបៀបណាដែរឬទេ?

[១៤:១១:១២]

**ឆ៖** ជាការពិតណាស់អ្នកដែលធ្វើការងារផ្នែកឯកសារនេះ អ្នកដែលមិនបានទៅទទួលការបណ្តុះបណ្តាលនៅខាងក្រៅ ក៏បានទទួលការបណ្តុះបណ្តាលនៅខាងក្នុង ជាពិសេសមានអ្នកជំនាញមកពីសាកលវិទ្យាល័យយែល ពីសាកលវិទ្យាល័យញូវសៅវែល មកធ្វើការបណ្តុះបណ្តាលផ្ទាល់នៅមជ្ឈ-មណ្ឌលឯកសារកម្ពុជា។ លើសពីនេះទៅទៀត គឺថាខ្ញុំជាអ្នកគ្រប់គ្រងផ្នែកហ្នឹងផ្ទាល់ គឺយើងមានការប្រជុំ មានការចែករំលែកនូវបទពិសោធន៍ការងាររវាងគ្នាទៅវិញទៅមក ជាពិសេសរៀងរាល់ថ្ងៃសុក្រ គឺយើងមានការប្រជុំជាមួយនឹងសមាជិកក្រុម អំពីការងារធ្វើឯកសារ អំពីការងារផ្សេងៗដែលមាននៅមជ្ឈមណ្ឌលឯកសារកម្ពុជា។

**សៈ** សូមអរគុណ។ ខ្ញុំសូមសួរបន្តទៅលើចំណុចនៃការងារផ្សេងទៀត ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើការងារ គឺគម្រោងផ្សេងៗដែល ឌី.ស៊ី.ខេម បានធ្វើការងារ មុនពេលដែលខ្ញុំចូលសួរទៅដល់បញ្ហាឯកសារ។ លោកបានលើកឡើងកាលពីព្រឹកមិញ អំពីការសម្ភាស ដែលបានធ្វើឡើងដោយបុគ្គលិក ឌី.ស៊ី.ខេម នៅទូទាំងប្រទេសកម្ពុជា។ ថាតើការសម្ភាសនោះធ្វើឡើងតែការសាកសួរទៅកាន់ជនរងគ្រោះតែប៉ុណ្ណោះ ឬក៏ធ្វើទៅកាន់ជនរងគ្រោះដែលគេត្រូវបានចោទប្រកាន់ថាជាជនរងគ្រោះ នៃរបប ឬក៏ឧក្រិដ្ឋកម្មដែលបានកើតឡើង?

[១៤:១២:៥៤]

**ឆៈ** ការធ្វើបទសម្ភាសនេះ គឺធ្វើឡើងតាមគម្រោងមួយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយើងឲ្យឈ្មោះថា "គម្រោងជំរុញឲ្យមានការទទួលខុសត្រូវ" ដែលតាមរយៈគម្រោងនេះគឺយើងចុះទៅធ្វើការសម្ភាសមនុស្សដែលផ្អែកទៅលើឯកសារ គឺឯកសារទាក់ទងទៅនឹងប្រវត្តិរូប នៃអតីតយុទ្ធជនកម្មាភិបាលខ្មែរក្រហម ដែលមាននៅមជ្ឈមណ្ឌលឯកសារកម្ពុជា។ នៅពេលដែលយើងចុះទៅសម្ភាសគឺយើងមានឯកសារនេះនៅក្នុងដៃ ដែលយើងអាចរក-- ចុះទៅរកលំនៅដ្ឋាន ឬអាសយដ្ឋានបាន។ ហើយការសម្ភាសនេះទៀតសោត គឺយើងសម្ភាសទាំងអតីតយុទ្ធជនកម្មាភិបាលខ្មែរក្រហម ទាំងអ្នកដែលរស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ ពីរបបខ្មែរក្រហមហ្នឹងផងដែរ ជាពិសេសគឺក្រុមគ្រួសារសាច់ញាតិ ដែលមានកូនមានចៅ ដែលពាក់ព័ន្ធទៅនឹងឯកសារប្រវត្តិរូបដែលយើងមាននៅក្នុងដៃ ពេលដែលយើងចុះទៅធ្វើការសម្ភាស។ ហើយនៅក្នុងការធ្វើការសម្ភាសនេះទៀតសោត គឺយើងមានជាកម្រងសំណួរ ដែលយើងបានតាក់តែង ដែលយើងបានស្នើសុំឲ្យអ្នកជំនាញការច្បាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ធ្វើការពិនិត្យពិច័យទៅលើការធ្វើកម្រងសំណួរនេះ ហើយកម្រងសំណួរនេះត្រូវបានផ្ដល់ជូនមកអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរ ជាពិសេសគឺ ផ្ដល់ជូនសហចៅក្រមស៊ើបអង្កេតនៅពេលដែលចុះទៅធ្វើការស៊ើបអង្កេតនៅមជ្ឈមណ្ឌលឯកសារកម្ពុជា។

[១៤:១៥:០៣]

**សៈ** ហេតុអ្វីបានជាគេសម្រេចឲ្យធ្វើការសម្ភាស ទៅលើចារីដែលគេចោទប្រកាន់ថា ធ្វើការប្រព្រឹត្តបទល្មើសនៅក្នុងកម្ពុជាប្រជាធិបតេយ្យ និងអ្នកដែលជាជនរងគ្រោះនៃអំពើទាំងអស់នោះ?

**ឆៈ** ខ្ញុំយល់ថា ទីមួយ គឺយើងមានឯកសារបង្ហាញច្បាស់លាស់។ ទីពីរ គឺយើងបានបង្ហាញពីគោលបំណងរបស់យើង ដែលជាអង្គការមួយធ្វើការចងក្រងឯកសារ ដើម្បីបម្រើដល់ការចងចាំ និង

ប្រវត្តិសាស្ត្រនៃកម្ពុជាប្រជាធិបតេយ្យ ដោយមានការយល់ច្បាស់អំពីគោលបំណងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយដោយមានការយល់ព្រម អំពីអ្នកដែលត្រូវបានផ្ដល់បទសម្ភាស ទើបបទសម្ភាសនេះ អាចធ្វើឡើងដោយជោគជ័យ។

**ស៖** នៅពេលដែលលោកនិយាយអំពីគោលបំណង ហើយនៅពេលដែលលោកនិយាយនៅក្នុងសក្ខីកម្មរបស់លោកពេលមុននេះ គឺថាគោលបំណងបេសកកម្មនេះ ដើម្បីកត់ត្រាជាប្រវត្តិសាស្ត្រផងដែរ តើមែនដែរឬទេ?

**ឆ៖** ជាការត្រឹមត្រូវ ហើយរហូតមកដល់ពេលនេះ យើងបាន-- មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងជាសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ហើយដែលសៀវនេះ ត្រូវបានយកទៅបង្រៀននៅទូទាំងប្រទេសនៅក្នុងថ្នាក់រៀនថែមទៀតផង។

[១៤:១៧:០៣]

**ស៖** សូមអរគុណ។ បន្ថែមទៅលើសៀវភៅនោះ គឺមានទស្សនាវដ្ដីស្វែងរកការពិតមួយទៀត ដែលលោកបានលើកឡើងកាលពីព្រឹកមិញ ថាតើ ឌី.ស៊ី.ខេម មជ្ឈមណ្ឌលឯកសារនេះ មានបោះពុម្ពសៀវភៅផ្សេងទៀត ដែលក្នុងគោលបំណងជាកម្មវិធីសិក្សានេះផ្សេងទៀតដែរឬទេ?

**ឆ៖** ក្រៅពីសៀវភៅ ទស្សនាវដ្ដីស្វែងរកការពិត មជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពជាសៀវភៅ ជាសំណេរស្រាវជ្រាវមួយចំនួន ហើយដែលមាននៅមជ្ឈមណ្ឌលឯកសារកម្ពុជា។

**ស៖** ថាតើមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការស្វែងរក ធ្វើគម្រោងស្វែងរកព័ត៌មានជាសាធារណៈ ដូចដែលលោកលើកឡើងព្រឹកមិញនេះ ជាពិសេសសម្រាប់ការបណ្ដុះបណ្ដាលគ្រូបង្រៀនដែរឬទេ? មានគម្រោងគំនិតផ្ដួចផ្ដើមដើម្បីធ្វើការបណ្ដុះបណ្ដាលជាសាធារណៈ ទៅដល់គ្រូបង្រៀននានា ដើម្បីឲ្យគាត់យល់អំពីសម័យកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

**ឆ៖** បាទ ជាការត្រឹមត្រូវ។ នេះគឺជាកិច្ចការមួយចម្បងដែលយើងត្រូវធ្វើការបណ្ដុះបណ្ដាលលោកគ្រូអ្នកគ្រូដែលឲ្យលោកគ្រូ អ្នកគ្រូអាចបង្រៀនមេរៀននេះ ទៅមនុស្សជំនាន់ក្រោយ នៅក្នុងគោលបំណងមួយគឺថា ដើម្បីជាការទប់ស្កាត់ ដើម្បីឲ្យទទួលបាននូវការផ្សះផ្សា ដើម្បីឲ្យទទួលបាននូវការអត់ឱនរវាងគ្នាទៅវិញទៅមក មិនមែនជាការបង្រៀនឲ្យមានជាគំនិតសងសឹកនោះទេ។

[១៤:១៩:០២]

**ស៖** ដូច្នេះ វាត្រឹមត្រូវដែរឬទេ ថាតើគោលបំណងរបស់កម្ពុជាប្រជាធិបតេយ្យនេះ គឺដើម្បី

ផ្សះផ្សាជាតិផងដែរ តាមចម្លើយដែលលោកផ្ដល់អម្បាញ់មិញនេះ។

**ឆ៖** បាទ សូមលោកព្រះរាជអាជ្ញាចោទសំណួរនេះម្ដងទៀត ខ្ញុំស្ដាប់អត់ច្បាស់។

**ស៖** តទៅលើចម្លើយដែលលោកបានលើកឡើងថាដើម្បីជាការផ្សះផ្សាជាតិ និងការអត់ឱនគ្នា ថាតើផ្នែកហ្នឹង ទិដ្ឋភាពហ្នឹងជាការងារសំខាន់របស់លោកដែរឬទេ?

**ឆ៖** ជាការងារនៅក្នុងគម្រោងសិក្សាប្រវត្តិសាស្ត្រប្រជាធិបតេយ្យ គឺនៅក្នុងការសិក្សានេះ គឺយើងមានគោលបំណងឲ្យការសិក្សានេះ ក្លាយទៅជាការផ្សះផ្សា ក្លាយទៅការអត់ឱន ជាជាងក្លាយទៅជាការសងសឹក។

[១៤:២០:០៥]

**ស៖** សូមអរគុណ។ ចំណុចចុងក្រោយ ពាក់ព័ន្ធទៅនឹងគម្រោងក្រៅពីការចងក្រងឯកសារក្រៅពីគម្រោងនេះ លោកបានរៀបរាប់អំពីការកំណត់ផែនទីទៅលើរណ្ដៅរួមដែលលោកបានលើកឡើងកាលពីព្រឹកមិញ។ ថាតើមានស្រុកចំនួនប៉ុន្មាននៅក្នុងប្រទេសកម្ពុជាដែលលោកបានធ្វើការកំណត់ផែនទីរណ្ដៅសាកសពរួមនោះ?

**ឆ៖** ខ្ញុំគ្រាន់តែអាចដឹងថានៅក្នុងប្រទេសកម្ពុជាមានស្រុកចំនួន១៨៦ស្រុក ហើយដោយសារថានៅពេលដែលយើងអនុវត្តនូវគម្រោងធ្វើផែនទីរណ្ដៅសាកសពនេះ គឺក្នុងអំឡុងពេលមួយដែលស្រុកមួយចំនួនស្ថិតនៅក្នុងការគ្រប់គ្រងរបស់របបកម្ពុជាប្រជាធិបតេយ្យនៅឡើយ។ ដូច្នេះការធ្វើការសិក្សា ធ្វើការលើគម្រោងនេះ គឺមិនទាន់បានចប់សព្វគ្រប់ទាំងអស់នៅក្នុងគ្រប់ស្រុកនៅប្រទេសកម្ពុជានោះទេ។

[១៤:២១:២៣]

**ស៖** តើលោកអាចជម្រាបជូនអង្គជំនុំជម្រះដោយសង្ខេបបានដែរឬទេថា ថាតើលោកធ្វើការកំណត់ទីតាំងរណ្ដៅរួមដែលយើងអាចចាត់ទុកថាជាទីតាំងរណ្ដៅដែលវាសំខាន់សម្រាប់ធ្វើផែនទីនេះដែរឬទេ?

**ឆ៖** មុនយើងចុះទៅធ្វើការស្រាវជ្រាវកិច្ចការទាំងអស់នេះនៅតាមស្រុក តាមខេត្តនោះគឺថាយើងបានផ្អែកទៅលើៗឯកសារ ឯកសារនោះគឺទាក់ទងទៅនឹងឯកសារ ទីមួយគឺឯកសារការស្រាវជ្រាវអំពីអំពើឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ដែលការស្រាវជ្រាវនេះធ្វើឡើងដោយរបបសាធារណៈរដ្ឋប្រជាមានិតកម្ពុជា ដែលនៅក្នុងទសវត្សរ៍ឆ្នាំ១៩៨០។ តាមរយៈឯកសារនេះក៏មានឯកសារមួយទៀតដែលយើង ដែលនៅមជ្ឈមណ្ឌលឯកសារកម្ពុជាយើងហៅថា ឯកសាររណសិរ្ស

ព្រោះកាលពីសម័យនោះគឺថាឯកសារទាក់ទងនឹងពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ គឺមានទុកនៅ ចងក្រងទុកនៅមន្ទីរវណសិប្បនៅទូទាំងប្រទេស។

ហើយឯកសារមួយទៀតនោះ គឺជាឯកសារដែលមាននៅមន្ទីរ ក្រសួងមន្ទីរឃោសនាការវប្បធម៌ និងព័ត៌មាន។ ដោយផ្អែកលើឯកសារនេះ គឺយើងអាចដឹងអំពីៗទីតាំងរណ្តៅដែលបានធ្វើការគាស់កកាយពីមុនរួចមកហើយ។ នៅពេលដែលយើងទៅដល់ទីតាំង គឺយើងបានទទួលព័ត៌មានបន្ថែមទៀតអំពីអ្នកដែល-- អ្នកស្រុក អ្នកភូមិ ដែលគាត់ ទីមួយគាត់អាចធ្លាប់ចូលរួមនៅក្នុងការគាស់រណ្តៅសាកសព។ ទីពីរគាត់អាចជាអ្នកដែលធ្លាប់រស់នៅក្នុងជុំវិញ ក្នុងតំបន់ដែលរណ្តៅសាកសពនេះមាននៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ អ៊ីចឹងទាំងអស់នេះឯង ជាមូលដ្ឋានសម្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជានៅក្នុងការធ្វើការចុះទៅស្រាវជ្រាវចងក្រងលើការងារនេះ។

[១៤:២៤:០៨]

**ស៖** នៅពេលដែលទីតាំងមួយ រណ្តៅមួយត្រូវបានកំណត់ដោយបុគ្គលិករបស់លោករួចហើយ ថាតើការកំណត់នោះធ្វើឡើងតាមភូមិសាស្ត្រដែរឬទេ ឬក៏បានកត់ត្រាទៅលើទីតាំងភូមិសាស្ត្រដែរឬទេ?

**ឆ៖** បាទ នៅក្នុងការកំណត់ទីតាំងនេះ គឺយើងបានប្រើម៉ាស៊ីនកំណត់នូវទីតាំង ដែលយើងហៅថាម៉ាស៊ីន *"ជីភីអេស ក្លូប៊ល ប្រ៊ូស៊ីសសិននីង ស៊ីសស្តែម"* ដែលម៉ាស៊ីននេះអាចប្រាប់យើងអំពីរយៈទទឹង បណ្តោយ រយៈទទឹងខ្សែ រយៈទទឹងបណ្តោយ និងទទឹងដែលអាចកំណត់ទីតាំងបាន យ៉ាងច្បាស់លាស់នៅលើផែនទី ហើយនៅពេលដែលយើងប្រើប្រាស់ម៉ាស៊ីននេះ គឺយើងមានការកត់ត្រានៅលើទម្រង់តារាងមួយដែលមានកត់ត្រានូវតួលេខដែលបង្ហាញអំពីរយៈទទឹង រយៈបណ្តោយ ដែលបង្ហាញតាមម៉ាស៊ីន GPS នេះតែម្តង។

**ស៖** វាត្រឹមត្រូវដែរឬទេ ដែលថាព័ត៌មានទាំងនោះវាមានតាមរយៈប្រព័ន្ធអ៊ីនធឺណែតផងដែរ។ តើពិតជាដូច្នោះដែរឬទេ?

**ឆ៖** ជាការត្រឹមត្រូវ គឺយើងបានដាក់បង្ហោះលទ្ធផលនៃការសិក្សាស្រាវជ្រាវនេះនៅលើគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

**ស៖** សូមអរគុណ។ សំណួរខ្ញុំប្រហែលជាសុំសួរចូលបន្តទៅលើការគ្រប់គ្រង និងការកាន់កាប់ឯកសារ ជាពិសេសទៅលើការប្រមែប្រមូល និងរើកកាយឯកសារ។ តាមអ្វីដែលលោកដឹងល្អបំផុតនោះ តាមចំណេះដឹងរបស់លោកនោះ ថាតើយើងដឹងថាមានអ្វីកើតឡើងចំពោះឯកសាររបស់កម្ពុជាប្រជាធិប

តេយ្យក្រោយពីការដួលរលំនៃរបបនោះនៅដើមឆ្នាំ១៩៧៩?

[១៤:២៦:៤៩]

**ឆ៖** តាមការយល់ដឹងរបស់ខ្ញុំ ទាក់ទងទៅនឹងឯកសារនេះ គឺថាឯកសារទាំងអស់នេះ គឺអាចត្រូវបាននៅរាយប៉ាយនៅតាមអគារនេះ នៅតាមកន្លែងនោះ នៅលើដៃបុគ្គលនេះ នៅលើដៃបុគ្គលនោះ ដែលមិនមានជាឯកសារមួយដែលនៅក្នុងផ្តុំនៅកន្លែងតែមួយនោះទេ។ ហើយដោយសារតែមានការអនុញ្ញាតត្រឹមត្រូវ ទើបមជ្ឈមណ្ឌលឯកសារកម្ពុជាមានលទ្ធភាពអាចចុះទៅធ្វើការស្រាវជ្រាវ ធ្វើការប្រមែប្រមូល និងចងក្រងទុកឯកសារទាំងអស់នេះនៅមជ្ឈមណ្ឌលឯកសារកម្ពុជា។

**ស៖** និយាយម្យ៉ាងទៀតបានន័យថា យើងមិនបានទៅប្រមែប្រមូលតែកន្លែងម្តុំទេនៃឯកសារកម្ពុជាប្រជាធិបតេយ្យនោះ។ តើមែនដែរឬទេ?

**ឆ៖** ជាការត្រឹមត្រូវ។

**ស៖** ប្រសិនបើខ្ញុំយល់មិនខុសទេ កាលពីព្រឹកមិញឯកសារកម្ពុជាប្រជាធិបតេយ្យខុសៗគ្នា គឺវានៅៗតាមតំបន់ផ្សេងៗ តើពិតជាត្រឹមត្រូវដែរឬទេ?

**ឆ៖** ជាការត្រឹមត្រូវ។

**ស៖** ខ្ញុំនឹងព្យាយាមធ្វើការសួរទៅលើចំណុចចម្បងៗមួយចំនួន ថាតើឯកសារមួយចំនួនត្រូវបានរកឃើញនៅមន្ទីរស-២១ នោះមានដែរឬទេ? មានឯកសារណាដែលរកឃើញនៅមន្ទីរស-២១ ដែរឬទេ?

[១៤:២៨:៥៦]

**ឆ៖** បាទប្រាកដជាមាន គឺជាពិសេស គឺឯកសារដែលមិនមែនជាឯកសារចម្លើយសារភាព។ ព្រោះថា ឯកសារចម្លើយសារភាពដែលមាននៅទួលស្លែងយើងមិនបានយកមកទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជាទេ។

**ស៖** ប្រសិនបើខ្ញុំយល់មិនខុសនោះទេ មានឯកសារមួយចំនួនមិនមែនជាចម្លើយសារភាពនោះទេ ក៏ប៉ុន្តែរកឃើញនៅមន្ទីរស-២១ ដែរ តើពិតជាត្រឹមត្រូវដែរឬទេ?

**ឆ៖** ជាការត្រឹមត្រូវ។

**ស៖** តើនរណាគេរកឃើញឯកសារទាំងអស់នោះ?

**ឆ៖** ដូចខ្ញុំបានជម្រាបពីខាងដើម គឺថាទាក់ទងទៅនឹងការប្រមែប្រមូលឯកសារនេះ គឺថាមាន

បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាជាច្រើននាក់ដែរទៀត ដែលបានចូលរួមនៅក្នុងការប្រមែប្រមូលឯកសារនេះ។ ទាំងរូបខ្ញុំ ទាំងលោកនាយករបស់ខ្ញុំ ទាំងសហការីរបស់ខ្ញុំ គឺសុទ្ធតែជាអ្នកដែលធ្លាប់បានទៅប្រមែប្រមូលឯកសារ ហើយជាពិសេសគឺឯកសារនៅទួលស្លែងនេះតែម្តង ខ្ញុំបាន-- រូបខ្ញុំផ្ទាល់ គឺបានទៅដល់ទីនោះ ហើយបានស្រាវជ្រាវមើលឯកសារផ្សេងៗ ដែលវាមានការចាំបាច់នៅក្នុងការសិក្សាស្រាវជ្រាវនៅមជ្ឈមណ្ឌលឯកសារកម្ពុជា។

[១៤:៣០:២៥]

**ស៖** តាមការយល់ដឹងរបស់លោក មុនពេលបង្កើតមជ្ឈមណ្ឌលឯកសារកម្ពុជា ថាតើឯកសារទាំងអស់នោះ វានៅតែនៅក្នុងមន្ទីរ ស-២១ ដែរឬទេ? គឺជាពិសេសចន្លោះឆ្នាំ១៩៧៩ ទៅដល់ ឆ្នាំ១៩៩៥ នោះ?

**ឆ៖** តាមការយល់ដឹងរបស់ខ្ញុំ ខ្ញុំយល់ថា ឯកសារទាំងអស់នេះនៅទីនោះមែន។ ក្រោយមកនៅពេលដែលខ្ញុំបានទៅធ្វើការប្រមែប្រមូលនិងស្រាវជ្រាវនៅ ជាពិសេសនៅទួលស្លែង គឺយើងបានឃើញឯកសារនៅទីនោះ។

**ស៖** តើយើងអាចដឹងថា ឯកសារនេះមាននៅស-២១ នៅក្នុងអំឡុងពេលនោះបានដោយរបៀបណា?

**ឆ៖** ជាទូទៅគឺមន្ទីរស-២១ នេះត្រូវបានបើកឲ្យប្រើប្រាស់តាំងពីក្រោយរបបខ្មែរក្រហម ហើយដែលជា ដែលមនុស្សទូទៅនៅក្នុងប្រទេសកម្ពុជាបានស្គាល់ថាជាកន្លែងដែល-- គុករបស់ខ្មែរក្រហម ហើយមានការចងក្រងជាឯកសារ។ អ៊ីចឹងសម្រាប់យើងជាអ្នកសិក្សាស្រាវជ្រាវ យើងបានដឹងថានៅទីនោះអាចមាន ឬគ្មានឯកសារ។ អ៊ីចឹងនៅពេលដែលយើងចុះទៅធ្វើការស្រាវជ្រាវ គឺយើងបានប្រទះឃើញនូវឯកសារនេះតែម្តង។

**ស៖** ខ្ញុំគិតថាលោកចៅក្រម ឡាវែន៍ បានសួរពីខាងដើមមកហើយអំពីទីតាំងរបស់ឯកសារគឺក្រសួងមហាផ្ទៃ។ តើលោកដឹងឬក៏នៅចាំបានថាតើនៅពេលណា ហើយនិងឯកសារនៅក្រសួងមហាផ្ទៃនេះ ត្រូវបានប្រមូលដោយ ឌី.ស៊ី.ខេម ដោយរបៀបណាដែរ?

[១៤:៣២:៥៥]

**ឆ៖** ឯកសារដែលយើងប្រមូលមកដាក់ ទុកដាក់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា គឺយើងចាប់ផ្តើមប្រមូលតាំងពីឆ្នាំ៩៥។ អ៊ីចឹងដោយសារថាឯកសារច្រើន ចំពោះថ្ងៃខែ ខ្ញុំអាចថាមិនចាំ ប៉ុន្តែបើសិន

ជាយើងមើលទៅលើបញ្ជីឯកសារដែលមានចងក្រងទុកដាក់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា នោះលោក លោកស្រីនឹងបានដឹងច្បាស់លាស់ថា ឯកសារមួយណាយើងប្រមូលពីកន្លែងណា ហើយប្រមូលនៅពេលណា។

**ស៖** ប្រសិនណាត្រូវការ ប្រហែលជាលោកនឹងអាចផ្តល់ព័ត៌មានបន្ថែមដែលសួរអម្បាញ់មិញនេះបានទៀតមែនទេ?

**ឆ៖** ជាការត្រឹមត្រូវ។

**ស៖** តើលោកអាចនៅចាំបានដោយប្រការណាមួយទេថា ឯកសារប្រភេទណាមួយដែលប្រមូលបានក្រសួងមហាផ្ទៃនោះ?

**ឆ៖** បាទ ឯកសារដែលយើងបានប្រមូលពីក្រសួងមហាផ្ទៃនោះ គឺជាពិសេសឯកសារទាក់ទងទៅនឹងៗចម្លើយសារភាព ដែលនៅមជ្ឈមណ្ឌលឯកសារកម្ពុជា យើងបានកាតាឡុក បានចុះលេខឯកសារនោះ គឺជាឯកសារ “J” ហើយនិងមានឯកសារផ្សេងៗទៀត ដូចជាឯកសារ លន់ នល់ ដែលយើងហៅថា លន់ នល់ *ដូស្សេ* ហើយនិងមានឯកសារផ្សេងៗទៀត។

[១៤:៣៥:០០]

**ស៖** ចាតើសំណួរអស់នោះអាចមាននៅក្នុងក្រសួងមហាផ្ទៃនោះដោយរបៀបណាដែរ?

**ឆ៖** តាមដែលអ្វីដែលខ្ញុំអាចដឹងបាន គឺនៅពេលដែលមានការរៀបចំជាក្រសួងមន្ទីរ ពេលខ្លះទៅឯកសារហ្នឹង គឺត្រូវបានប្រមែប្រមូលយកមកទុកនៅក្នុងក្រសួងមហាផ្ទៃ ដោយយល់ថាជាឯកសារពីរបបមុន ហើយយកមកទុកដាក់នៅក្រសួងមហាផ្ទៃ។ នៅពេលដែលយើងចុះធ្វើការសិក្សាស្រាវជ្រាវ យើងបានប្រទះឃើញឯកសារនេះ ដែលទាក់ទងទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យ ហើយយើងបានធ្វើការប្រមែប្រមូលនិងចងក្រងទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា។

**ស៖** ចាតើនៅក្នុងឧទាហរណ៍ជាក់ស្តែងមួយនេះ គឺថា លោកបញ្ជូនឯកសារដើមគឺពីក្រសួងមហាផ្ទៃគឺថា យកទៅតម្កល់ទុកនៅ ឌី.ស៊ី.ខេម មែនទេ?

[១៤:៣៦:២១]

**ឆ៖** ត្រឹមត្រូវ ដោយយើងបានធ្វើនូវយថាភាពនៃឯកសារតាមរយៈការសួរនាំថា ឯកសារទាំងអស់នេះពីមុននៅទីណា? ហើយមកដល់ក្រសួងយ៉ាងដូចម្តេច? ហើយបន្ទាប់មកគឺយើងធ្វើការទទួលនូវឯកសារនេះយកមកទុកដាក់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា។ ហើយពេលមកដល់មជ្ឈមណ្ឌលឯកសារ

កម្ពុជា គឺយើងបានអនុវត្តនូវវិធីសាស្ត្រនៅក្នុងការទុកដាក់ នៅក្នុងការចងក្រងឯកសារដូចបានជម្រាបកាលពីព្រឹកមិញអ៊ីចឹង។

**ស៖** ខ្ញុំគិតថា ពីខាងដើមលោកបានលើកឡើងថា ការប្រមូលនេះគឺមានរួមទាំងឯកសារចម្លើយសារភាពផង បើតាមខ្ញុំចាំ មែនទេ?

**ឆ៖** បាទ ជាការត្រឹមត្រូវ។

**ស៖** ចាតើលោកដឹងថា ហេតុអ្វីបានជាមានឯកសារចម្លើយសារភាពដែលស្ថិតនៅក្រសួងមហាផ្ទៃក្រៅពីទីតាំងផ្សេងនោះទៅវិញ? ក្រៅពីមន្ទីរសន្តិសុខស-២១ ទៅវិញនោះ? បើសិនណាជាឯកសារនោះវាជាឯកសារដើមដែរនោះ?

**ឆ៖** តាមការយល់ដឹងរបស់ខ្ញុំគឺថា ឯកសារនេះត្រូវបានបញ្ជូនទៅថ្នាក់លើមួយទៀត គឺជាៗអ្នកគ្រប់គ្រងនៅក្នុងក្រសួងការពារជាតិរបស់របបកម្ពុជាប្រជាធិបតេយ្យ ដែលទទួលបន្ទុកផ្នែកសន្តិសុខ។ ហើយតាមការយល់ដឹងរបស់ខ្ញុំគឺថា ឯកសារទាំងអស់នេះ គឺវាពាក់ព័ន្ធទៅនឹងបញ្ហាសន្តិសុខ ដូច្នេះហើយឯកសារនេះត្រូវបានបញ្ជូនទៅក្រសួងការពារជាតិរបស់កម្ពុជាប្រជាធិបតេយ្យ ដែលជំនាន់នោះ គឺគ្រប់គ្រងដោយ ដឹកនាំដោយ សុន សេន ដែលហៅក្រៅថា សមមិត្ត ខៀវ។ នៅពេលដែលរបបនេះដួលរលំទៅគឺថា ឯកសារនេះត្រូវបានរកឃើញ ហើយត្រូវបានបញ្ជូនទៅក្រសួងមហាផ្ទៃ ដើម្បីធ្វើការទុកដាក់នៅកន្លែងហ្នឹង។ ហើយម្យ៉ាងវិញទៀតនោះគឺថា ការផ្តល់ឯកសារបែបនេះ ពេលដែលរបបកម្ពុជាប្រជាធិបតេយ្យដួលរលំទៅគឺថា ពេលហ្នឹងគឺ ត្រូវការទីកន្លែង ត្រូវការបន្ទប់សម្រាប់ធ្វើការងារ អ៊ីចឹងម្នាក់ៗត្រូវការបោសសម្អាតបន្ទប់ ហើយបើសិនជាមានឯកសារ មានអ៊ីចឹង អាចបញ្ជូនទៅកន្លែងណាមួយដែលអាចគិតថា ថែរក្សាឯកសារនោះបាន។

[១៤:៣៩:២៤]

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលសម្របសម្រួលដល់សាក្សី ដើម្បីរកកន្លែងសម្រាកសមរម្យ និងសូមអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មហ្នឹងឲ្យបានមុនអង្គជំនុំជម្រះចូលមកកាន់អាសនៈ។

*(សវនាការសម្រាកពីម៉ោង ១៤:៤០ នាទី ដល់ម៉ោង ១៥:០០ នាទី)*

[១៥:០០:៤៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

ជាបន្ត សូមផ្តល់វេទិកាទៅសហព្រះរាជអាជ្ញារងអន្តរជាតិ ដើម្បីបន្តការសួរសំណួរទៅកាន់សាក្សី។ សូមអញ្ជើញ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ មុនពេលដែលខ្ញុំសូមចាប់ផ្តើម ខ្ញុំសូមជូនជាផលប្រយោជន៍ដល់អង្គជំនុំជម្រះ និងភាគីផងដែរ នៅក្នុងសំណុំរឿងរបស់យើងនាពេលនេះ យើងមានឯកសារចុងក្រោយនៃបញ្ជីរបស់សហព្រះរាជអាជ្ញា នៃឯកសារនៅក្នុងសវនាការវគ្គដំបូង ដូចដែលយើងពិភាក្សាកាលពីសប្តាហ៍មុន។ យើងខ្ញុំជឿថា យើងបានដាក់ត្រឹមថ្ងៃអង្គារ ប៉ុន្តែយើងអាចដាក់ត្រឹមថ្ងៃចន្ទ ថ្ងៃនេះរួចមកហើយ។ នៅក្នុងនោះ តារាងនោះគឺរួមមានឯកសារដែលប្រមូលមកបានពី ឌី.ស៊ី.ខេម ដាក់បញ្ចូលជូននៅចំពោះមុខអង្គជំនុំជម្រះ គឺឯកសារបញ្ជីមានឯកសារប្រហែលជា ២.៣៨៤ឯកសារ ហើយបញ្ជីនេះគឺថានឹងមានក្នុងពេលឆាប់ៗនេះ។ សូមអរគុណ។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក ដារ៉ាពៅ យើងខ្ញុំអនុញ្ញាតសូមសាកសួរសំណួរ ពាក់ព័ន្ធទៅនឹងឯកសារដែលលោកប្រមូលបាន ឬក៏ដែល ឌី.ស៊ី.ខេម ប្រមូលបានមកពីក្រសួងមហាផ្ទៃ។ លោកបានផ្តល់សក្ខីកម្មមុននេះថាឯកសារទាំងឡាយ ត្រូវបានគេជឿជាក់ថា ត្រូវបានរក្សាទុកក្រោមការក្តោបក្តាប់របស់លោក សុន សេនដែលជារដ្ឋមន្ត្រីក្រសួងការពារជាតិ នៃរបបកម្ពុជាប្រជាធិបតេយ្យ។ ថាតើលោកដឹងចំណុចនេះតាមរបៀបណាដែរ?

[១៥:០២:៥៩]

**ឆ៖** គឺយើងបានមើលទៅលើឯកសារហ្នឹងផ្ទាល់ ហើយយើងបានមានឃើញឯកសារហ្នឹងត្រូវបានយើងធ្វើយថាភាពនៃឯកសារ ដែលដឹងថា ឯកសារនេះគឺជាឯកសារដែលស្ថិតក្រោម-- ដែលជារបស់ក្រសួងការពារជាតិ នៃកម្ពុជាប្រជាធិបតេយ្យ ហើយដែលមានទីតាំងមួយនៅកណ្តាលក្រុងភ្នំពេញដែរ តាមរយៈនេះដែលយើងអាចដឹងថា ឯកសារនេះជាឯកសាររបស់ សុន សេន។

**ស៖** ថាតើជាការប្រមូលបាន ដែលបាន-- ជាកម្រងនៃឯកសារប្រមូលបានដែលយើងហៅថាឯកសាររបស់សន្តិបាលហ្នឹងឬក៏យ៉ាងម៉េច? ឬក៏មិនមែនទេ?

**ឆ៖** បាទ ជាការត្រឹមត្រូវ។ គឺជាឯកសារដែលយើងប្រមូលបានមក ហើយដែលយើងហៅថាជាឯកសារសន្តិបាល។

**ស៖** លោកក៏បានបញ្ជាក់ផងដែរថា ការប្រមែប្រមូលបាននេះ-- ការប្រមែប្រមូលឯកសារសន្តិបាលនេះគឺក៏ជាឯកសារខាង លន់ នល់ ផងដែរ តើពិតជាត្រឹមត្រូវដែរឬទេ?

[១៥:០៤:៣៣]

**ឆ៖** ជាការត្រឹមត្រូវ គឺជាបណ្តុំឯកសារដែលយើងទទួលបានពីក្រសួងមហាផ្ទៃ។

**ស៖** បណ្តុំឯកសារ លន់ នល់ ថាតើមានលក្ខណៈដូចគ្នា ឬក៏មានកំណត់លក្ខណៈយ៉ាងម៉េចដែរ គេកំណត់យ៉ាងម៉េចដែរ ដែលអាចចាត់ទុកជាឯកសារ លន់ នល់ នុ៎ង?

**ឆ៖** ឯកសារ លន់ នល់ គឺទាក់ទង-- យើងពិនិត្យទៅមើល-- ទៅលើខ្លឹមសារនៃឯកសារ យើងពិនិត្យទៅលើកាលបរិច្ឆេទនៃឯកសារ។ ខ្ញុំឲ្យឧទាហរណ៍មួយ គឺនៅក្នុងឯកសារ លន់ នល់ គឺភាគច្រើនគឺរាយការណ៍អំពីសភាពការណ៍របស់ខ្មាំង គឺសំដៅទៅលើចលនាតស៊ូរបស់របបខ្មែរក្រហមនេះឯង។ អ៊ីចឹង ប៉ុន្តែនៅក្នុងបណ្តុំឯកសារដែលយើងហៅថា លន់ នល់ *ដូស្យេ* នេះ គឺមានឯកសារខ្លះដែលជាឯកសារនិយាយអំពីរបបខ្មែរក្រហម ដែលពាក់ព័ន្ធនឹងរបបខ្មែរក្រហមខ្លះដែរ។

**ស៖** សូមអរគុណច្រើន។ ខ្ញុំសូមបញ្ជាក់បំភ្លឺ ខ្ញុំក៏ចាប់អារម្មណ៍ចង់សួរផងដែរ ថាតើ ឌី.ស៊ី.ខេម មានការកំណត់សញ្ញាសម្គាល់ ឬលេខកូដ យ៉ាងម៉េចចំពោះបណ្តុំឯកសារ លន់ នល់ ហ្នឹង?

**ឆ៖** ចំពោះបណ្តុំឯកសារ លន់ នល់ នៅមជ្ឈមណ្ឌលឯកសារកម្ពុជា បន្ទាប់ពីយើងថតចម្លងពីឯកសារដើម ហើយយកមកធ្វើការចងក្រង ធ្វើការចុះលេខនេះ គឺឯកសារនេះយើងប្រើអក្សរ “L” ពីខាងមុខ។

**ស៖** ដូច្នេះគឺបានន័យថា វាមានឯកសារមួយចំនួនដែលអក្សរ “L” គឺគេកំណត់ និងដាក់នៅលើឯកសារមកពីបណ្តុំ លន់ នល់ ហើយក៏អាចមានសញ្ញា “L” ដែលជាសញ្ញាសម្គាល់ឯកសាររបស់ខ្មែរក្រហមដែរឬទេ?

[១៥:០៧:១២]

**ឆ៖** បើនិយាយឲ្យខ្លីទៅ គឺថានៅក្នុងបណ្តុំឯកសារ ដែលយើងហៅថាឯកសារ លន់ នល់ *ដូស្យេ*

នេះ គឺឲ្យតែឯកសារនៅក្នុងបណ្តុំឯកសារហ្នឹង គឺយើងធ្វើការចងក្រងដោយចុះលេខវា ជាឯកសារជាប្រភេទអក្សរ “L”។

**ស៖** សូមអរគុណ។ ខ្ញុំសូមសួរបន្តចូលទៅដល់ទីបណ្ណសារ ដែលយើងបានពិភាក្សាមុននេះលោកបានបញ្ជាក់រួចមកហើយ អំពីបណ្ណសារដ្ឋាន។ ឯកសារមួយចំនួន ក៏បានរកឃើញមកពីបណ្ណសារដ្ឋានជាតិផងដែរ តើពិតជាត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ជាការត្រឹមត្រូវ។ ហើយឯកសារនេះ គឺសុទ្ធតែជាឯកសារថតចម្លង ដែលមាននៅមជ្ឈមណ្ឌលឯកសារកម្ពុជា។

**ស៖** សូមអរគុណ។ ដូច្នេះ ភាពខុសគ្នារវាងឯកសារដែលលោកទទួលបានពីបណ្ណសារដ្ឋានជាតិដូចដែលលោកបានបញ្ជាក់មកនោះ គឺជាឯកសារថតចម្លងទាំងអស់ ហើយវាមានភាពខុសភាពទៅនឹងឯកសារដែលលោកទទួលបានមកពីក្រសួងមហាផ្ទៃក្នុង ដែលវាជាឯកសារដើម តើពិតជាដូច្នេះដែរឬទេ?

**ឆ៖** ជាការត្រឹមត្រូវ ព្រោះឯកសារដែលយើងធ្វើការប្រមែប្រមូល និងចងក្រងពីឯកសារដែលមាននៅបណ្ណសារដ្ឋានជាតិនេះ គឺជាឯកសារដែលយើងថតចម្លង ហើយបើធៀបទៅនឹងឯកសារដែលយើងប្រមែប្រមូលបានពីក្រសួងមហាផ្ទៃ ដែលជាឯកសារដើម គឺមានលក្ខណៈខុសគ្នាឆ្ងាយ។ គឺយើងអាចមើលឃើញភាពខុសគ្នានេះ ដោយផ្ទាល់ភ្នែក ដោយការអង្កេតទៅលើភាពចំណាស់នៃឯកសារកាលបរិច្ឆេទ ខ្លឹមសារ ភាសា ហើយនិងការមានឯកសារមួយចំនួន គឺវាទាក់ទងទៅនឹងមានចំណារដែលមានពណ៌ ដែលអីច្បាស់លាស់។

[១៥:០៩:៤០]

**ស៖** ខ្ញុំសូមសួរបន្តទៀតទៅលើប្រភពដែលប្រមូលឯកសារមក តើលោកស្គាល់អំពីការងាររបស់គណៈកម្មការរបស់ខាងមជ្ឈមណ្ឌលឯកសារកម្ពុជាដែរឬទេ? ឬក៏មានគណៈកម្មការមួយដែលដឹកនាំដោយលោក ដេវីដ ហាក ជួយធ្វើការងារដល់មជ្ឈមណ្ឌលឯកសារកម្ពុជាដែរឬទេ?

**ឆ៖** យើងបានដឹងអំពីការងារ ធ្វើការចងក្រងឯកសារនេះដែលដឹកនាំដោយលោក ដេវីដ ហាក ហើយឯកសារនេះត្រូវបានប្រគល់ជូនមកមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយដែលនៅក្នុងឯកសារនេះយើងចាត់ទុកជាឯកសារប្រភេទអក្សរ “D”។

**ស៖** និយាយដោយលក្ខណៈទូលាយ ប្រសិនបើលោកចាំ ថាតើមានប្រភេទឯកសារណាខ្លះ

ដែលស្ថិតនៅក្នុងកម្រងឯកសារលោក ដេវីដ ហក ហ្នឹង។ វាជាឯកសារប្រមូលបានពីសម័យកម្ពុជាប្រជាធិបតេយ្យ ឬក៏ជាប្រភេទឯកសារផ្សេងទៀតដែលនៅក្នុងសំណុំឯកសារនុ៎ង?

**ឆ៖** នៅក្នុងសំណុំឯកសាររបស់ ឯកសារលោក ដេវីដ ហក នេះ គឺមានឯកសារជាឯកសារខ្មែរក្រហម មានឯកសារជាបទសម្ភាសដែលធ្វើឡើងជាមួយនឹងជនភៀសខ្លួន ដែលមានជាខ្សែអាត់ផង និងមានឯកសារជារូបថតមួយចំនួនផង។

[១៥:១១:៣៨]

**ស៖** តាមការយល់ដឹងរបស់លោក តើលោក និង ឌី.ស៊ី.ខេម នៅពេលបច្ចុប្បន្នកំពុងតែកាន់កាប់ឯកសារទាំងឡាយដែលបានប្រមូលមកពីគណៈកម្មការ ឬក៏ពីលោកហ្នឹងមែនដែរឬទេ?

**ឆ៖** ឯកសាររបស់លោក ដេវីដ ហក ដែលបញ្ជូនមកមជ្ឈមណ្ឌលឯកសារកម្ពុជាគឺមានចងក្រង និងថែរក្សាទុកយ៉ាងត្រឹមត្រូវនៅមជ្ឈមណ្ឌលឯកសារកម្ពុជា។

**ស៖** ប្រហែលជាសំណួររបស់ខ្ញុំ វាច្បាស់រួចមកហើយ។ ថាតើលោកកាន់កាប់សំណុំឯកសារទាំងឡាយដែលប្រមូលដោយគណៈកម្មការហ្នឹង ហើយបញ្ជូនមកឲ្យលោកទាំងស្រុងតែម្តងជូន ឌី.ស៊ី.ខេម មជ្ឈមណ្ឌលឯកសារកម្ពុជានេះ។ តើមែនដែរឬទេ?

**ឆ៖** ខ្ញុំអាចដឹងបានថា ឯកសារនេះមាន ដោយសារថាឯកសារនេះបញ្ជូនមកតាមជើងយន្តហោះ យើងអាចដឹងបានថាឯកសារនេះមានទម្ងន់៥៥០គីឡូក្រាម ហើយដែលជា ដែលមានលិខិតបញ្ជាក់នៅក្នុងហ្នឹងតែម្តង។

[១៥:១៣:១១]

**ស៖** តើលោកបានដឹងដែរឬទេថា គណៈកម្មការដែលដឹកនាំលោក ហក នោះគឺគាត់ទទួលបាន និងគ្រប់គ្រងឯកសារនេះដោយរបៀបណា? ហើយថាតើគាត់ប្រមូលឯកសារនោះចេញមកពីប្រភពណាដែរ?

**ឆ៖** បាទ ជាទូទៅ ក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យដួលរលំទៅ គឺថាអ្នកដែលរស់រានមានជីវិតមិនមានការចាប់អារម្មណ៍ពីរឿងឯកសារទេ។ ហើយអ្នកដែលចាប់អារម្មណ៍ អ្នកដែលអាចដឹងអាចធ្វើការសិក្សាស្រាវជ្រាវ ពេលនោះគឺមានតាមអ្នកស្រាវជ្រាវដូចជាលោក ដេវីដ ហក ដូចជា លោកសាស្ត្រាចារ្យ ប៊ែន គៀរនិន ជាដើមដែលយល់ដឹងអំពីសារៈសំខាន់នៃប្រវត្តិសាស្ត្រនៃឯកសារ ហើយចូលមកធ្វើការសិក្សាស្រាវជ្រាវ។ បន្ទាប់មកគឺនៅពេលយើងបង្កើតមជ្ឈមណ្ឌលឯកសារកម្ពុជានៅឆ្នាំ

៩៥ គឺអ្នកទាំងអស់នោះយល់ថា មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងដែលផ្ទុកឯកសារ ជាកន្លែងដែលថារក្សាឯកសារមានលក្ខណៈត្រឹមត្រូវច្បាស់លាស់ និងអាចរក្សាឯកសារនេះបានគង់វង្សយូរអង្វែង ទើបបានផ្តល់ឯកសារនេះមកមជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីធ្វើការចងក្រងទុកដាក់តទៅមុខទៀត។

[១៥:១៤:៥៣]

**ឆះ** ដូច្នេះប្រសិនបើយល់ ខ្ញុំយល់ពីលោកដោយត្រឹមត្រូវនោះ គឺថានៅក្នុងករណីមួយចំនួនឯកសារទាំងអស់នោះ គឺប្រមូលនៅក្នុងប្រទេសកម្ពុជាដោយបុគ្គលមួយចំនួនដូចជា លោក ដេវីដ ហក។ ក្រោយមកឯកសារទាំងអស់នោះ គឺបានបញ្ជូន និងផ្តល់ជូនមក ឌី.ស៊ី.ខេម ក្រោយពី ឌី.ស៊ី.ខេម បានបង្កើតឡើង។ តើពិតជាត្រឹមត្រូវដែរឬទេ?

**ឆះ** បាទ ជាការត្រឹមត្រូវ។

**សះ** ចូលទៅដល់ប្រភេទឯកសារមួយទៀត ដែលលោកបានលើកឡើង ទើបតែបានលើកឡើងថា បុគ្គលមួយចំនួនដូចជា ដេវីដ ហក និងលោកសាស្ត្រាចារ្យ ប៊ែន ឃៀរនិន ដែលគាត់បានផ្តល់ជូនឯកសារមកឲ្យ ឌី.ស៊ី.ខេម ក្រោយពី ឌី.ស៊ី.ខេម បានបង្កើតឡើង។ តើមានបុគ្គលណាផ្សេង ឬក៏អ្នកសិក្សាស្រាវជ្រាវណាផ្សេង ដែលគាត់ប្រមូលឯកសារទាំងអស់នោះ ហើយបានផ្តល់ជូនមក ឌី.ស៊ី.ខេម ដែរឬទេ តាមដែលលោកចាំនោះ?

[១៥:១៦:០៧]

**ឆះ** ជាទូទៅ យើងអាចមើលដឹងបានថា តើឯកសារមួយណាដែលផ្តល់ដោយអ្នកណា។ ជាក់ស្តែងដូចជាឯកសារលោក ដេវីដ ហក បន្ទាប់ពីយើងធ្វើការចុះលេខអក្សរ “D” រួចហើយៗនៅខាងក្រោមនោះយើងមានដាក់លេខសម្គាល់មួយទៀត គឺអក្សរ “H” ដែលសម្គាល់ថា ជាឯកសាររបស់លោក ដេវីដ ហក។ បើសិនជាឯកសារដែលផ្តល់ដោយលោកសាស្ត្រាចារ្យ ប៊ែន ឃៀរនិន នៅពីក្រោមលេខអក្សរ “D” ហើយ គឺនៅពីក្រោមហ្នឹងគឺមានដាក់ឈ្មោះ ប៊ែន នៅក្រោមហ្នឹង ដើម្បីសម្គាល់ថា ឯកសារនេះយកបានទទួលមកពីលោកសាស្ត្រាចារ្យ ប៊ែន ឃៀរនិន ឬបានមកពីលោក ដេវីដ ហក។

**សះ** តើលោកចាំដែរឬទេ ថាតើមានអ្នកសិក្សាស្រាវជ្រាវ និងអ្នកចងក្រងប្រមូលឯកសារផ្សេងទៀត ដែលបានផ្តល់ឯកសារជូនមកកាន់លោក និងផ្តល់ជូនមកកាន់ ឌី.ស៊ី.ខេម ក្រៅពីលោក ដេវីដ ហក រួមជាមួយនឹងលោក ប៊ែន ឃៀរនិន នោះ?

**ឆះ** មានលោកសាស្ត្រាចារ្យ ដេវីដ ឆេនដ៍ល័រ ដែរ។

**ស៖** នៅពេលដែលលោកបានទទួលឯកសារពីអ្នកស្រាវជ្រាវណាម្នាក់ ដូចដែលលោកបានរៀបរាប់ ហើយឯកសារនោះវាបង្ហាញថា វាជាឯកសារកម្ពុជាប្រជាធិបតេយ្យ។ ថាតើលោកផ្ទៀងផ្ទាត់យ៉ាងម៉េច ទើបដឹងថា ឯកសារទាំងអស់នោះទំនងជាឯកសារកម្ពុជាប្រជាធិបតេយ្យ? ហើយវាមិនមែនជាឯកសារដែលក្លែងបន្លំ?

**ឆ៖** បាទ គឺចំពោះមជ្ឈមណ្ឌលឯកសារកម្ពុជា គឺយើងសួរផ្ទាល់ទៅអ្នកដែលផ្តល់ឯកសារហ្នឹងតែម្តង ដូចជា សាស្ត្រាចារ្យ ដេវីដ ឆេនដ័ល័រ គាត់ធ្វើការ ធ្វើដំណើរចុះឡើងៗស្រុកខ្មែរ ហើយគាត់បានមកធ្វើការស្រាវជ្រាវនៅមជ្ឈមណ្ឌលឯកសារកម្ពុជាដែរ។ អ៊ីចឹងការសាកសួរដូចជាមិនមានការលំបាក ហើយយើងសួរផ្ទាល់តែម្តង។

[១៥:១៨:៥៤]

**ស៖** តើលោកបានពិនិត្យមើលឯកសារហ្នឹងឡើងវិញដែរឬទេ នៅពេលដែលលោក ឡាវ៉ែន៍ គាត់បានលើកជាឧទាហរណ៍ឲ្យលោកបញ្ជាក់មើលឡើងវិញនោះ?

**ឆ៖** តើលោកព្រះរាជអាជ្ញាសំដៅទៅលើឯកសារមួយណាបាទ?

**ស៖** សូមអភ័យទោសបាទ! គឺខ្ញុំសួរបន្តពីចម្លើយមុននេះ ឯកសារដែលលោកបានទទួលពីអ្នកសិក្សាស្រាវជ្រាវ ហើយឯកសារនោះវាទំនងបង្ហាញថា ជាឯកសារមកសម័យកម្ពុជាប្រជាធិបតេយ្យ។ ក្រោយពីលោកដឹងអ៊ីចឹង តើលោកបានពិនិត្យមើលឯកសារហ្នឹងឡើងវិញ? មើលអំពីយថាភាពរបស់វា និងភាពស៊ីសង្វាក់នៃឯកសារទាំងអស់នោះទេ ដើម្បីកត់ត្រាឲ្យបានត្រឹមត្រូវនោះ?

**ឆ៖** បាទ ជាការពិតណាស់ ឧទាហរណ៍ជាក់ស្តែងដូចជា ឯកសារដែលទទួលបានពីលោកសាស្ត្រាចារ្យ ដេវីដ ឆេនដ័ល័រ។ យើងបានពិនិត្យមើលឯកសារហ្នឹង យើងបានអានដោយយកចិត្តទុកដាក់ យើងបានធ្វើការផ្ទៀងផ្ទាត់មើលអំពីខ្លឹមសារនៅក្នុងឯកសារ អំពីកាលបរិច្ឆេទដែលមាននៅលើឯកសារ អំពីប្រភេទភាសា ដែលប្រើប្រាស់នៅក្នុងឯកសារហ្នឹងជាដើម ដើម្បីធ្វើការផ្ទៀងផ្ទាត់មើលថាតើឯកសារ ហ្នឹង ជាឯកសារដែលពាក់ព័ន្ធទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យ ហៅថាខ្មែរក្រហម ឬក៏ជាឯកសារ យ៉ាងដូចម្តេច? យើងបានធ្វើការងារនេះ។

**ស៖** តើលោកទុកចិត្តដែរឬទេ តើលោកជឿជាក់លើខ្លួនឯងដែរទេ ក្រោយពីលោកមានបទពិសោធន៍ ១៧ឆ្នាំមកនោះ? ថាតើលោកជឿជាក់ថា ការវាយតម្លៃ និងការផ្ទៀងផ្ទាត់ទៅលើឯកសាររបស់លោកនោះ គឺពិតជាផ្ទៀងផ្ទាត់ និងធ្វើឡើងបានត្រឹមត្រូវដែរឬទេ?

[១៥:២១:០៤]

**ឆ៖** ដោយមានការធ្វើការងារនេះរយៈពេល ១៧ឆ្នាំ ហើយយើងមានការធ្វើការងារដោយយកចិត្តទុកដាក់ គឺចំពោះខ្ញុំផ្ទាល់ គឺខ្ញុំអាចវាយតម្លៃបានថា តើឯកសារហ្នឹងជាឯកសារខ្មែរក្រហម ឬមិនមែនតាមរយៈការអានដោយយកចិត្តទុកដាក់ តាមរយៈការធ្វើអង្កេតទៅលើខ្លឹមសារដែលមាននៅលើឯកសារ តាមរយៈការមើលកាលបរិច្ឆេទដែលមាននៅលើឯកសារ តាមរយៈការប្រើភាសានៅក្នុងឯកសារហ្នឹងតែម្តង។ អ៊ីចឹងជាបទពិសោធន៍ការងាររយៈពេល ១៧ឆ្នាំនេះ ខ្ញុំអាចមើលបាន វាយតម្លៃបាន។

**ស៖** ប្រសិនបើលោកសង្ស័យទៅលើយថាភាព ឬក៏ភាពដើមនៃឯកសារនោះ នៅគិតពេលដែលលោកវាយតម្លៃនោះ តើលោកនឹងធ្វើយ៉ាងម៉េច ចាត់វិធានការយ៉ាងម៉េចដើម្បីអាចផ្ទៀងផ្ទាត់ឲ្យបានត្រឹមត្រូវថា វាជាឯកសារមួយពិតប្រាកដនោះ?

**ឆ៖** ជាទូទៅបញ្ហានេះមិនសូវជាមានកើតឡើងច្រើនទេ ហើយបើសិនជាមានកើតឡើងក៏យើងមានអ្នកជំនាញនៅក្នុងការសិក្សាស្រាវជ្រាវ ដែលលោកធ្លាប់ធ្វើការសិក្សាស្រាវជ្រាវពីបញ្ហាកម្ពុជាជាពិសេសទាក់ទងទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង គឺយើងមានការធ្វើការសួរផ្ទៀងផ្ទាត់ពន្យល់ឲ្យពន្យល់អំពីលក្ខណៈឯកសារអំពីខ្លឹមសារអីជាដើម គឺយើងមានធ្វើការផ្ទៀងផ្ទាត់ជាមួយនឹងអ្នកជំនាញបាទ។

[១៥:២២:៥៦]

**ស៖** លោកបានលើកឡើងមុននេះថា លោកបានផ្តល់នូវកំណត់ហេតុ ឬក៏ឯកសារថតចម្លងមួយចំនួនទៅដល់អ្នកជំនាញដែលគេស្រាវជ្រាវនៅក្នុងរបបនោះ តើអ្នកផ្សេងនោះអ្នកទាំងអស់នោះ អ្នកស្រាវជ្រាវទាំងអស់នោះមានប្រាប់លោកដែរឬទេថា ឯកសារដែលលោកផ្តល់ជូនឲ្យគេនោះ ប្រហែលជាឯកសារដែលមានយថាភាពនោះទេ?

**ឆ៖** ចំពោះអ្នកសិក្សាស្រាវជ្រាវ នៅពេលដែលធ្វើការស្នើសុំឯកសារយកទៅធ្វើការសិក្សាលើប្រធានបទអ្វីមួយនោះ គឺថា យើងបានធ្វើការបញ្ជាក់ថា ឯកសារនេះជាឯកសារដែលយើងបានចងក្រងទុកដាក់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយយើងបានផ្តល់ឯកសារនេះទៅដល់អ្នកសិក្សាស្រាវជ្រាវទាំងអស់នោះឲ្យធ្វើការវាយតម្លៃ និងវិភាគខ្លួនឯងទៅលើឯកសារ ដោយយើងបានប្រាប់ថា យើងមិនធ្វើការវិភាគទៅលើឯកសារទាំងអស់នោះទេ។ អ៊ីចឹងវាស្រ័យទៅលើអ្នកសិក្សាស្រាវជ្រាវ ថាតើអ្នកទាំងនោះ ធ្វើការវាយតម្លៃ ធ្វើការវិភាគទៅលើឯកសារយ៉ាងម៉េចៗនោះ គឺអាស្រ័យទៅលើអ្នកដែលធ្វើ

ការសិក្សាស្រាវជ្រាវនោះ។

**ស៖** តាមការយល់ដឹងរបស់លោក ថាតើអ្នកជំនាញទាំងអស់នោះចេះនិយាយភាសាខ្មែរដែរឬទេ?

**ឆ៖** បាទដូចជាសាស្ត្រាចារ្យ ដេវីដ ឆេនដ៍ល័រ គាត់និយាយខ្មែរបានយ៉ាងច្បាស់លាស់។ លោកសាស្ត្រាចារ្យ ប៉ែន ឃៀរនិន និយាយភាសាខ្មែរបានយ៉ាងច្បាស់លាស់។

[១៥:២៤:៥៥]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកច្រើន។ នៅក្នុងពេលនេះ លោកប្រធាន ខ្ញុំសូមអនុញ្ញាតពីលោកប្រធាន សូមខ្ញុំសូមបង្ហាញនូវសំណុំឯកសារមួយចំនួនទៅដល់សាក្សី ដើម្បីធ្វើយ៉ាងណាឲ្យសាក្សីនោះអាចមើលដោយចោះៗ ដោយមួយភ្លែត ហើយដើម្បីអាចឲ្យគាត់អាចបង្ហាញអំពីសញ្ញាសម្គាល់ ដែលមាននៅក្នុងឯកសារនោះផង ដើម្បីអាចឲ្យយើងបង្ហាញការពិតបាន។ ថាតើវាជាឯកសារដើមដែរឬទេ? ប្រសិនបើសមស្របនៅពេលនេះ ខ្ញុំសូមអនុញ្ញាតបន្តបង្ហាញឯកសារនោះតែម្តង។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! សូមអញ្ជើញ!

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណច្រើន។

**ស៖** លោក ពៅដារ៉ា យើងខ្ញុំបានបង្ហាញ-- នឹងបង្ហាញលោកនូវឯកសារមួយចំនួនដែលឯកសារទាំងអស់នេះ គឺយើងបានទទួលមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា។ ប្រសិនបើខ្ញុំអាចនោះ គឺខ្ញុំសូមឲ្យលោកធ្វើការពិនិត្យមើល ហើយមើលសញ្ញាសម្គាល់ផ្សេងៗនៅលើឯកសារនោះ តើវាមានន័យយ៉ាងម៉េច? ដូច្នេះ ខ្ញុំសូមឲ្យខាងសហការីរបស់ខ្ញុំបង្ហាញឯកសារនោះនៅលើអេក្រង់។

[១៥:២៦:២១]

សូមអភ័យទោស ត្រូវការពេលមួយភ្លែត ប្រហែលជាយើងដូចជាមានបញ្ហាបន្តិចទៅលើបច្ចេកទេស។

ដូច្នេះហើយ ខ្ញុំសូមឲ្យបង្ហាញឯកសារនេះតែម្តងទៅ សូមអរគុណច្រើន។

លោក ដារ៉ាពៅ ប្រសិនបើលោកមើលឯកសារនេះ នៅជ្រុងខាងស្តាំ ខាងលើ យើងឃើញមានអក្សរ និងតួលេខចំនួនពីរខុសគ្នា។ តើលោកអាចបញ្ជាក់ដែរឬទេ ថាតើលេខដែលមានចាប់ផ្តើមដោយ

អក្សរ “D” នោះមានន័យយ៉ាងម៉េច?

**ឆ៖** ដូចខ្ញុំបានជម្រាបពីខាងដើម គឺរាល់ឯកសារត្រូវបានចុះលេខសម្គាល់ដោយផ្ដើមឡើងដោយមានតួអក្សរមួយ ហើយបន្ទាប់មក គឺលេខ។ ចំពោះអក្សរ “D” នេះ វាមិនមានន័យជាផ្លូវច្បាប់ ជាផ្លូវអីនោះទេ ប៉ុន្តែយើងបានដឹងថា អក្សរ “A”, អក្សរ “B”, អក្សរ“C” ត្រូវបានគេប្រើប្រាស់រួចហើយ។ អ៊ីចឹងនៅអក្សរ “D”។ ហើយអក្សរ “D” នេះ វាមកពីពាក្យមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលជាភាសាអង់គ្លេសថា “*ដុកខ្យូមិនថេស៊ិន សិនធ័រ អហ្វ ខេមបូឌា*”។ អ៊ីចឹងយើងជ្រើសរើសយក “D” នេះមកធ្វើជាលេខសម្គាល់សម្រាប់ឯកសារនេះ។ ហើយនៅខាងលើបង្អស់ គឺផ្ដើមដោយអក្សរ “D” ហើយនិងមានលេខ។ ហើយលេខនេះ គឺយើងចុះបន្តបន្ទាប់ទៅតាមចំនួនឯកសារដែលមាន។ នៅខាងក្រោមលេខសម្គាល់“D” ហើយនិងមានលេខនេះ គឺមានក្នុងរង្វង់ក្រចកមួយដែលសរសេរពាក្យថា “០៩ បបក”។ នេះគឺជាការចុះលេខដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបង្ហាញអំពី ថាតើឯកសារនេះប្រភពដើមមាននៅកន្លែងណា? ព្រោះនៅពេលដែល យើងទទួលឯកសារដើម គឺយើងមិនបានធ្វើការប៉ះពាល់ ឬក៏អនុញ្ញាតឲ្យអ្នកសិក្សាស្រាវជ្រាវណាប៉ះពាល់ទៅលើឯកសារដើមទេ។

អ៊ីចឹងដើម្បីឲ្យឯកសារនេះ អាចបម្រើដល់សាធារណជន ដល់អ្នកសិក្សាស្រាវជ្រាវ យើងថតចម្លងឯកសារនេះ ហើយយើងយកចុះលេខនៅលើឯកសារ។

[១៥:២៩:១៧]

អ៊ីចឹងដើម្បីឲ្យឯកសារថតចម្លងនេះ អាចផ្ទៀងផ្ទាត់បានទៅនឹងឯកសារដើម ដើម្បីរកឯកសារដើមឲ្យងាយស្រួលរកឃើញ គឺយើងត្រូវចុះប្រភពនៃឯកសារនៅពីខាងក្រោមលេខរបស់ឯកសារនីមួយៗ។

**ស៖** សូមអរគុណ។ សំណួរ នៅក្នុងជើងទំព័រខាងក្រោម ដែលក្នុងនោះបានលើកឡើងឯកសារដីកាបញ្ជូនរឿងទៅស៊ើបសួរ លេខឯកសារ IS21.18 ដែលនៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញានៅក្នុងសវនាការវគ្គដំបូង។ ប្រសិនបើងយើងពិភាក្សាឯកសារនេះបន្តិចទៅ លោកបានបញ្ជាក់ថាលេខលំដាប់លំដោយនេះគឺចាប់ផ្ដើមដោយអក្សរ ឌី ឬអក្សរ “D” ហើយវាដាក់ទៅតាមលំដាប់លំដោយនៃឯកសារដែលបង់ដោយ ឌី.ស៊ី.ខេម តើលោកអាចនិយាយពន្យល់បន្ថែមដែរឬទេ ថាតើលេខដែលនៅក្នុងរង្វង់ក្រចកខាងក្រោមអក្សរ “D” និងតួលេខនេះ វាពាក់ព័ន្ធ និងជាប់ពាក់ព័ន្ធទៅនឹងអ្វីដែរ? ហើយចេញមកពីប្រភពណាដែរ? ហើយខ្ញុំសូមបង្ហាញឯកសារនេះសាជាថ្មី ដើម្បីឲ្យសាក្សីមើលឃើញ។

សូមអរគុណ។ ដូច្នេះយើងឃើញថា អក្សរនៅខាងក្រោមហ្នឹង ដែលនៅក្រោម “D” ហ្នឹង តើវា

មានន័យយ៉ាងម៉េចអក្សរហ្នឹង? ហើយលេខហ្នឹង?

[១៥:៣១:១១]

**ឆ៖** បាទ ដូចខ្ញុំបានជម្រាបអ៊ីចឹងគឺថា អក្សរ និងលេខនៅខាងក្រោមហ្នឹងគឺ វាប្រាប់អំពីប្រភពនៃឯកសារដើម។ ហើយអក្សរនេះគឺយើងដាក់ទៅតាមបណ្ដុំឯកសារ ដែលយើងទទួលបានជាដុំៗ។ បាទ ជួនកាលឯកសារយើង ពេលដែលយើងទទួលបានវាមកជាសំណុំឯកសារមួយដុំ ហើយនៅក្នុងឯកសារហ្នឹងនៅពេលដែលវាមានឯកសារបន្តបន្ទាប់ជាសន្លឹក ជាក្រដាសហ្នឹងបន្តបន្ទាប់មក។ អ៊ីចឹងនៅពេលដែលយើងចុះលេខ គឺយើងត្រូវចុះលេខនៅក្នុងឯកសារ យកឯកសារមកដុំហ្នឹងមកធ្វើការចុះលេខ ដូច្នេះដើម្បីឱ្យដឹងថា ឯកសារដែលយើងចុះលេខមួយសន្លឹកនេះ វាជាឯកសារចេញពីបណ្ដុំឯកសារមួយណា។ អ៊ីចឹងយើងត្រូវដាក់ឯកសារ ដាក់លេខសម្គាល់នៅខាងក្រោមមួយនេះ ឱ្យដឹងថាឯកសារមួយសន្លឹកនេះគឺចេញពីបណ្ដុំឯកសារដើមមួយណា។

[១៥:៣២:២៩]

**ស៖** វាហាក់ដូចជាមានការពិបាកបន្តិច ដោយសារតែយើងកំពុងពិភាក្សាទៅលើឯកសារច្រើន។ តើឯកសារនេះលោកអាចកំណត់អត្តសញ្ញាណវាដែរឬទេ? នៅពេលដែលលោកមើលអក្សរ ឬលំដាប់លំដោយ នៃលេខដែលបានដាក់នោះ តើលោកដឹងថាចេញពីប្រភពនោះមកពីណា?

**ឆ៖** ជាការពិតណាស់នៅពេលដែលឃើញឯកសារភ្លាម ខ្ញុំដឹងថាឯកសារហ្នឹងត្រូវបានថតចម្លងចេញពីឯកសារដើមនៅដុំមួយណា។ ហើយបើសិនជាមានការស្នើសុំលើឯកសារដើម គឺយើងអាចទៅយកឯកសារដើមនោះមកជូន ដោយអត់មានការភ័ន្តច្រឡំ ព្រោះពួកយើងដឹងពីប្រភពរបស់វានៅក្នុងឯកសារដែលយើងថតចម្លង។

**ស៖** ប្រសិនបើសុំបង្ហាញអេក្រង់ខាងខ្ញុំ ដោយសង្ខេបរយៈពេលមួយភ្លែតទៅ។ ដោយសារយើងរកឯកសារនោះតាមឯកសារមូលដ្ឋានទិន្នន័យ និងឯកសារ "D"។ ដូច្នេះ សូមឱ្យបង្ហាញអេក្រង់ខាងខ្ញុំ។

តើយើងអាចសុំបង្ហាញតាមអេក្រង់បានទេ នេះជាការពិត គឺជាឯកសារមកពី-- នេះជា*វេបសាយ*របស់ ឌី.ស៊ី.ខេម ហើយសហការីរបស់ខ្ញុំកំពុងតែវាយលេខនេះចូល គឺលេខដែលយើងបានឃើញ D01648។ ខ្ញុំដឹងថាមើលទៅមិនច្បាស់ទេ នៅលើអេក្រង់ ក៏ប៉ុន្តែខ្ញុំសង្ឃឹមថា លោកអាចកំណត់ទំព័រនេះបាន។ លោក ដាវ៉ាពៅ ថាតើយើងកំពុងតែមើលទំព័រទីប៉ុន្មានដែរ?

[១៥:៣៤:៣៩]

**ឆ៖** លោកព្រះរាជអាជ្ញាសួរទំព័រយ៉ាងម៉េច? នៅក្នុងនេះ ខ្ញុំបានឃើញជាលទ្ធផល *ស៊ើចពី វេបសាយ* របស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ គឺលេខ *អាយ.ឌី* ឯកសារហ្នឹង គឺ D01648 ហើយឯកសារនេះគឺមានការបរិច្ឆេទរបស់វាថ្ងៃ១៨ ខែ៦ ឆ្នាំ៧៧។ ហើយយើងបានប្រមូលឯកសារនេះ ពីក្រសួងមហាផ្ទៃនៅក្នុងឆ្នាំ១៩៩៩ ហើយឯកសារនេះគឺមាននៅក្នុងសំណុំឯកសារដើមរបស់វា គឺលេខ "09 បបក" ដែលអង់គ្លេសនៅក្នុងនេះដាក់ថា "bbk"។ អ៊ីចឹង ពេលដែលមានការស្នើសុំឯកសារដើមណាមួយរបៀបនេះគឺយើងដឹងភ្លាមថាឯកសារនៅកន្លែងណា ហើយឯកសារនៅក្នុងសំណុំឯកសារមួយដុំ នៅដុំមួយណា។

**ស៖** លោក សូមអរគុណលោក។ លោកបានឆ្លើយទៅនឹងសំណួរខ្ញុំពេញលេញហើយ ហើយប្រសិនជាខ្ញុំអាចបង្ហាញនូវឯកសារមួយផ្សេងទៀត គឺឯកសារនេះ ក៏មាននៅក្នុងសំណុំរឿងដែរគឺ D83-001 ហើយសូមឲ្យ-- ខ្ញុំសូមឲ្យមន្ត្រីតុលាការបង្ហាញជូននៅលើអេក្រង់កុំព្យូទ័រ។ សូមអរគុណច្រើន។ លោក ដារ៉ាពៅ បើសិនជាមើលទៅលើឯកសារនេះ តើលោកអាចកំណត់អំពីលេខ "D" តាមលំដាប់លំដោយនេះ ដែលដូចដែលលោកបានបង្ហាញពីខាងមុននោះ បានដែរឬទេ?

[១៥:៣៦:៥៥]

**ឆ៖** បាទ នៅក្នុងឯកសារបង្ហាញនេះ គឺមានឯកសារលេខ D13527 ហើយនៅខាងក្រោមលេខនេះគឺមានដាក់អក្សរ TSL1813 គឺជាការចុះលេខឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ ហើយលេខនៅខាងក្រោមដែលដាក់អក្សរថា TSL1813 នេះ គឺសំដៅទៅលើឯកសារដែលឯកសារដើមរបស់វានៅទួលស្លែង គឺនៅក្នុងលេខ 13 និងដប់-- 1318។ អ៊ីចឹង បើសិនជាមានការស្នើសុំផ្ទៀងផ្ទាត់ ឬក៏ស្នើសុំឯកសារដើម យើងដឹងភ្លាមថា ឯកសារនេះគឺជាឯកសារដើមរបស់វានៅទួលស្លែង ហើយបើសិនជារកឲ្យងាយស្រួលគឺនៅក្នុង-- នៅទួលស្លែងគឺមានការចុះលេខរបស់ទួលស្លែងគឺ TSL1813 ទៅរកឃើញភ្លាម។

**ស៖** តើពាក្យថា TSL នេះ វាបញ្ជាក់ពាក្យខ្មែរថា ទួលស្លែង អ៊ីចឹងមែនទេ?

**ឆ៖** ជាការត្រឹមត្រូវ។

**ស៖** យើងខ្ញុំមានចង់បង្ហាញនូវឯកសារនេះ ដោយរកឃើញនៅតាម*វេបសាយ*ដែល ដែលយើងបង្ហាញដូចបង្ហាញឯកសារមុននេះ។ សូមឲ្យមន្ត្រីតុលាការរកមើលនៅក្នុង*វេបសាយ*។ សូមអរគុណច្រើន។ នៅពេលដែលលោកអានឯកសារ D13527 ជាថ្មីម្តងទៀត សូមលោកមេត្តាពន្យល់ជាសង្ខេប

ទៅលើចំណុចនេះបានម្តងទៀតទេ?

**ឆ៖** បាទ អរគុណ។ ឯកសារនេះ មានលេខ*អាយ.ឌី. ណាំប៊ើ* របស់ឯកសារនេះគឺ D13527។ ឯកសារនេះត្រូវបានប្រមូលចងក្រងនៅក្នុងឆ្នាំ១៩៩៩ ហើយជាឯកសារដែលមានប្រភពនៅទួលស្លែង ដែលមានដាក់នៅក្នុងរង្វង់ក្រចកថា TSL1813។

[១៥:៣៩:៥២]

**សៈ** សូមអរគុណលោកច្រើន ហើយយើងសូមចូលទៅឯកសារមួយទៀត ដើម្បីឲ្យមានការកត់ត្រាឲ្យត្រឹមត្រូវ គឺថាឯកសារនេះ គឺD243.2.1.1។ សូមឲ្យមន្ត្រីតុលាការបង្ហាញឯកសារនេះ។

សូមអរគុណច្រើន។ ពេលមើលឯកសារនេះទៅ តើលោកអាចបញ្ជាក់បានថាឯកសារនេះ ជាឯកសារអ្វីដែរ?

**ឆ៖** បាទ ជាឯកសារទង់បដិវត្ត ហើយដែលឯកសារនេះគឺធ្វើការស្កេនចេញពីឯកសារទង់បដិវត្ត ដែលមាននៅមជ្ឈមណ្ឌលឯកសារកម្ពុជា។ តាមពិតទៅឯកសារទង់បដិវត្តនេះ ទង់របស់វាមិនមែនមានពណ៌ដូចឃើញនៅក្នុងអេក្រង់ ឃើញក្នុងកញ្ចក់ទូរទស្សន៍នេះទេ គឺច្បាប់ដើមរបស់វាមានពណ៌ក្រហម។

[១៥:៤១:១៦]

**សៈ** នៅក្នុងករណីនេះ គឺថាឯកសារនេះត្រូវបានស្កេនចេញមក ប៉ុន្តែមិនមានលេខ “D” នោះទេ នៅផ្នែកខាងលើ ខាងស្តាំ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ ម៉េចក៏មិនមានលេខបែបហ្នឹង?

**ឆ៖** ដោយសារឯកសារនេះស្កេនចេញពីឯកសារដើម អ៊ីចឹងដូចខ្ញុំបានជម្រាបពីខាងដើម គឺថាឯកសារដើមយើងមិនមានធ្វើការប៉ះពាល់ចុះលេខទៅលេខឯកសារដើម ឬក៏សរសេរទៅលើឯកសារដើមទេ។ អ៊ីចឹងដូច្នេះការដែលធ្វើការស្កេនឯកសារចេញពីឯកសារដើម នោះលោក លោកស្រីនឹងឃើញនៅលើឯកសារនេះ គឺអត់មានឯកសារ“D” ឬឯកសារ-- លេខឯកសារដែលភ្ជាប់មកជាមួយទេ ព្រោះវាជាឯកសារដើម។ ហើយដោយសារឯកសារដើម គឺយើងមិនបានធ្វើការចុះលេខទៅលើឯកសារដើមទៅលើឯកសារដើមបែបនេះទេ។

[១៥:៤២:២៤]

**សៈ** សូមអរគុណលោកច្រើន។ ប្រហែលជាខ្ញុំរួតសុំចូលទៅមើលឯកសារនេះនៅក្នុងទិន្នន័យ ដើម្បីមើលលេខ “D” *ណាំប៊ើ* ដែលយើងនិយាយអំពីបញ្ជាឯកសារចេញនៅខែសីហា ១៩៧៧ ហើយសហការីរបស់ខ្ញុំកំពុងតែស្វែងរកនៅក្នុង*វេបសាយ*នេះ វាទាក់ទងទៅនឹងឯកសារទង់បដិវត្តនេះ ដោយ

សារថាយើងជួបបញ្ហាចម្រូងចម្រាសទៅលើឯកសារនេះ។ តើនេះវាឆ្លើយតប លោក ដាវ៉ាពៅ វាឆ្លើយតបទៅនឹងឯកសារដែលទើបមើលអម្បាញ់មិញនេះដែរឬទេ? ដោយគ្រាន់តែលោកពន្យល់អំពីកាលបរិច្ឆេទ និងចំណុចសំខាន់ៗនេះ?

**ឆ៖** បាទ សំណួរអាចចោទសួរថា ហេតុអីបាននៅក្នុងបញ្ជីឯកសារនេះ យើងមានឃើញលេខ *អាយ.ឌី* ឯកសារ គឺលេខD21410 ព្រោះឯកសារនេះ យើងបានធ្វើកាតាឡុកចេញពីឯកសារថតចម្លង។ អ៊ីចឹងនៅលើឯកសារថតចម្លង យើងអាចចុះលេខសម្គាល់របស់វានៅលើឯកសារថតចម្លង។ នៅពេលដែលយើងយកមកធ្វើកាតាឡុក គឺយើងមានលេខឯកសារនេះជាប់នៅលើឯកសារថតចម្លងតែម្តង។ ហើយឯកសារនេះគឺមានចុះកាលបរិច្ឆេទ ខែ៨ ឆ្នាំ៧៥ ហើយយើងប្រមូលនៅក្នុងឆ្នាំ១៩៩៩។ ហើយឯកសារដើមរបស់វា គឺនៅសារមន្ទីរទួលស្លែង នៅក្នុងនេះ យើងដាក់ថា TSL ដែលជាអក្សរកាត់សម្គាល់ទួលស្លែង។

[១៥:៤៤:១៥]

**ស៖** សូមអរគុណច្រើន។ លោកបានពន្យល់នៅក្នុងទិន្នន័យនេះអំពីប្រភពឯកសារដែលបានមកពីទួលស្លែង។ ជាសង្ខេបទៅមានន័យថា ឯកសារដើមនេះ គឺឯកសារយើងបានមកពីឯកសារដើមដែលមាននៅទួលស្លែងមែនទេ?

**ឆ៖** បាទ ជាការត្រឹមត្រូវ។

**ស៖** យោងទៅលើការស្រាវជ្រាវរបស់លោក តើមានហេតុផលណាជាក់លាក់ដែលថា គេអាចជួបប្រទះទៅនឹងបញ្ហាដូចជា ទស្សនាវដ្តីបដិវត្ត គេអាចនឹងរកបាននៅទីនោះទេ តាមការស្រាវជ្រាវរបស់លោក?

[១៥:៤៥:00]

**ឆ៖** សូមលោកព្រះរាជអាជ្ញាបញ្ជាក់ឲ្យបានច្បាស់ម្តងទៀត ដោយការបកប្រែថា រកឃើញនៅទីនោះ។ ទីនោះចង់សំដៅទៅលើទីកន្លែងនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ឬក៏នៅទួលស្លែងបាទ?

**ស៖** គឺថាទីតាំងរបស់វា គឺលោកបានបញ្ជាក់ថា វាស្ថិតនៅទួលស្លែងឯកសារដើមនោះ។ សំណួររបស់ខ្ញុំ គឺយោងទៅតាមការស្រាវជ្រាវរបស់លោក ថាតើហេតុអីបានជាលោកអាចរកបានឯកសារដើមនេះនៅទួលស្លែង?

**ឆ៖** បាទ នៅពេលដែលយើងចុះធ្វើការស្រាវជ្រាវនៅទួលស្លែង គឺដូចខ្ញុំបានជម្រាបពីខាងដើម

ថាឲ្យតែឯកសារទាក់ទងទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យ ឬក៏អំពីរបបកម្ពុជាប្រជាធិបតេយ្យ គឺយើងប្រមូលយកមកចងក្រង និងថែរក្សាទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា។ អ៊ីចឹងដោយសារឯកសារទង់បដិវត្តនេះមានថែរក្សាទុកនៅទួលស្លែង គឺយើងធ្វើការថតចម្លងយកទុកដាក់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីបម្រើដល់ការសិក្សាស្រាវជ្រាវផ្សេងៗ ដែលសាធារណជន ក៏ដូចជានិស្សិត ក៏ដូចជាសិស្សចង់ធ្វើការសិក្សាស្រាវជ្រាវអំពីរបបកម្ពុជាប្រជាធិបតេយ្យ។

[១៥:៤៦:៥១]

**ស៖** តើឯកសារដើមនៃឯកសារទង់បដិវត្តនេះយើងអាចរកបាននៅទីកន្លែងផ្សេងៗគ្នា ឬក៏យ៉ាងម៉េចដែរនៅក្នុងអំឡុងនៃកម្ពុជាប្រជាធិបតេយ្យនោះ? ក្រោយមកយើងអាចរកនៅកន្លែងផ្សេងៗគ្នា បានឬយ៉ាងណា?

**ឆ៖** បាទ ជាក់ស្តែងឯកសារទង់បដិវត្តនេះ យើងក៏អាចទទួលបានពីបុគ្គល និងពីកន្លែងផ្សេងៗទៀត ដែលក្រៅពីនៅទួលស្លែង។ ហើយដោយសារថា ឯកសារទង់បដិវត្តនេះត្រូវបានផ្សព្វផ្សាយទៅដល់កម្មាភិបាលរបស់កម្ពុជាប្រជាធិបតេយ្យហ្នឹង។ អ៊ីចឹងឯកសារនេះវាអាចស្ថិតនៅក្នុងដៃរបស់បុគ្គល ហើយបុគ្គលនោះអាចនៅជុំវិញ នៅក្នុងទីក្រុងភ្នំពេញ អ៊ីចឹងពេលដែលរបបនេះដួលរលំទៅ គឺថាឯកសារនេះវាអាចនៅផ្ទះណាមួយ វាអាចថានៅដៃបុគ្គលណាមួយ ឬក៏បុគ្គលនោះពេលដែលចូលមកដល់ គឺថាកាន់កាប់ផ្ទះណាមួយអ៊ីចឹង គឺអាចរកបាន អាចប្រទះឃើញនូវឯកសារទង់បដិវត្តប្រភេទនេះបាន។

[១៥:៤៨:១៩]

**ស៖** ខ្ញុំសូមបង្ហាញជូននូវឯកសារមួយទៀត នៅពេលដែលយើងនៅសល់ពេលតិចតួចខ្លះដែរ។ គឺឯកសារ D366/7.1.331 ឯកសារនេះមាននៅក្នុងសំណុំរឿងហើយ ៗក៏មាននៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញានេះផងដែរ។ ខ្ញុំសូមឲ្យមន្ត្រីតុលាការបង្ហាញជូនឯកសារនេះនៅលើអេក្រង់កុំព្យូទ័រ។

សូមអរគុណច្រើន ដោយសារពេលវេលាវាមានកំណត់លោក ដារ៉ាពៅ។ តើលោកអាចពន្យល់អំពីលំដោយលេខ “D” នេះ ដូចដែលលោកបានពន្យល់លើកមុននោះបានឬទេ?

[១៥:៤៩:១២]

**ឆ៖** បាទ ឯកសារនេះ គឺមានឯកសារលេខ D20476 ដែលជាលេខផ្តល់ឲ្យឯកសារនេះដោយ

មជ្ឈមណ្ឌលឯកសារកម្ពុជា។ ហើយនៅក្នុងរង្វង់ក្រចកខាងក្រោម ក៏ជាការសរសេរដោយមជ្ឈមណ្ឌលឯកសារកម្ពុជាដែរ ដើម្បីកំណត់សម្គាល់ថា ឯកសារនេះ គឺជាឯកសារថតចម្លងពីឯកសារដើមនៅបណ្ណសារដ្ឋានជាតិ ៗដែលមានអក្សរកាត់ “ANC” ហើយនៅក្នុងលេខ៣៧ នៅក្នុងប្រអប់០៨។ ពេលដែលយើងចង់រកឯកសារដើម គឺយើងទៅបណ្ណសារដ្ឋានជាតិ ប្រាប់ថាលេខ៣៧ ប្រអប់០៨ នោះយើងនឹងរកឃើញឯកសារនេះភ្លាម។

[១៥:៥០:១០]

**ស៖** សូមអរគុណលោកច្រើន។ ដោយសារនៅសល់ពេលវេលាតិចតួចខ្លះដែរ អ៊ីចឹងខ្ញុំសូមចូលទៅបញ្ហាដាច់ដោយឡែកមួយផ្សេងទៀត ទាក់ទងទៅនឹងទំនាក់ទំនងរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និង អ.វ.ត.ក នេះ។ តើមជ្ឈមណ្ឌលឯកសារកម្ពុជាផ្តល់ជំនួយការណាមួយមកដល់អង្គភាពគាំពារសាក្សីនៅក្នុងការរៀបចំឯកសារណាមួយនោះដែរ ឬទេ?

**ឆ៖** ខ្ញុំសូមសួរបញ្ជាក់អង្គភាពគាំពារសាក្សី លោកសួរ។ ចំពោះអង្គគាំពារសាក្សី មិនថាតែអង្គភាពគាំពារសាក្សី មិនថាអង្គភាពការពារក្តី ឲ្យតែមានការស្នើសុំឯកសារ យើងផ្តល់ជូន យើងមិនបានធ្វើការផ្តល់ជូនឯកសារណាមួយដែលមិនមានការស្នើសុំ។ ព្រោះការស្នើសុំមានការបញ្ជាក់លេខឯកសារមួយច្បាស់លាស់។ អ៊ីចឹងបើសិនជាមានការស្នើសុំ នោះនឹងមានការបញ្ជាក់លេខឯកសារច្បាស់លាស់ ហើយយើងនឹងអាចរកឯកសារនោះជូនបាន។

[១៥:៥១:៤៧]

**ស៖** សូមអរគុណច្រើន ប្រហែលជាសំណួរខ្ញុំមិនច្បាស់។ ខ្ញុំសំណួរខ្ញុំគឺទាក់ទងការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី តើ ឌី.ស៊ី.ខេម មានជួយសម្របសម្រួលដើម្បីឲ្យអ្នកទាំងនោះដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែរឬទេ?

**ឆ៖** បាទមាន។

**ស៖** តើជំនួយការបែបណា ដែល ឌី.ស៊ី.ខេម ជួយមកដល់អង្គភាពនេះ?

**ឆ៖** ខ្ញុំបានធ្វើការងារផ្ទាល់លើកិច្ចការងារ ការស្នើសុំឯកសារនេះតែម្តង គឺថាសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី គឺតាមរយៈមេធាវី ឬតាមរយៈបុគ្គលជាដើមបណ្តឹងរដ្ឋប្បវេណីហ្នឹងផ្ទាល់ ដែលមានឯកសារៗដែលទាក់ទងទៅនឹងៗសាច់ញាតិដែលបានស្លាប់បាត់បង់ជីវិតនោះ ហើយបានស្នើសុំឯកសារហ្នឹង ដើម្បីយកទៅធ្វើការគាំទ្រដល់ឯកសារពាក្យបណ្តឹងរបស់ខ្លួន តាមរយៈការស្នើសុំនេះ យើងបាន

ផ្តល់ឯកសារនេះជូនតាមសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក៏ដូចជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ដែលមានការស្នើសុំមក។

**ស៖** ហើយលោកបានបញ្ជាក់ពីខាងដើមថា ជំនួយការនេះ គឺថាលោកជួយគ្រប់ភាគីទាំងអស់ បើសិនជាខ្ញុំយល់ច្រឡំសូមបញ្ជាក់ គឺថាភាគីណាក៏ដោយដែលចូលរួមនៅក្នុងដំណើរការនីតិវិធីនេះ គឺលោកនឹងជួយទាំងអស់មែនទេ?

**ឆ៖** ជាការពិត បាទខ្ញុំអាចរៀបរាប់បាន រួមទាំងក្រុមមេធាវីការពារក្តីទៀតផង មិនត្រឹមតែថា ដើមបណ្តឹងរដ្ឋប្បវេណី ការិយាល័យរបស់សហព្រះរាជអាជ្ញា ការិយាល័យរបស់សហចៅក្រមស៊ើបអង្កេត គឺគ្រប់ភាគីទាំងអស់មានការស្នើសុំឯកសារ។

[១៥:៥៤:១៨]

**ស៖** លោក ដារ៉ាពៅ ចំពោះអ្នកណាម្នាក់ដែលត្រូវបានទទួលការចោទប្រកាន់ ដោយសារថា មជ្ឈមណ្ឌលឯកសារកម្ពុជានេះបានបញ្ជាក់អំពីឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ហេតុដូច្នេះមានការចោទប្រកាន់ថា មជ្ឈមណ្ឌលឯកសារកម្ពុជាមានភាពលម្អៀងមិនអាចគួរឲ្យទុកចិត្តបាន លោកអាចជួយពន្យល់ បើគេចោទបែបនេះលោកអាចឆ្លើយដោយរបៀបណាដែរ?

**ឆ៖** ទីមួយគឺយើងបានបញ្ជាក់ពីខាងដើមថា មជ្ឈមណ្ឌលឯកសារកម្ពុជា មានគោលដៅសំខាន់ពីរ គឺយើងចងក្រងឯកសារ ប្រមែប្រមូលឯកសារ ចងក្រងឯកសារ ដើម្បីបម្រើដល់ការចងចាំទៅដល់ផ្នែកប្រវត្តិសាស្ត្រ។ ទីពីរ គឺយើងចងក្រងឯកសារ ដើម្បីផ្តល់ជូន យើងប្រើពាក្យ ជនទាំងឡាយណា ឬក៏អ្នកណា ដែលចង់ស្វែងរកយុត្តិធម៌ជូនដល់អ្នករស់រានមានជីវិតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺយើងបានផ្តល់ជូន។

អ៊ីចឹងដោយយោងទៅតាមគោលបំណងរបស់ខ្លួននេះ គឺថាយើងបានផ្តល់ជូនមកអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយយើងបានផ្តល់គ្រប់ភាគីទាំងអស់ ហើយយើងបានផ្តល់ជូននេះដោយមិនមានការរឹតត្បិត គឺផ្តល់ជូនទៅតាមការស្នើសុំ។ ឲ្យតែមានការស្នើសុំ គឺយើងផ្តល់ជូន ហើយយើងមិនផ្តល់ជូនត្រឹមតែតុលាការ យើងផ្តល់ជូនដល់អ្នកដែលធ្វើការសិក្សាស្រាវជ្រាវ ធ្វើការសិក្សាអំពីរបបកម្ពុជាប្រជាធិបតេយ្យ។ យើងផ្តល់ដល់អ្នកសារព័ត៌មាន យើងផ្តល់ដល់និស្សិត ដល់សិស្ស ដែលបានមកធ្វើការស្រាវជ្រាវលើឯកសារនេះ។

[១៥:៥៦:២៨]

ចំណុចសំខាន់ គឺថាមជ្ឈមណ្ឌលឯកសារកម្ពុជាមិនធ្វើការវិភាគទៅលើឯកសារដែលខ្លួនប្រមែប្រមូល និងទទួលបានទេ។ គឺឯកសារមកយ៉ាងដូចម្ដេច គឺនៅជាឯកសារអ៊ីចឹង គឺអ្នកដែលទទួលយកទៅប្រើប្រាស់ ធ្វើការវិភាគខ្លួនឯង វាយតម្លៃ ធ្វើការវិភាគ ធ្វើការសិក្សាខ្លួនឯង គឺយើងមិនបានធ្វើការវិនិច្ឆ័យទៅលើឯកសារនេះទេ។ សូមកែតម្រូវ គឺថាយើងមិនបានធ្វើការវិភាគទៅលើឯកសារនេះទេ។

**ស៖** ហើយតើលោកឆ្លើយទៅនឹងការចោទប្រកាន់ដែលថា ដោយសារតែមជ្ឈមណ្ឌលឯកសារកម្ពុជាបង្កើតឡើងដោយរដ្ឋាភិបាលបរទេស នេះបើយើងគិតទៅដល់ការបង្កើតនៅឆ្នាំ១៩៩៥។ ហេតុដូច្នេះឯងទើបថា អង្គការមួយនេះមិនអាចគួរឲ្យទុកចិត្តបានទេ អាចនឹងមានភាពលម្អៀង។ តើការចោទប្រកាន់បែបនេះ លោកគិតថាត្រឹមត្រូវដែរទេ?

[១៥:៥៧:៤៤]

**ឆ៖** ខ្ញុំប្រកាន់យកជំហរដែលបានឆ្លើយជូនពីខាងដើមអំពីថា តើបើសិនជាមានការចោទប្រកាន់ថា មជ្ឈមណ្ឌលឯកសារកម្ពុជាមានលម្អៀង ឬមិនលម្អៀង។ ខ្ញុំសូមប្រកាន់យកអ្វីដែលខ្ញុំបានឆ្លើយពីខាងដើមមុននេះ។

**ស៖** សូមអរគុណច្រើនណាស់ ខ្ញុំគិតថាវាលើសពីអ្វីដែលច្បាស់លាស់ហើយ ហើយយើងអស់ពេលម៉ោងហើយនោះ។ នៅក្នុងដំណាក់កាលនេះ លោកប្រធាន ខ្ញុំគិតថាម៉ោងបួនហើយ ហើយខ្ញុំសូមប្រគល់ទៅដល់សហការីជាតិរបស់ខ្ញុំ តើអនុញ្ញាតឲ្យបន្ត ឬក៏សហការីជាតិរបស់ខ្ញុំគួរបន្តនៅព្រឹកស្អែកលោកប្រធាន?

[១៥:៥៨:៣២]

**ប្រធានអង្គជំនុំ៖**

បាទអរគុណច្រើន សហព្រះរាជអាជ្ញារងអន្តរជាតិ។ អរគុណសាក្សី ពេលវេលាសមល្មមនឹងសម្រាកហើយ ចំណែកឯកសារសហព្រះរាជអាជ្ញារងជាតិនោះ គឺទុកពេលវេលាបន្តទៅព្រឹកថ្ងៃស្អែក។ ហើយអង្គជំនុំជម្រះសូមជម្រាបលោកសាក្សីថា អង្គជំនុំជម្រះនៅក្នុងកិច្ចដំណើរការសវនាការស្ដាប់សក្ខីកម្មរបស់លោកនៅមិនទាន់ចប់នៅឡើយទេ នៅត្រូវបន្តនៅធ្វើនៅថ្ងៃស្អែកទៀតចាប់ពីម៉ោងប្រាំបួនព្រឹក។

ដូច្នេះសាក្សី អង្គជំនុំជម្រះអញ្ជើញលោកមកចូលរួម មកផ្ដល់សក្ខីកម្មនៅ-- ដោយមានវត្តមាននៅក្នុងសាលសវនាការនេះ ចាប់ពីម៉ោងប្រាំបួនព្រឹកថ្ងៃស្អែក។

សូមអញ្ជើញលោកមេធាវីការពារក្ដីជាតិ មេធាវីអន្តរជាតិការពារក្ដីឲ្យ នួន ជា!

[១៥:៥៩:៣៨]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ កាលពីសប្ដាហ៍មុន គឺលោកប្រធានសួរខ្ញុំថា តើខ្ញុំត្រូវការរយៈពេលប៉ុន្មានដើម្បីសាកសួរទៅលើសាក្សីរូបនេះ? យើងខ្ញុំគិតថា ខាងយើងខ្ញុំនោះអាចចំណាយពេលកន្លះថ្ងៃដើម្បីសាកសួរទៅកាន់សាក្សីរូបនេះ។ យើងដឹងថាគឺមួយម៉ោងកន្លះសម្រាប់មេធាវីការពារក្ដីនីមួយៗនោះ គឺមិនគ្រប់គ្រាន់នោះទេ។ ពីដំបូង គឺយើងខ្ញុំសូមថាបីក្រុមហ្នឹង គឺមួយថ្ងៃកន្លះ ហើយនៅពេលនេះគឺខ្ញុំសូមបញ្ជាក់ឲ្យច្បាស់លាស់ និងជាក់ដាក់តែម្ដងថា យើងត្រូវការកន្លះថ្ងៃ។

**ប្រធានអង្គជំនុំ៖**

បាទឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកហើយ ដូច្នេះអង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ ហើយសវនាការនឹងបន្តធ្វើនៅថ្ងៃស្អែក ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយចំណែកឯការកត់សម្គាល់របស់មេធាវីការពារក្ដី នួន ជា អម្បាញ់មិញនេះ អង្គជំនុំជម្រះនឹងជម្រាបជូននៅថ្ងៃស្អែក ពីព្រោះអង្គជំនុំជម្រះបានជម្រាបជូនដល់ភាគីរួចហើយអំពីពេលវេលាហើយនិងកាលបរិច្ឆេទក្នុងការមានសិទ្ធិក្នុងការសួរទៅសាក្សីរូបនេះ ប៉ុន្តែនេះជាសំណើបន្ថែមថ្មីដែលពីលើអ្វីដែលអង្គជំនុំជម្រះបានសម្រេចរួចហើយ។

ដូច្នេះអង្គជំនុំជម្រះនឹងជម្រាបជូននៅថ្ងៃស្អែកព្រលឹមឡើង គឺមុននឹងចាប់ផ្ដើមកិច្ចពិភាក្សា។

[១៦:០១:២៨]

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទាំងបីរូបទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ ហើយឲ្យនាំពួកគាត់ទាំងបីនាក់មកកាន់សាលសវនាការនេះនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។

អញ្ជើញសម្រាកចុះ៕

*(ចៅក្រមចាកចេញពីបន្ទប់សវនាការ)*

*(សវនាការផ្អាកនៅម៉ោង ១៦:០១នាទី)*